ក្រសួងបរិស្ថាន
MINISTRY OF ENVIRONMENT

# វិធានប្រតិបត្តិសម្រាប់ មាត្រា ៦ នៃកិច្ចព្រមព្រៀងទីក្រុងប៉ារីស ស្តីពីការប្រែប្រួលអាកាសធាតុ នៅកម្ពុជា

ឆ្នាំ ២០២៤



**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្តីការគណៈរដ្ឋមន្ត្រី**

**លេខ :** ១៣៨០ សសណ.សប

ថ្ងៃព្រហស្បតិ៍ ២កើត ខែមិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២៣

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**ជម្រាបជូន**

**ឯកឧត្តមរដ្ឋមន្ត្រីក្រសួងបរិស្ថាន**

**កម្មវត្ថុ៖** ករណីគោរពស្នើសុំអនុញ្ញាតជាគោលការណ៍ ដាក់ឱ្យប្រើប្រាស់វិធានប្រតិបត្តិសម្រាប់ការអនុវត្តមាត្រា៦ នៃកិច្ចព្រមព្រៀងប៉ារីស ស្តីពីការប្រែប្រួលអាកាសធាតុ។

**យោង** ៖- លិខិតលេខ២១៤៥ ស.ណ ប.ស្ត ចុះថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០២៣ របស់ក្រសួងបរិស្ថាន

- ចំណារដ៏ខ្ពង់ខ្ពស់បំផុតរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០២៣។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ទីស្តីការគណៈរដ្ឋមន្ត្រីសូមជម្រាបជូនឯកឧត្តមជ្រាបថា រាជរដ្ឋាភិបាលអនុញ្ញាតជូនឯកឧត្តមរដ្ឋមន្ត្រីក្រសួងបរិស្ថាន ដាក់ឱ្យប្រើប្រាស់វិធានប្រតិបត្តិសម្រាប់ការអនុវត្តមាត្រា៦ នៃកិច្ចព្រមព្រៀងប៉ារីសស្តីពីការប្រែប្រួលអាកាសធាតុ ដើម្បីជាលទ្ធភាពឱ្យក្រសួងបរិស្ថានស្វែងរកថវិកាពីការធ្វើពាណិជ្ជកម្មឥណទានកាបូនសម្រាប់មូលនិធិបរិស្ថាន និងសង្គម។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមជ្រាបនិងចាត់ចែងអនុវត្ត។

**ជ.រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**រដ្ឋលេខាធិការ**

**សួន សុភ័ណ្ឌា**

**ចម្លងជូន៖**

- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងពាណិជ្ជកម្ម
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ
- ឯកសារ កាលប្បវត្តិ

## អារម្ភកថា

នៅខែធ្នូ ឆ្នាំ២០១៥ រដ្ឋភាគីចំនួន១៩៦ នៃអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC) រួមទាំងព្រះរាជាណាចក្រកម្ពុជាបានអនុម័តកិច្ចព្រមព្រៀងទីក្រុងប៉ារីសស្តីពីការប្រែប្រួលអាកាសធាតុក្នុងគោលបំណងដើម្បីកម្រិតកំណើនកម្ដៅភពផែនដីឱ្យនៅក្រោម ២ អង្សាសែលស៊ុស ធៀបទៅនឹងកម្រិតមុនបដិវត្តន៍ឧស្សាហកម្ម និងបន្តកិច្ចខិតខំប្រឹងប្រែងកម្រិតកំណើនសីតុណ្ហភាពមធ្យមត្រឹម ១.៥ អង្សាសែលស៊ុស។ ភាគីទាំងអស់នៃកិច្ចព្រមព្រៀងទីក្រុងប៉ារីស តម្រូវឱ្យរៀបចំផែនការរួមចំណែករបស់ជាតិ (NDC) ដើម្បីអនុវត្តអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ ដែលបានកំណត់គោលដៅសម្រាប់សកម្មភាពកាត់បន្ថយ និងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ រៀងរាល់ ៥ឆ្នាំម្ដង ដើម្បីដាក់ជូនទៅ UNFCCC។

ប្រទេសកម្ពុជាបានធ្វើបច្ចុប្បន្នភាព NDC នៅឆ្នាំ២០២០ ដោយបានប្ដេជ្ញាកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ (GHG) ប្រមាណ ៤១,៧% បើធៀបទៅនឹងការព្យាករតាមទម្លាប់ធម្មតា (BAU) ជាមួយនឹងការគាំទ្រហិរញ្ញវត្ថុគ្រប់គ្រាន់។ ទន្ទឹមនឹងនេះ ប្រទេសកម្ពុជាបានដាក់ចេញនូវយុទ្ធសាស្ត្រអភិវឌ្ឍន៍រយៈពេលវែងប្រកបដោយអព្យាក្រឹតកាបូន (LTS4CN) នៅឆ្នាំ២០២១ ដោយបានកំណត់គោលដៅក្លាយជាប្រទេសអព្យាក្រឹតកាបូននៅឆ្នាំ២០៥០។ ការកំណត់គោលដៅកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ (GHG ER) គឺជាកិច្ចការប្រឈម ដែលចាំបាច់ត្រូវគិតគូរក្នុងការដាក់ចេញនូវសកម្មភាពកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ប្រកបដោយភាពច្នៃប្រឌិតជាច្រើន ដើម្បីឱ្យកម្ពុជាអាចបន្តបង្កើនការអភិវឌ្ឍសេដ្ឋកិច្ច និងឧស្សាហកម្មតាមរយៈវិធានការប្រកបដោយចីរភាព និងការបញ្ចេញកាបូនតិច។

មាត្រា៦ នៃកិច្ចព្រមព្រៀងទីក្រុងប៉ារីសស្តីពីការប្រែប្រួលអាកាសធាតុ អនុញ្ញាតឱ្យប្រទេសនានាសហការដោយស្ម័គ្រចិត្តក្នុងការអនុវត្ត NDC របស់ខ្លួន។ នៅក្នុងការអនុវត្តកិច្ចសហប្រតិបត្តិការស្ម័គ្រចិត្តក្រោមមាត្រា៦ សំដៅលើការធ្វើពាណិជ្ជកម្មជាអន្តរជាតិនៃឥណទាន GHG ER រវាងប្រទេសនានា ដោយ GHG ER ដែលសម្រេចបាននៅក្នុងប្រទេសមួយ ត្រូវបានរាប់បញ្ចូលទៅក្នុងលទ្ធផលនៃគោលដៅ NDC របស់ប្រទេសមួយផ្សេងទៀតជាថ្នូរនឹងការផ្តល់ថវិកា។ ហេតុដូចនេះហើយ វិធីសាស្ត្រសហការក្រោមមាត្រា៦ បានផ្តល់យន្តការមួយតាមរយៈហិរញ្ញវត្ថុអន្តរជាតិដល់គម្រោង GHG ER នានា ដែលប្រឈមនឹងឧបសគ្គក្នុងការអនុវត្ត។

ដើម្បីជួយសម្រួលដល់ការអនុវត្តវិធីសាស្ត្រសហការក្រោមមាត្រា៦ វិធានប្រតិបត្តិសម្រាប់មាត្រា៦ នៃកិច្ចព្រមព្រៀងទីក្រុងប៉ារីសស្តីពីការប្រែប្រួលអាកាសធាតុនៅកម្ពុជា ត្រូវបានរៀបចំឡើងតាមរយៈ

កិច្ចសហប្រតិបត្តិការរវាងក្រសួងបរិស្ថាន និងវិទ្យាស្ថានអភិវឌ្ឍន៍បៃតងសកល (GGGI)។ វិធានប្រតិបត្តិនេះ នឹងគាំទ្រដល់ការបង្កើនលំហូរហិរញ្ញវត្ថុសម្រាប់គម្រោងអាទិភាពរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ។ ឯកសារនេះ បង្កើតលក្ខណៈវិនិច្ឆ័យសម្រាប់គម្រោងនានានៅក្រោមមាត្រា៦ និងបញ្ជាក់ពីតួនាទីរបស់រាជរដ្ឋាភិបាលក្នុងការគ្រប់គ្រងដំណើរការពាក់ព័ន្ធនឹងមាត្រា៦។ វិធានប្រតិបត្តិនេះ នឹងផ្តល់នូវភាពច្បាស់លាស់ និងការធានាដល់ម្ចាស់គម្រោង និងអង្គភាពទិញដ៏មានសក្តានុពល ដែលនាំឱ្យមានកំណើននៃទីផ្សារកាបូនអន្តរជាតិប្រកបដោយសុចរិតភាពខ្ពស់។

ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះអន្តរក្រសួង ស្ថាប័ន និងអ្នកពាក់ព័ន្ធទាំងអស់ រួមទាំង GGGI ដែលបានផ្តល់ជំនួយផ្នែកប្រឹក្សាយោបល់ ជំនាញ និងជំនួយបច្ចេកទេសជាបន្តបន្ទាប់ ក្នុងការរៀបចំវិធានប្រតិបត្តិនេះបានគ្រប់ជ្រុងជ្រោយ។ វិធានប្រតិបត្តិនេះ គឺជាលទ្ធផលនៃការអនុវត្តការងារបែបបុរេសកម្ម ដែលត្រូវបានគិតគូរប្រកបដោយឈ្លាសវៃ ស្របទៅតាមស្ថានភាពនៃការអភិវឌ្ឍរបស់ប្រទេសកម្ពុជា៕

ថ្ងៃ អង្គារ ១៣ រោច ខែ មិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ មករា ឆ្នាំ២០២៤

**រដ្ឋមន្ត្រីក្រសួងបរិស្ថាន**

**បណ្ឌិត អ៊ាង សុផល្លែត**

## សេចក្តីណែនាំអំពីវិធានប្រតិបត្តិសម្រាប់មាត្រា ៦ នៃកិច្ចព្រមព្រៀងទីក្រុងប៉ារីសស្តីពីការប្រែប្រួលអាកាសធាតុនៅកម្ពុជា

វិធានប្រតិបត្តិសម្រាប់មាត្រា ៦ នៃកិច្ចព្រមព្រៀងទីក្រុងប៉ារីសស្តីពីការប្រែប្រួលអាកាសធាតុនៅកម្ពុជា (វិធានប្រតិបត្តិសម្រាប់មាត្រា ៦) បង្កើតនូវក្របខ័ណ្ឌស្ថាប័នសម្រាប់វិធីសាស្ត្រសហការសម្រាប់មាត្រា ៦ ដែលកម្ពុជាត្រូវបំពេញកាតព្វកិច្ចក្នុងនាមជារដ្ឋហត្ថលេខី។ វិធានប្រតិបត្តិសម្រាប់មាត្រា ៦ មានគោលបំណងផ្តល់ការណែនាំដល់តួអង្គដូចតទៅ៖

- **រាជរដ្ឋាភិបាលកម្ពុជា** (RGC) តាមរយៈការបញ្ជាក់អំពីតួនាទី និងទំនួលខុសត្រូវរបស់ជនបង្គោលជាតិក្នុងការអនុវត្តយន្តការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ (GHG ER) និងដំណើរការគ្រប់គ្រងសំណើសុំការអនុញ្ញាត (ជំពូកទី១-៣)
- **ម្ចាស់គម្រោងមានបំណងបង្កើតការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ (GHG ER) ដែលត្រូវបានអនុញ្ញាត តាមរយៈការអនុវត្តគម្រោងនានានៅកម្ពុជា** ដោយត្រូវឆ្លើយតបនឹងលក្ខណៈវិនិច្ឆ័យសម្រាប់ការវាយតម្លៃសំណើសុំការអនុញ្ញាត (ជំពូកទី២) និងបំពេញដំណើរការដាក់លាក់សម្រាប់គម្រោងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់នៃមាត្រា ៦ ដែលម្ចាស់គម្រោងត្រូវអនុវត្តតាម (ជំពូកទី៣)។
- **អង្គភាពទិញដែលមានសក្តានុពល** តាមរយៈការបង្ហាញឱ្យឃើញថា រាជរដ្ឋាភិបាលកម្ពុជាបានបង្កើតនូវយន្តការផ្តល់ការអនុញ្ញាត និងការរាយការណ៍អំពីវិធីសាស្ត្រសហការសម្រាប់មាត្រា ៦ ដែលកម្ពុជាជាប្រទេសហត្ថលេខី ហើយប្រទេសកម្ពុជាបានបំពេញតាមលក្ខខណ្ឌតម្រូវនៃការចូលរួមចំណែកអនុវត្តស្របតាមមាត្រា ៦.២ (ជំពូកទី១)។

វិធានប្រតិបត្តិនេះ មានរចនាសម្ព័ន្ធដូចខាងក្រោម៖

- **ជំពូកទី១** បរិយាយអំពីបរិបទ និងក្របខ័ណ្ឌគោលនយោបាយសម្រាប់ការចូលរួមរបស់ប្រទេសកម្ពុជាក្នុងវិធីសាស្ត្រសហការស្របតាមមាត្រា ៦ នៃកិច្ចព្រមព្រៀងទីក្រុងប៉ារីសស្តីពីការប្រែប្រួលអាកាសធាតុ។ ជំពូកនេះ បរិយាយអំពីយុទ្ធសាស្ត្រកាត់បន្ថយការប្រែប្រួលអាកាសធាតុ ក្របខ័ណ្ឌបទប្បញ្ញត្តិសម្រាប់ការគ្រប់គ្រងយន្តការទីផ្សារកាបូនរបស់រាជរដ្ឋាភិបាលកម្ពុជា រួមទាំងតួនាទីរបស់អាជ្ញាធរជាតិ សិទ្ធិកម្មសិទ្ធិលើការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ និងថ្លៃសេវារដ្ឋបាលពាក់ព័ន្ធ ព្រមទាំងវិធីសាស្ត្រ និងក្របខ័ណ្ឌសម្រាប់ការចូលរួមនៅក្នុងមាត្រា ៦ រួមទាំងរបៀបដែលកម្ពុជាបំពេញតាមលក្ខខណ្ឌតម្រូវសម្រាប់ការចូលរួមនៃមាត្រា ៦ ផងដែរ។
- **ជំពូកទី២** បរិយាយលម្អិតអំពីលក្ខណៈវិនិច្ឆ័យសិទ្ធិដែលគម្រោងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ត្រូវបំពេញតាមដើម្បីទទួលបានការអនុញ្ញាតស្របតាមមាត្រា ៦។

- **ជំពូកទី៣** បរិយាយអំពីដំណើរការ ដែលរាជរដ្ឋាភិបាលកម្ពុជាបានបង្កើតឡើងដើម្បីការអនុញ្ញាតចំពោះគម្រោងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ដែលបានអនុវត្តនៅកម្ពុជា ក៏ដូចជា ការចេញ និងការផ្ទេរ ឬការលុបចោលនូវការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ដែលបានអនុញ្ញាត។ ជំពូកទី៣ មានគោលបំណងណែនាំដល់ម្ចាស់គម្រោងអំពីដំណើរការដែលពួកគេត្រូវអនុវត្តតាម ក្នុងការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ដែលបានអនុញ្ញាតសម្រាប់ការផ្ទេរស្របតាមវិធីសាស្ត្រសហការនៃមាត្រា ៦.២ ដែលកម្ពុជាគឺជារដ្ឋហត្ថលេខី។

# បញ្ជីពាក្យបំព្រួញ

| ពាក្យកាត់ | និយមន័យ |
|---|---|
| CDM | យន្តការអភិវឌ្ឍន៍ស្អាត |
| CMA | សន្និសីទភាគី ដែលជាកិច្ចប្រជុំភាគីនៃកិច្ចព្រមព្រៀងទីក្រុងប៉ារីស |
| FOLU | ព្រៃឈើ និងការប្រើប្រាស់ដីផ្សេងៗ |
| GHG ER | ការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ |
| GGGI | វិទ្យាស្ថានអភិវឌ្ឍន៍បៃតងសកល |
| GWP | សក្តានុពលកម្តៅសកល |
| IPCC | ក្រុមការងារអន្តររដ្ឋាភិបាលស្តីពីការប្រែប្រួលអាកាសធាតុ |
| ITMO | លទ្ធផលនៃការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ដែលផ្ទេរជាអន្តរជាតិ |
| JCM | យន្តការឥណទានកាបូនរួមគ្នា |
| LTS4CN | យុទ្ធសាស្ត្រអភិវឌ្ឍន៍រយៈពេលវែងប្រកបដោយអព្យាក្រឹតកាបូន |
| MO | លទ្ធផលនៃការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ |
| NA | អាជ្ញាធរជាតិ |
| NCSD | ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព |
| NDC | ផែនការរួមចំណែករបស់ជាតិ ដើម្បីអនុវត្តអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ |
| NSGHGI | អនុក្រុមការងារសារពើភ័ណ្ឌឧស្ម័នផ្ទះកញ្ចក់ថ្នាក់ជាតិ |
| OIMP | គោលបំណងកាត់បន្ថយការបញ្ចេញឧស្ម័នជាអន្តរជាតិផ្សេងៗ |
| OMGE | ការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ជារួមនៅក្នុងការបញ្ចេញឧស្ម័នជាសកល |
| RGC | រាជរដ្ឋាភិបាលកម្ពុជា |
| SOP | ចំណែកប្រាក់ចំណេញ |
| UNFCCC | អនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ |
| VCS | ស្តង់ដារកាបូនស្ម័គ្រចិត្ត |

# និយមន័យនៃវាក្យសព្ទសំខាន់ៗ

ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាពនៃរាជរដ្ឋាភិបាលកម្ពុជា បានបង្កើតបញ្ជីវាក្យសព្ទសំខាន់ៗ និងនិយមន័យពាក់ព័ន្ធនឹងការអភិវឌ្ឍប្រកបដោយចីរភាព រួមជាមួយនឹងការបកប្រែផ្លូវការជាភាសាខ្មែរផងដែរ។[1] បញ្ជីវាក្យសព្ទនេះបង្កើតឡើងក្នុងគោលបំណង ដើម្បីបញ្ចៀសការភ័ន្តច្រឡំពាក់ព័ន្ធនឹងការប្រើប្រាស់ពាក្យពេចន៍ជាក់លាក់ណាមួយ ក៏ដូចជា ដើម្បីធានានូវសង្គតិភាពនៃការប្រើប្រាស់វាក្យសព្ទទាំងនោះ។ តារាងខាងក្រោមនេះ មានរៀបរាប់អំពីវាក្យសព្ទមួយចំនួនដែលប្រើប្រាស់នៅក្នុងសន្ធានុក្រម និងនៅក្នុងវិធានប្រតិបត្តិនេះ ព្រមទាំងវាក្យសព្ទត្រូវគ្នាផងដែរ។

| *វាក្យសព្ទ* | *ការប្រើប្រាស់ក្នុង UNFCCC* | *និយមន័យ* |
|---|---|---|
| ការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ (GHG ER) | លទ្ធផលនៃការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ (MO) | ការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ មានចំនួនមួយតោននៃការកាត់បន្ថយ ឬការដកការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ដោយវាស់វែងគិតជាលក្ខខណ្ឌសមមូលឧស្ម័នកាបូនិក ($CO_2$) (ឧ. ១ GHG ER = ១$tCO_2eq$)។ យោងតាមកិច្ចព្រមព្រៀងទីក្រុងប៉ារីសស្តីពីការប្រែប្រួលអាកាសធាតុ ការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់សំដៅលើ "លទ្ធផលនៃការកាត់បន្ថយការបញ្ចេញឧស្ម័ន ឬ MO"។ វិធានប្រតិបត្តិនេះ ប្រើប្រាស់ពាក្យថា ការកាត់បន្ថយ ការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ នៅពេលសំដៅដល់លទ្ធផលនៃការកាត់បន្ថយការបញ្ចេញឧស្ម័ន។ |
| គម្រោងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ (គម្រោង GHG ER) | សកម្មភាពកាត់បន្ថយការបញ្ចេញឧស្ម័ននិង/ឬ វិធីសាស្ត្រសហការ | គម្រោងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់គឺជាសកម្មភាពមូលដ្ឋាននាំឱ្យមានការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់។ យោងតាមកិច្ចព្រមព្រៀងទីក្រុងប៉ារីសស្តីពីការប្រែប្រួលអាកាសធាតុ គម្រោងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ សំដៅដល់ "សកម្មភាពកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់"។ វិធានប្រតិបត្តិនេះប្រើប្រាស់ពាក្យថា គម្រោងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ នៅពេលសំដៅលើសកម្មភាពកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់។ មាត្រា ៦.២ នៃកិច្ចព្រមព្រៀងទីក្រុងប៉ារីសស្តីពីការប្រែប្រួលអាកាសធាតុ ក៏សំដៅលើ "វិធីសាស្ត្រសហការ" ហើយរាជរដ្ឋាភិបាលកម្ពុជា ត្រូវតែផ្តល់ការអនុញ្ញាតសម្រាប់វិធីសាស្ត្រសហការ ដែល |

[1] https://ncsd.moe.gov.kh/lexicon

| | | |
|---|---|---|
| | | ប្រទេសកម្ពុជាគឺជាភាគីចូលរួម។ ដើម្បីឱ្យជ្រាបច្បាស់ "វិធីសាស្ត្រសហការ" នៅក្នុងបរិបទវិធានប្រតិបត្តិនេះ សំដៅលើគម្រោងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ដែលបង្កើតការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់សម្រាប់ប្រើប្រាស់ក្រោមមាត្រា ៦។ |
| ការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ដែលបានអនុញ្ញាតក្រោមមាត្រា ៦ (GHG ER ដែលបានអនុញ្ញាត) | លទ្ធផលនៃការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ដែលផ្ទេរជាអន្តរជាតិ (ITMO) | "ការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ដែលបានអនុញ្ញាតក្រោមមាត្រា ៦" សំដៅលើការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ដែលរដ្ឋាភិបាលកម្ពុជាបានផ្តល់ការអនុញ្ញាតសម្រាប់ការផ្ទេរជាអន្តរជាតិស្របតាមវិធីសាស្ត្រសហការសម្រាប់មាត្រា ៦។ យោងតាមកិច្ចព្រមព្រៀងទីក្រុងប៉ារីសស្តីពីការប្រែប្រួលអាកាសធាតុ ការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ដែលបានអនុញ្ញាតក្រោមមាត្រា ៦ សំដៅលើ "លទ្ធផលនៃការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ដែលផ្ទេរជាអន្តរជាតិ" ឬ ITMOs។ វិធានប្រតិបត្តិនេះប្រើប្រាស់ពាក្យថា ការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ដែលបានអនុញ្ញាតក្រោមមាត្រា ៦ នៅពេលសំដៅលើសកម្មភាពកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់។ |
| វិធានប្រតិបត្តិមាត្រា ៦.២ | សេចក្តីសម្រេច ២/CMA.៣ និង សេចក្តីសម្រេច -/CMA.៤ | ពាក្យថា "វិធានប្រតិបត្តិមាត្រា ៦.២" ក្នុងបរិបទនៃវិធានប្រតិបត្តិនេះ សំដៅដល់សេចក្តីសម្រេចពាក់ព័ន្ធនានា ដែលជាកិច្ចប្រជុំភាគីនៃកិច្ចព្រមព្រៀងទីក្រុងប៉ារីស (CMA) បានធ្វើឡើង ដើម្បីផ្តល់នូវវិធានអំពីវិធីសាស្ត្រសហការ ដែលមាននៅក្នុងមាត្រា ៦ កថាខណ្ឌទី២ នៃកិច្ចព្រមព្រៀងទីក្រុងប៉ារីសស្តីពីការប្រែប្រួលអាកាសធាតុ។ សេចក្តីសម្រេចនេះ អាចរួមមានសេចក្តីសម្រេចដែលបានធ្វើឡើងនៅក្នុងកិច្ចប្រជុំ COP២៦ (សេចក្តី សម្រេច ២/CMA.៣) និង COP២៧ (សេចក្តីសម្រេច -/CMA.៤)។[2] |

[2] រាល់សេចក្តីសម្រេចទាំងអស់មានផ្សព្វផ្សាយនៅលើវែបសាយត៍ https://unfccc.int/process/the-paris-agreement/cooperative-implementation

## មាតិកា

សេចក្តីណែនាំអំពីវិធានប្រតិបត្តិសម្រាប់មាត្រា ៦ នៃកិច្ចព្រមព្រៀងទីក្រុងប៉ារីសស្តីពីការប្រែប្រួលអាកាសធាតុនៅកម្ពុជា ....... i

បញ្ជីពាក្យបំព្រួញ ....... iii

និយមន័យនៃវាក្យសព្ទសំខាន់ៗ ....... iv

មាតិកា ....... vi

បញ្ជីរូបភាព ....... viii

បញ្ជីតារាង ....... ix

១. បរិបទ និងក្របខ័ណ្ឌសម្រាប់ការចូលរួមក្នុងវិធីសាស្រ្តសហការ ស្របតាមមាត្រា ៦ នៃកិច្ចព្រមព្រៀងទីក្រុងប៉ារីសស្តីពីការប្រែប្រួលអាកាសធាតុ....... ១

១.១ កិច្ចព្រមព្រៀងទីក្រុងប៉ារីសស្តីពីការប្រែប្រួលអាកាសធាតុ និងការចូលរួមចំណែករបស់ជាតិ ....... ១

១.២ យុទ្ធសាស្រ្តកាត់បន្ថយការប្រែប្រួលអាកាសធាតុរបស់ប្រទេសកម្ពុជា ....... ៤

១.៣ ក្របខ័ណ្ឌបទប្បញ្ញត្តិសម្រាប់ការគ្រប់គ្រងយន្តការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ....... ៥

១.៤ វិធីសាស្រ្តចូលរួមក្រោមមាត្រា ៦ និងលក្ខខណ្ឌតម្រូវសម្រាប់ការចូលរួម ....... ១០

២. លក្ខណៈវិនិច្ឆ័យសិទ្ធិនៃគម្រោងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ដើម្បីទទួលបានការអនុញ្ញាតក្រោមមាត្រា ៦....... ១៤

២.១. លក្ខខណ្ឌវិនិច្ឆ័យដើម្បីទទួលការអនុញ្ញាតសម្រាប់គម្រោង GHG ER....... ១៤

៣. ដំណើរការសម្រាប់គម្រោងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ក្រោមមាត្រា ៦ ....... ២៥

៣.១ រចនាសម្ព័ន្ធនៃជំពូក....... ២៦

៣.២ ដំណាក់កាលមុនអនុវត្តគម្រោង ....... ២៨

៣.៣ ការអនុវត្តគម្រោង ....... ៣៤

៣.៤ ការចេញ និងផ្ទេរ/លុបចោល ....... ៣៨

ឧបសម្ព័ន្ធ៖ ឯកសារគំរូ ....... ៤៥

១.សំណើសុំលិខិតគាំទ្រសម្រាប់គម្រោងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ....... ៤៦

២.លិខិតគាំទ្រសម្រាប់គម្រោងការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ....... ៥០

៣. ស្នើសុំលិខិតអនុញ្ញាតកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ............................................................ ៥២
៤. លិខិតអនុញ្ញាតសម្រាប់ការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់..................................................... ៥៨
៥. សំណើសុំការត្រួតពិនិត្យវិជ្ជមាន................................................................................................ ៦២
៦. លិខិតត្រួតពិនិត្យវិជ្ជមាន ........................................................................................................ ៦៤

# បញ្ជីរូបភាព

រូបភាព ១៖ ការប្រើប្រាស់ GHG ER ដែលមានការអនុញ្ញាត និងមិនមានការអនុញ្ញាតពក្រោមមាត្រា ៦ នៃកិច្ចព្រមព្រៀងទីក្រុងប៉ារីស ........ ០៣
រូបភាព ២៖ យុទ្ធសាស្រ្តចូលរួមក្រោមមាត្រា ៦ របស់ប្រទេសកម្ពុជា ........ ១២
រូបភាព ៣៖ ដំណាក់កាលនៃវដ្ត GHG ER មាត្រា ៦ ........ ២៨
រូបភាព ៤៖ ដំណើរការផ្តល់ការអនុញ្ញាតលើ GHG ER ........ ៣០
រូបភាព ៥៖ ដំណើរការសម្រាប់ការត្រួតពិនិត្យវិជ្ជមាននៃការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ........ ៣៨
រូបភាព ៦៖ ដំណើរការសម្រាប់ការចេញ និងផ្ទេរ/លុបចោលការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ដែលបានអនុញ្ញាត ........ ៤៣

# បញ្ជីតារាង

តារាង ១៖ លក្ខណៈវិនិច្ឆ័យដើម្បីទទួលបានការអនុញ្ញាតក្រោមមាត្រា ៦ នៃគម្រោង GHG ER ក្នុងប្រទេសកម្ពុជា ........................................................................ ១៦
តារាង ២៖ បញ្ជីលក្ខណៈវិនិច្ឆ័យអភិវឌ្ឍន៍ប្រកបដោយចីរភាពសម្រាប់ការវាយតម្លៃសំណើសុំគម្រោងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់នៅកម្ពុជា........................................................................ ២១
តារាង ៣៖ ការពិពណ៌នាអំពីតួអង្គ........................................................................ ២៩
តារាង ៤៖ដំណើរការសម្រាប់ការស្នើសុំលិខិតគាំទ្រលើគម្រោងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ......៣១
តារាង ៥៖ ដំណើរការសម្រាប់ការអនុញ្ញាតការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ..............................៣៤
តារាង ៦៖ ដំណើរការសម្រាប់ការត្រួតពិនិត្យវិជ្ជមាននៃការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់............. ៤០
តារាង ៧៖ ការចេញ ការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ដែលបានអនុញ្ញាត................................. ៤៤
តារាង ៨៖ ការផ្ទេរ/ការលុបចោលការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ដែលបានអនុញ្ញាត ................ ៤៦

## ១. បរិបទ និងក្របខ័ណ្ឌសម្រាប់ការចូលរួមក្នុងវិធីសាស្ត្រសហការ ស្របតាមមាត្រា ៦ នៃកិច្ចព្រមព្រៀងទីក្រុងប៉ារីសស្តីពីការប្រែប្រួលអាកាសធាតុ

ជំពូកនេះ បរិយាយអំពីបរិបទ និងក្របខ័ណ្ឌគោលនយោបាយសម្រាប់ការចូលរួមរបស់កម្ពុជានៅក្នុងវិធីសាស្ត្រសហការ ស្របតាមមាត្រា ៦ នៃកិច្ចព្រមព្រៀងទីក្រុងប៉ារីសស្តីពីការប្រែប្រួលអាកាសធាតុ។ ជំពូកនេះ កំណត់នូវយុទ្ធសាស្ត្រ កាត់បន្ថយការប្រែប្រួលអាកាសធាតុរបស់រាជរដ្ឋាភិបាលកម្ពុជា ក្របខ័ណ្ឌបទប្បញ្ញត្តិសម្រាប់ការគ្រប់គ្រងយន្តការទីផ្សារកាបូន រួមទាំងអង្គភាពដែលទទួលបានអាណត្តិក្នុងការដើរតួនាទីជំនួសមុខឱ្យរាជរដ្ឋាភិបាលកម្ពុជា ពាក់ព័ន្ធនឹងវិធីសាស្ត្រសហការនៃមាត្រា ៦ និងសិទ្ធិកម្មសិទ្ធិពាក់ព័ន្ធនឹងការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ និងវិធីសាស្ត្រ និងក្របខ័ណ្ឌសម្រាប់ការចូលរួមអនុវត្តមាត្រា ៦ របស់រាជរដ្ឋាភិបាលកម្ពុជាព្រមទាំងរបៀបដែលកម្ពុជាបំពេញតាមលក្ខខណ្ឌចូលរួមអនុវត្តមាត្រា ៦ ផងដែរ។

### ១.១ កិច្ចព្រមព្រៀងទីក្រុងប៉ារីសស្តីពីការប្រែប្រួលអាកាសធាតុ និងការចូលរួមចំណែករបស់ជាតិ

កិច្ចព្រមព្រៀងទីក្រុងប៉ារីសដែលរដ្ឋភាគីនៃអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC) ចំនួន ១៩៦ បានអនុម័ត កាលពីខែធ្នូ ឆ្នាំ២០១៥ មានគោលបំណងកាត់បន្ថយការកើនឡើងនូវកម្តៅផែនដីឱ្យស្ថិតក្រោមកម្រិត ២ អង្សាសែលស៊ុស ធៀបទៅនឹងកម្រិតមុនពេលបដិវត្តន៍ឧស្សាហកម្ម ព្រមទាំងខិតខំប្រឹងប្រែងកម្រិតការកើនឡើងសីតុណ្ហភាពត្រឹម ១.៥ អង្សាសែលស៊ុស។ គ្រប់រដ្ឋភាគីទាំងអស់នៃកិច្ចព្រមព្រៀង ទីក្រុងប៉ារីស ត្រូវដាក់ចេញផែនការ និងគោលដៅថ្នាក់ជាតិដើម្បីអនុវត្តសកម្មភាពកាត់បន្ថយ និងសកម្មភាពបន្សាំ ទៅនឹងការប្រែប្រួលអាកាសធាតុ។ ផែនការ ដែលត្រូវធ្វើបច្ចុប្បន្នភាព និងផ្ញើជូន UNFCCC រៀងរាល់ ៥ ឆ្នាំម្តងនេះហៅថា ផែនការរួមចំណែករបស់ជាតិដើម្បីអនុវត្តអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (NDC)។

មាត្រា ៦ នៃកិច្ចព្រមព្រៀងទីក្រុងប៉ារីសស្តីពីការប្រែប្រួលអាកាសធាតុ អនុញ្ញាតឱ្យប្រទេសនានាចូលរួមសហការដោយស្ម័គ្រចិត្ត ក្នុងការអនុវត្ត NDC នេះ។ កិច្ចសហការដោយស្ម័គ្រចិត្តក្រោមមាត្រា ៦ នេះ សំដៅលើការធ្វើពាណិជ្ជកម្មឥណទាននៃការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ជាអន្តរជាតិរវាងប្រទេស និងប្រទេស ដែលប្រទេសមួយសម្រេចបាននូវការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ អាចរាប់បញ្ចូលទៅក្នុងគោលដៅ NDC របស់ប្រទេសមួយទៀតបាន តាមរយៈការទិញលក់។[3] ដូច្នេះ វិធីសាស្ត្រសហការសម្រាប់មាត្រា ៦ កំណត់យន្តការសម្រាប់ស្នើសុំហិរញ្ញវត្ថុអន្តរជាតិសម្រាប់គម្រោងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ដែលប្រឈមនឹងឧបសគ្គក្នុងការអនុវត្ត។

[3] មាត្រា ៦ ចែងអំពី GHG ER ដែលអាចផ្ទេរជាអន្តរជាតិក្នុងគោលបំណងកាត់បន្ថយការបញ្ចេញឧស្ម័នជាអន្តរជាតិ ជាជាងវិធីសាស្ត្រសហការ ឬសម្រាប់គោលបំណងផ្សេងៗដែលបានកំណត់ដោយភាគីផ្ទេរ។ គោលបំណងទាំងនេះ ត្រូវបានហៅរួមគ្នាថាជា "គោលបំណងកាត់បន្ថយការបញ្ចេញឧស្ម័នជាអន្តរជាតិផ្សេងៗ"។

**បញ្ញត្តិសំខាន់ៗក្នុងមាត្រា ៦ នៃកិច្ចព្រមព្រៀងទីក្រុងប៉ារីសស្តីពីការប្រែប្រួលអាកាសធាតុ**

ខាងក្រោមនេះ គឺជាកថាខណ្ឌពាក់ព័ន្ធមួយចំនួននៃមាត្រា ៦ សម្រាប់ការអនុវត្តៈ

- **មាត្រា ៦.២** ផ្តល់នូវមូលដ្ឋានសម្រាប់ប្រទេសនានា ក្នុងការចូលរួមអនុវត្តវិធីសាស្រ្តសហការ។ ឯកសារអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC) បានផ្តល់នូវវិធានប្រតិបត្តិអំពីកិច្ចសហការនៃមាត្រា ៦.២ ក្នុងនោះរួមបញ្ចូលទាំងលក្ខខណ្ឌតម្រូវសម្រាប់ការចូលរួម និងការរាយការណ៍ផងដែរ។[4] វិធានប្រតិបត្តិមាត្រា ៦.២ នេះ ក៏បញ្ជាក់យ៉ាងច្បាស់អំពីរបៀប គណនាការផ្ទេរ អត្រាការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ (GHG ER) ជាអន្តរជាតិ តាមរយៈការអនុវត្តវិធីសាស្ត្រកែតម្រូវឱ្យត្រូវគ្នាផងដែរ។ មាត្រា ៦.២ ជាក្របខ័ណ្ឌគ្រប់ជ្រុងជ្រោយមួយសម្រាប់ការផ្ទេរជាអន្តរជាតិនូវ ការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ទាំងអស់ "ដែលបានអនុញ្ញាត" ដោយប្រទេសម្ចាស់ផ្ទះ ដោយមិនគិតអំពីយន្តការដែលការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ត្រូវបានចេញជូននោះទេ (រូបភាព១)។
- **មាត្រា ៦.៤** បង្កើតយន្តការអន្តរជាតិជារួមមួយ ដែលយន្តការនេះនឹងចេញការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ បន្តពីយន្តការអភិវឌ្ឍន៍ស្អាត (CDM)។[5] ការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ដែលបានចេញជូនស្របតាមយន្តការមាត្រា ៦.៤ ត្រូវតែនៅមានការអនុញ្ញាតស្របតាមវិធានប្រតិបត្តិនៃមាត្រា ៦.២ ដដែល ដើម្បីអាចប្រើប្រាស់សម្រាប់ NDC របស់ប្រទេសមួយផ្សេងទៀតក្នុងគោលបំណងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ជាអន្តរជាតិផ្សេងៗ ដូចមានបង្ហាញក្នុង រូបភាព១។ យន្តការដែលបានបង្កើតឡើងក្រោមមាត្រា ៦.៤ ត្រូវស្ថិតក្រោមការគ្រប់គ្រងដោយអង្គភាពត្រួតពិនិត្យអន្តរជាតិស្របតាមវិធានប្រតិបត្តិរបស់កិច្ចព្រមព្រៀងទីក្រុងប៉ារីសស្តីពីការប្រែប្រួលអាកាសធាតុ។[6]

មាត្រា ៦.៨ កំណត់ "យុទ្ធសាស្រ្តមិនមែនទីផ្សារ" ដែលមិនតម្រូវឱ្យមានការផ្ទេរការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់នោះទេ។ វិធីសាស្រ្តនេះគឺមិនស្ថិតនៅក្រោមវិសាលភាពនៃឯកសារនេះនោះទេ។

---

[4] UNFCCC សេចក្តីសម្រេច ២/CMA.៣ និងសេចក្តីសម្រេច ៦/CMA.៤។

[5] UNFCCC សេចក្តីសម្រេច ៣/CMA.៣ ឧបសម្ព័ន្ធ មាននៅលើគេហទំព័រ https://unfccc.int/sites/default/files/resource/cma2021_10_add1_adv.pdf#page=25 ។

[6] អង្គភាពត្រួតពិនិត្យ គឺមានសមាជិក ១២ រូប ដែលជាតំណាងមកពីនៅក្នុងកិច្ចព្រមព្រៀងទីក្រុងប៉ារីស។ អង្គភាពត្រួតពិនិត្យ ត្រូវទទួលខុសត្រូវចំពោះ CMA។

## សារៈសំខាន់នៃការអនុញ្ញាតរបស់ប្រទេសម្ចាស់ផ្ទះស្របតាមមាត្រា ៦

សកម្មភាពសំខាន់ៗដែលប្រទេសម្ចាស់ផ្ទះ[7] បានអនុវត្តដើម្បីអនុញ្ញាតឱ្យមានសកម្មភាពកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់សម្រាប់ការផ្ទេរជាអន្តរជាតិស្របតាមមាត្រា ៦ គឺជា "ការអនុញ្ញាត"។ ការអនុញ្ញាតឱ្យមានការផ្ទេរការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ដោយប្រទេសម្ចាស់ផ្ទះ ក៏បានបញ្ជាក់អំពីកាតព្វកិច្ចក្នុងការអនុវត្តវិធីសាស្ត្រកែតម្រូវឱ្យត្រូវគ្នាផងដែរ នៅពេលផ្ទេរការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់លើកដំបូង ពោលគឺស្របតាមវិធានប្រតិបត្តិមាត្រា ៦.២។ ដូច្នេះ ប្រទេសម្ចាស់ផ្ទះ ត្រូវរៀបចំក្របខ័ណ្ឌស្ថាប័នដ៏រឹងមាំមួយសម្រាប់ការអនុញ្ញាតឱ្យមានការផ្ទេរការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់នេះ។

*រូបភាព១៖ ការប្រើប្រាស់ GHG ER ដែលមានការអនុញ្ញាត និងគ្មានការអនុញ្ញាតនៅក្រោមមាត្រា ៦ នៃកិច្ចព្រមព្រៀងទីក្រុងប៉ារីស*




លើសពីនេះទៅទៀត ការអនុញ្ញាតចំពោះការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ក្រោមក្របខ័ណ្ឌមាត្រា ៦.២ ក៏មានឥទ្ធិពលលើប្រភេទនៃការអះអាងរបស់ភាគីទិញការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ផងដែរ។ ដូចមានបង្ហាញនៅក្នុង រូបភាព១ ការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ អាចត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ ដើម្បីបង្គ្រប់គោលដៅ NDC របស់ប្រទេសមួយទៀត ឬសម្រាប់គោលបំណងកាត់បន្ថយការបញ្ចេញឧស្ម័នជាអន្តរជាតិផ្សេងៗ ក្នុងនោះរាប់បញ្ចូលទាំងការកាត់កងដោយស្ម័គ្រចិត្ត ឬសម្រាប់ប្រើប្រាស់ស្របតាមកម្មវិធីអនុលោមភាព ដូចជា CORSIA កម្មវិធីកាត់កងសម្រាប់ក្រុមហ៊ុនអាកាសចរណ៍អន្តរជាតិ។ ការប្រើប្រាស់ការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ដែលពុំមានការអនុញ្ញាតគឺកាន់តែមានភាពរឹតត្បិតក្រោមក្របខ័ណ្ឌដែលបានផ្តល់ជូនដោយកិច្ចព្រមព្រៀងទីក្រុងប៉ារីស។

---

[7] ប្រទេសដឹកនាំគម្រោង GHG ER បង្កើត GHG ER សម្រាប់ការផ្ទេរជាអន្តរជាតិស្របតាមមាត្រា ៦ ឬក៏ហៅម្យ៉ាងទៀតថា "ប្រទេសភាគីលក់" ឬ "ប្រទេសផ្ទេរ"។

## ១.២ យុទ្ធសាស្ត្រកាត់បន្ថយការប្រែប្រួលអាកាសធាតុរបស់ប្រទេសកម្ពុជា

ប្រទេសកម្ពុជា ជាភាគីនៃ UNFCCC និងបានផ្តល់សច្ចាប័នកិច្ចព្រមព្រៀងទីក្រុងប៉ារីសនេះនៅក្នុងខែកុម្ភៈ ឆ្នាំ ២០១៧។ ទោះបីជាបានរួមចំណែកតិចតួចចំពោះការបញ្ចេញឧស្ម័នផ្ទះកញ្ចក់សកលនាពេលកន្លងមក តែកម្ពុជាបានប្តេជ្ញាអនុវត្តសកម្មភាពកាត់បន្ថយការប្រែប្រួលអាកាសធាតុប្រកបដោយមហិច្ឆតា តាមរយៈ NDC ដែលបានធ្វើបច្ចុប្បន្នភាព និងយុទ្ធសាស្ត្រអភិវឌ្ឍន៍រយៈពេលវែងប្រកបដោយអព្យាក្រឹតកាបូន (LTS4CN) ត្រឹមឆ្នាំ២០៥០។

### ផែនការបច្ចុប្បន្នភាពរួមចំណែករបស់ជាតិ ដើម្បីអនុវត្តអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (Updated NDC)

ក្នុងឆ្នាំ២០២០ រាជរដ្ឋាភិបាលកម្ពុជា បានដាក់ផែនការបច្ចុប្បន្នភាពរួមចំណែករបស់ជាតិ ដើម្បីអនុវត្តអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (Updated NDC) ជូន UNFCCC ដែលក្នុងនោះ ក៏បានដាក់បញ្ចូលនូវការប្តេជ្ញាចិត្តក្នុងការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ថ្នាក់ជាតិត្រឹម ៦៤.៦ លានតោន $CO_2$ ក្នុងឆ្នាំ២០៣០ ធៀបនឹងសេណារីយ៉ូបន្ទាត់មូលដ្ឋាន "ការព្យាករណ៍តាមទម្លាប់ធម្មតា"។[8] ថ្លៃចំណាយលើការអនុវត្តសកម្មភាពកាត់បន្ថយការបញ្ចេញឧស្ម័នដែលបានកំណត់នៅក្នុង NDC គឺត្រូវបានប៉ាន់ស្មានថាមានចំនួនប្រហែល ៥.៨ ប៊ីលានដុល្លារសម្រាប់រយៈពេលចាប់ពីឆ្នាំ២០២១ ទៅឆ្នាំ២០៣០ ដោយសកម្មភាពភាគច្រើនគឺជាសកម្មភាពមានលក្ខខណ្ឌផ្អែកលើការផ្តល់ហិរញ្ញប្បទានអន្តរជាតិ។ ដើម្បីសម្រេចបាននូវគោលដៅ NDC របស់ខ្លួន ប្រទេសកម្ពុជាបានបង្ហាញថាវិធីសាស្ត្រសហការមាត្រា ៦ គឺជាផ្នែកមួយនៃយុទ្ធសាស្ត្រផ្តល់ហិរញ្ញប្បទានដែលត្រូវបានប្រើប្រាស់ ដើម្បីសម្រេចទៅតាមគោលដៅដាក់លាក់តាមវិស័យ។

### យុទ្ធសាស្ត្រអភិវឌ្ឍន៍រយៈពេលវែងប្រកបដោយអព្យាក្រឹតកាបូន (LTS4CN)

ក្នុងឆ្នាំ២០២១ រាជរដ្ឋាភិបាលកម្ពុជាបានដាក់នូវយុទ្ធសាស្ត្រអភិវឌ្ឍន៍រយៈពេលវែងប្រកបដោយអព្យាក្រឹតកាបូន (LTS4CN) ជូនទៅកាន់ UNFCCC។[9] LTS4CN រៀបរាប់អំពីផែនការរបស់ប្រទេសកម្ពុជា ក្នុងការសម្រេចឱ្យបាននូវគោលដៅមិនបញ្ចេញឧស្ម័នផ្ទះកញ្ចក់ត្រឹមឆ្នាំ២០៥០ ដែលស្របតាមគោលដៅនៃកិច្ចព្រមព្រៀងទីក្រុងប៉ារីស ដើម្បីកម្រិតនូវការកើនឡើងនៃកម្តៅភពផែនដី។ ថ្លៃចំណាយប្រចាំឆ្នាំលើការអនុវត្តយុទ្ធសាស្ត្រ LTS4CN នេះគឺត្រូវបានព្យាករណ៍ថាមានចំនួន ៦៩០ លានដុល្លារអាមេរិក ក្នុងឆ្នាំ២០២៣ ហើយកើនឡើងដល់ ២ ប៊ីលានដុល្លារអាមេរិកនៅឆ្នាំ២០៥០។ ការវិនិយោគពីវិស័យឯកជន ត្រូវបានរំពឹងមានចំនួនប្រមាណជា ៧៥% ថេរនៃបន្ទុកហិរញ្ញវត្ថុនៃការអនុវត្ត LTS4CN។

[8] https://unfccc.int/sites/default/files/NDC/2022-06/20201231_NDC_Updated_Cambodia.pdf
[9] https://unfccc.int/sites/default/files/resource/KHM_LTS_Dec2021.pdf

## ១.៣ ក្របខ័ណ្ឌបទប្បញ្ញត្តិសម្រាប់ការគ្រប់គ្រងយន្តការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់

### ការបង្កើតអាជ្ញាធរជាតិសម្រាប់យន្តការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ (GHG ER)

រាជរដ្ឋាភិបាលកម្ពុជា បានចាត់តាំងឱ្យក្រសួងបរិស្ថានធ្វើជាអាជ្ញាធរជាតិអចិន្ត្រៃយ៍សម្រាប់យន្តការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ (GHG ER) (តទៅនេះហៅកាត់ថា "អាជ្ញាធរជាតិ")។ អាជ្ញាធរជាតិនេះ គឺជាអង្គភាពទទួលបានការអនុញ្ញាតទាំងស្រុងក្នុងការដើរតួនាទីជំនួសមុខឱ្យរាជរដ្ឋាភិបាលកម្ពុជា នៅពេលចេញលិខិតគាំទ្រសម្រាប់គម្រោងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ និងការចេញលិខិតអនុញ្ញាត និងលិខិតត្រួតពិនិត្យវិជ្ជមានសម្រាប់ការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ដែលបានមកពីគម្រោងមានលក្ខណៈសម្បត្តិគ្រប់គ្រាន់នៅក្នុងប្រទេសកម្ពុជា។ អាជ្ញាធរជាតិនេះ ក៏ត្រូវទទួលខុសត្រូវចំពោះការអនុវត្តវិធីសាស្ត្រសហការនៅក្រោមមាត្រា ៦ នៃកិច្ចព្រមព្រៀងទីក្រុងប៉ារីស ជាមួយភាគីផ្សេងៗជំនួសមុខឱ្យរាជរដ្ឋាភិបាលកម្ពុជាផងដែរ។

រចនាសម្ព័ន្ធ មុខងារ និងលក្ខណៈវិនិច្ឆ័យរបស់អាជ្ញាធរជាតិនេះ អាចនឹងត្រូវធ្វើវិសោធនកម្មនៅក្នុងក្របខ័ណ្ឌបទប្បញ្ញត្តិបន្ថែម ដែលនឹងត្រូវរៀបចំឡើងដោយក្រសួងបរិស្ថាន។

<u>**រចនាសម្ព័ន្ធរបស់អាជ្ញាធរជាតិ**</u>

អាជ្ញាធរជាតិ ត្រូវមានសមាសភាពដូចខាងក្រោម៖

1. **ប្រធានអាជ្ញាធរជាតិ**
2. **អ្នកសម្របសម្រួលអាជ្ញាធរជាតិ**
3. **ក្រុមបច្ចេកទេសអាជ្ញាធរជាតិ**
4. **លេខាធិការដ្ឋានអាជ្ញាធរជាតិ**

ប្រធានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព / រដ្ឋមន្ត្រីក្រសួងបរិស្ថាន ត្រូវដើរតួនាទីជាប្រធានអាជ្ញាធរជាតិ។

<u>**មុខងាររបស់អាជ្ញាធរជាតិ**</u>

1. **ប្រធានអាជ្ញាធរជាតិ**

   ក. ប្រធានអាជ្ញាធរជាតិត្រូវតែជាតំណាងដែលទទួលបានការអនុញ្ញាតតែម្នាក់គត់ក្នុងការចុះហត្ថលេខា លើលិខិតអនុញ្ញាតសម្រាប់ការផ្ទេរអន្តរជាតិនៃការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ក្រោមមាត្រា ៦ បន្ទាប់ពី ទទួលអនុសាសន៍ណែនាំពីអ្នកសម្របសម្រួលអាជ្ញាធរជាតិ។

2. **អ្នកសម្របសម្រួលអាជ្ញាធរជាតិ**

   ក. ចុះហត្ថលេខាលើលិខិតគាំទ្រសម្រាប់គម្រោងការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់។

ខ. លើកសំណើសុំការអនុញ្ញាត និងគាំទ្រលើគម្រោងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ដោយពិចារណាអំពីលទ្ធផលរកឃើញ និងអនុសាសន៍ក្នុងរបាយការណ៍វាយតម្លៃបច្ចេកទេស ដែលបានរៀបចំឡើងដោយ ក្រុមការងារបច្ចេកទេសរបស់អាជ្ញាធរជាតិ។

គ. ដាក់លិខិតអនុញ្ញាតលើសំណើគម្រោងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ជូនប្រធានអាជ្ញាធរជាតិដើម្បីចុះហត្ថលេខា។

ឃ. ជូនដំណឹងដល់ភាគីស្នើសុំយន្តការគម្រោងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់អំពីការបដិសេធ សំណើសុំលិខិតគាំទ្រ លិខិតអនុញ្ញាត និងការពិនិត្យវិជ្ជមាន។

ង. ជ្រើសរើស ឬអញ្ជើញអ្នកជំនាញជាតិ និងអន្តរជាតិឱ្យជួយដល់ក្រុមបច្ចេកទេសអាជ្ញាធរជាតិ នៅក្នុងការវាយតម្លៃឯកសារគម្រោងក្នុងករណីចាំបាច់។

ច. តាមដានលើអនុលោមភាពតាមបញ្ញត្តិនៃវិធានប្រតិបត្តិសម្រាប់មាត្រា ៦ និងផ្ដល់អនុសាសន៍ជូនប្រធានដើម្បីដាក់ទណ្ឌកម្ម ក្នុងករណីចាំបាច់ ដែលរួមបញ្ចូលការដកការអនុម័ត ក្នុងករណីការអនុវត្តគម្រោងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់មិនគោរពតាមការសន្យា ដូចមានចែងក្នុងលិខិតអនុញ្ញាត។

ឆ. ជូនដំណឹងដល់ម្ចាស់គម្រោងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ពាក់ព័ន្ធយន្តការឥណទានកាបូន និងប្រទេសភាគីទិញអំពីការលុបចោលការអនុញ្ញាតការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ស្របតាមចំណុច (ច) ខាងលើ។

ជ. ដាក់ជូនរបាយការណ៍ និងព័ត៌មានពាក់ព័ន្ធជូនដល់ UNFCCC ពាក់ព័ន្ធនឹងការចូលរួមរបស់កម្ពុជានៅក្នុងវិធីសាស្ត្រសហការនៅក្រោមមាត្រា ៦ នៃកិច្ចព្រមព្រៀងទីក្រុងប៉ារីស។

## 3. ក្រុមបច្ចេកទេសអាជ្ញាធរជាតិ

ក. ពិនិត្យ វាយតម្លៃលើសំណើសុំគម្រោងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ និងរៀបចំរបាយការណ៍វាយតម្លៃបច្ចេកទេសជាមួយនឹងលទ្ធផលរកឃើញ និងអនុសាសន៍ណែនាំដើម្បីជាជំនួយដល់អ្នកសម្របសម្រួលអាជ្ញាធរជាតិនៅក្នុងការសម្រេចចិត្តអនុម័តលើសំណើសុំការអនុញ្ញាតចំពោះការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់។

ខ. សមាជិកនៃក្រុមបច្ចេកទេសអាជ្ញាធរជាតិ អាចផ្ទេរមុខងាររបស់ខ្លួនបានទៅកាន់មន្ត្រីបច្ចេកទេសជាន់ខ្ពស់នៃស្ថាប័នរបស់ខ្លួន លុះត្រាណាតែសមាជិកនោះបង្ហាញអ្នកតំណាងរបស់ខ្លួនទៅកាន់ប្រធានក្រុមបច្ចេកទេសក្នុងរយៈពេល ៥ ថ្ងៃធ្វើការ បន្ទាប់ពីទទួលបានសំណើសុំការអនុញ្ញាតចំពោះការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ដើម្បីត្រួតពិនិត្យ។

4. **លេខាធិការដ្ឋានអាជ្ញាធរជាតិ**

ក. ទទួលសំណើសុំលិខិតគាំទ្រសម្រាប់គម្រោងការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ និងសំណើសុំការអនុញ្ញាត និងការពិនិត្យវិជ្ជមាននៃគម្រោងការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ក្នុងនាមអាជ្ញាធរជាតិ និងតាមដានដំណើរការស្នើសុំនោះគ្រប់ដំណាក់កាលនៃដំណើរការពាក់ព័ន្ធទាំងអស់ ក៏ដូចជាជួយសម្រួលដល់អ្នកសម្របសម្រួលអាជ្ញាធរជាតិលើរាល់កិច្ចការរដ្ឋបាលពាក់ព័ន្ធនានា។

ខ. រៀបចំកិច្ចប្រជុំ ចែកចាយឯកសារ កត់ត្រា និងធ្វើរបាយការណ៍កិច្ចប្រជុំជូនដល់ក្រុមការងារបច្ចេកទេសអាជ្ញាធរជាតិ។

គ. គាំទ្រសកម្មភាពតាមដាន និងវាយតម្លៃរបស់អាជ្ញាធរជាតិ ដែលរួមបញ្ចូលការស្នើឱ្យម្ចាស់គម្រោងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ផ្តល់ព័ត៌មានបន្ថែម ឬផ្តល់លទ្ធភាពពេញលេញក្នុងការចុះពិនិត្យទីតាំងអភិវឌ្ឍន៍គម្រោង ក្នុងករណីចាំបាច់។

ឃ. ជ្រើសរើសអ្នកជំនាញបច្ចេកទេសជាតិ ឬអន្តរជាតិ នៅពេលមានការស្នើសុំពីអ្នកសម្របសម្រួលអាជ្ញាធរជាតិ។

ង. គាំទ្រដល់ការគ្រប់គ្រងព័ត៌មាននៃបញ្ជីការជាតិអំពី ការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ រួមទាំងការចុះបញ្ជីសំណើគម្រោងការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ថ្មីៗ និងសកម្មភាពនានាពាក់ព័ន្ធនឹងការអនុញ្ញាត និងការផ្ទេរការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់។

ច. រៀបចំរបាយការណ៍ និងព័ត៌មានពាក់ព័ន្ធជូន UNFCCC ទាក់ទងទៅនឹងការចូលរួមរបស់កម្ពុជានៅក្នុងវិធីសាស្ត្រសហការនៅក្រោមមាត្រា ៦ នៃកិច្ចព្រមព្រៀងទីក្រុងប៉ារីស។

## កម្មសិទ្ធិលើការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ដែលបានអនុញ្ញាតសម្រាប់ការផ្ទេរអន្តរជាតិនៅក្រោមមាត្រា ៦

រាជរដ្ឋាភិបាលកម្ពុជា មានសិទ្ធិអធិបតេយ្យចំពោះធនធានកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ដែលអាចសម្រេចបាននៅក្នុងប្រទេសកម្ពុជា។ ដោយផ្អែកលើការប្តេជ្ញាចិត្តរបស់កម្ពុជានៅក្នុងការលើកកម្ពស់កិច្ចខិតខំប្រឹងប្រែងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ បញ្ញត្តិខាងក្រោមពាក់ព័ន្ធនឹងកម្មសិទ្ធិលើការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ដែលត្រូវស្នើសុំការអនុញ្ញាតសម្រាប់ការផ្ទេរអន្តរជាតិក្រោមមាត្រា ៦ នឹងត្រូវអនុវត្តៈ

១. កម្ពុជា ត្រូវប្រគល់កម្មសិទ្ធិលើឯកតាកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ដែលនឹងត្រូវបង្កើតឡើងពីធនធានកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ទៅកាន់ម្ចាស់គម្រោងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ដែលបានអនុញ្ញាត ដោយផ្តល់សិទ្ធិលើធនធានទាំងនោះលើឯកតាកាត់បន្ថយការបញ្ចេញឧស្ម័ន

ផ្ទះកញ្ចក់ ដែលបានអនុញ្ញាត ដែលបង្កើតឡើងពីគម្រោងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ពាក់ព័ន្ធ និងសិទ្ធិលើផលបានមកពីការលក់ និងការផ្ទេរកម្មសិទ្ធិនាពេលអនាគតនៃឯកតាកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ដែលបានអនុញ្ញាតទៅកាន់អង្គភាពផ្សេងទៀតដូចខាងក្រោម៖

ក. ចំពោះគម្រោងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ដែលបានទទួលលិខិតអនុញ្ញាតពីរាជរដ្ឋាភិបាលកម្ពុជា កម្មសិទ្ធិត្រូវផ្ទេរទៅកាន់ម្ចាស់គម្រោងដែលបានអនុញ្ញាត នៅពេលចេញបរិមាណកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ស្របតាមការបែងចែកដែលបានព្រមព្រៀងគ្នានៃឯកតាកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ដែលបានបញ្ជាក់នៅក្នុងលិខិតអនុញ្ញាត។

ខ. ក្នុងករណីដែលរាជរដ្ឋាភិបាលកម្ពុជា មិនមែនជាអ្នកចូលរួមគម្រោង ប៉ុន្តែមានការចែងយ៉ាងច្បាស់លាស់ថា រដ្ឋាភិបាលដើរតួនាទីដឹកនាំពាក់ព័ន្ធនឹងកាអនុម័តលើគោលនយោបាយ ឬក្របខ័ណ្ឌច្បាប់អំណោយផលចាំបាច់សម្រាប់ការបង្កើតឯកតាកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ប្រកបដោយជោគជ័យនៃគម្រោង នោះរាជរដ្ឋាភិបាលកម្ពុជា អាចទាមទារកម្មសិទ្ធិរហូតដល់កម្រិតអតិបរិមា ១០% នៃឯកតាកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ទាំងនោះ។

២. ផលទាំងអស់ដែលបានមកពីការលក់ឯកតាកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ដែលបានអនុញ្ញាតស្របតាមចំណែកដែលជាកម្មសិទ្ធិរបស់រាជរដ្ឋាភិបាលកម្ពុជា ត្រូវតែបែងចែកទៅកាន់មូលនិធិបរិស្ថាននិងសង្គម។

៣. កម្មសិទ្ធិលើឯកតាកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ដែលបានផ្ទេរទៅកាន់ម្ចាស់គម្រោងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ស្របតាមចំណុច (១) ខាងលើអាចលុបចោលវិញបានក្នុងករណីមិនអនុលោមតាមបញ្ញត្តិពាក់ព័ន្ធនៃវិធានប្រតិបត្តិសម្រាប់មាត្រា ៦។

## ថ្លៃសេវាលើគម្រោងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់

ចំពោះគម្រោងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ដែលព្យាយាមបង្កើតការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ដែលអនុញ្ញាតស្របតាមមាត្រា ៦ នឹងត្រូវបង់ថ្លៃសេវារដ្ឋបាល ដើម្បីរ៉ាប់រងលើថ្លៃចំណាយពាក់ព័ន្ធនឹងមុខងារដំណើរការរបស់លេខាធិការដ្ឋានអាជ្ញាធរជាតិ និងការទូទាត់ជូនអ្នកជំនាញ។ ថ្លៃសេវារដ្ឋបាល ត្រូវតែបង់នៅមុនពេលចេញលិខិតអនុញ្ញាតជូន។

ចំពោះគម្រោងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ពាក់ព័ន្ធនឹងរេដបូក អាចនឹងមានការគិតថ្លៃសេវាបន្ថែមដើម្បីរ៉ាប់រងលើថ្លៃចំណាយពាក់ព័ន្ធនឹងការតាមដានត្រួតពិនិត្យ និងការវាយតម្លៃគម្រោងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ពាក់ព័ន្ធនឹងរេដបូក។ ម្ចាស់គម្រោងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ត្រូវមើលបទប្បញ្ញត្តិពាក់ព័ន្ធរបស់គម្រោងរេដបូក។

ថ្លៃសេវាវិធីសាស្ត្រកែតម្រូវឱ្យត្រូវគ្នា ក៏នឹងត្រូវគិតថ្លៃផងដែរ សម្រាប់ការអនុញ្ញាតលើឯកតាកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់នីមួយៗ ដើម្បីគាំទ្រដល់រាជរដ្ឋាភិបាលក្នុងការបង្កើនកម្រិតកាត់បន្ថយ និងការបន្សាំ។ ថ្លៃសេវាវិធីសាស្ត្រកែតម្រូវឱ្យត្រូវគ្នា ត្រូវទូទាត់ជូនដល់អាជ្ញាធរជាតិនៅមុនពេលចេញលិខិតត្រួតពិនិត្យវិជ្ជមានជូន។

រចនាសម្ព័ន្ធថ្លៃសេវារដ្ឋបាល និងថ្លៃសេវាវិធីសាស្ត្រកែតម្រូវឱ្យត្រូវគ្នា នឹងត្រូវរៀបចំ និងធ្វើនិយ័តកម្មបន្ថែមទៀតតាមរយៈក្របខ័ណ្ឌច្បាប់ដោយក្រសួងបរិស្ថាន និងផ្សព្វផ្សាយជូនដល់ម្ចាស់គម្រោងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់។

## បញ្ជីការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ថ្នាក់ជាតិ

រាជរដ្ឋាភិបាលកម្ពុជា នឹងខិតខំបង្កើតបញ្ជីការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ថ្នាក់ជាតិ ដើម្បីគាំទ្រដល់ការតាមដានគម្រោងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ដែលគ្រោង ឬកំពុងអនុវត្តនៅប្រទេសកម្ពុជា និងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ដែលគម្រោងទាំងនោះបានបង្កើតឡើង។ នៅមុនពេលដាក់ឱ្យប្រតិបត្តិការនូវបញ្ជី ការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ថ្នាក់ជាតិ រាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តវិធីសាស្ត្រខាងក្រោមពាក់ព័ន្ធនឹងការចូលរួមនៅក្នុងវិធីសាស្ត្រសហការនៅក្រោមមាត្រា ៦ នៃកិច្ចព្រមព្រៀងទីក្រុងប៉ារីស៖

- ប្រើប្រាស់បញ្ជីការអន្តរជាតិ ដែលនឹងត្រូវផ្តល់ជូនដោយ UNFCCC ឬ
- ប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធបញ្ជីការ ដែលផ្តល់ជូនដោយយន្តការឥណទានកាបូន។ ប្រការនេះអាចរួមបញ្ចូលយន្តការឥណទានទ្វេភាគី ឬយន្តការឥណទានឯករាជ្យ លុះត្រាណាតែយន្តការទាំងនេះបានបង្កើតនូវនីតិវិធីដើម្បីសម្របសម្រួលដល់ការផ្តល់ព័ត៌មានទាំងអស់ ដែលរាជរដ្ឋាភិបាលកម្ពុជាបានតម្រូវដើម្បីបំពេញតាមលក្ខខណ្ឌតម្រូវរាយការណ៍នៃមាត្រា ៦។

## ដំណើរការប្តឹងជំទាស់

ម្ចាស់គម្រោងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ មានសិទ្ធិប្តឹងជំទាស់ទៅនឹងសេចក្តីសម្រេចអវិជ្ជមាន (ឧ. ការបដិសេធ សំណើសុំលិខិតគាំទ្រ សម្រាប់គម្រោងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ឬសំណើសុំលិខិតអនុញ្ញាតឬលិខិតត្រួតពិនិត្យវិជ្ជមានលើគម្រោងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់) ពីអាជ្ញាធរជាតិ។

ការជំទាស់នេះ ត្រូវតែបញ្ជូនទៅកាន់ប្រធានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព និងដាក់ជូនដោយម្ចាស់គម្រោងជូនដល់លេខាធិការដ្ឋានអាជ្ញាធរជាតិ ដោយមានសេចក្តីពន្យល់បកស្រាយអំពីមូលហេតុនៃការប្តឹងជំទាស់ និងឯកសារច្បាប់ដើម (ឬឯកសារបញ្ជាក់អំពីការចម្លងត្រឹមត្រូវតាមច្បាប់ដើម) នៅក្នុងរយៈពេលសាមសិប (៣០) ថ្ងៃធ្វើការ រាប់គិតចាប់ពីកាលបរិច្ឆេទទទួលសេចក្តីសម្រេចអវិជ្ជមានពាក់ព័ន្ធនោះ។

ប្រធានលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព នឹងវាយតម្លៃមើលថា តើសេចក្តីសម្រេចរបស់អាជ្ញាធរជាតិ បានធ្វើឡើងស្របតាមវិធានប្រតិបត្តិសម្រាប់មាត្រា ៦ ដែរឬយ៉ាងណា នៅក្នុងរយៈពេលដប់ប្រាំ

(១៥) ថ្ងៃធ្វើការគិតចាប់ពីថ្ងៃទទួលបានបណ្ដឹងជំទាស់ ព្រមទាំងប្រាប់អំពីការសម្រេចចិត្តរបស់ខ្លួនជូនដល់អ្នកសម្របសម្រួល និងលេខាធិការដ្ឋានអាជ្ញាធរជាតិផងដែរ។ អាជ្ញាធរជាតិ នឹងជូនដំណឹងភ្លាមៗដល់ម្ចាស់គម្រោងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់អំពីសេចក្ដីសម្រេចលើបណ្ដឹងជំទាស់នោះ។

ដំណើរការប្ដឹងជំទាស់ អាចនឹងត្រូវកែប្រែនៅក្នុងឯកសារណែនាំបទប្បញ្ញត្តិបន្ថែម ដែលនឹងត្រូវរៀបចំឡើងដោយក្រសួងបរិស្ថាន។

**បទប្បញ្ញត្តិ និងនីតិវិធីពាក់ព័ន្ធ**

វិធានប្រតិបត្តិសម្រាប់មាត្រា ៦ នេះ គឺអនុវត្តចំពោះគម្រោងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ទាំងអស់ដែលអនុវត្តនៅក្នុងប្រទេសកម្ពុជា និងការស្នើសុំការអនុញ្ញាតលើគម្រោងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់សម្រាប់ការផ្ទេរអន្តរជាតិនៅក្រោមមាត្រា ៦ នៃកិច្ចព្រមព្រៀងទីក្រុងប៉ារីស។

បទប្បញ្ញត្តិ និងនីតិវិធីពាក់ព័ន្ធផ្សេងៗសម្រាប់ការគ្រប់គ្រងយន្តការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ នៅប្រទេសកម្ពុជា អាចនឹងត្រូវអនុវត្ត រួមទាំងបទប្បញ្ញត្តិពាក់ព័ន្ធនឹងគម្រោងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ជាក់លាក់តាមវិស័យ (ដូចជាគម្រោង រេដបូក) ឬចំពោះគម្រោងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ដែលកំពុងអនុវត្តនៅក្រោមយន្តការឥណទានកាបូនរួមគ្នា (JCM) ដែលចំពោះគម្រោងទាំងនេះ បញ្ញត្តិពាក់ព័ន្ធនៃសៀវភៅណែនាំស្ដីពីយន្តការឥណទានកាបូនរួមគ្នា នឹងត្រូវយកមកអនុវត្ត។ ប្រសិនបើគម្រោងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់មានលក្ខណៈសម្បត្តិពាក់ព័ន្ធច្រើន នោះម្ចាស់គម្រោង ត្រូវអនុវត្តតាមការណែនាំពាក់ព័ន្ធទាំងអស់។ ឧទាហរណ៍ គម្រោងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ដែលស្នើសុំការចុះបញ្ជីនៅក្រោមយន្តការឥណទានកាបូនរួមគ្នា និងការអនុញ្ញាតនៅក្រោមមាត្រា ៦ នឹងត្រូវតម្រូវឱ្យអនុវត្តតាមលក្ខខណ្ឌតម្រូវ និងដំណើរការដែលមានចែងនៅក្នុងសៀវភៅណែនាំស្ដីពីយន្តការឥណទានកាបូនរួមគ្នា និងវិធានប្រតិបត្តិសម្រាប់មាត្រា ៦។

## ១.៤ វិធីសាស្ត្រចូលរួមក្រោមមាត្រា ៦ និងលក្ខខណ្ឌតម្រូវសម្រាប់ការចូលរួម

### វិធីសាស្ត្រតាមដំណាក់កាលចំពោះការចូលរួមក្រោមមាត្រា ៦

ក្នុងឆ្នាំ២០២១ រាជរដ្ឋាភិបាលកម្ពុជាបានចាប់ផ្ដើមរៀបចំសម្រាប់ការចូលរួមក្រោមមាត្រា ៦។ ក្នុងដំណើរការនៃការរៀបចំនេះ រាជរដ្ឋាភិបាលកម្ពុជា បានទទួលជំនួយបច្ចេកទេសពីអង្គការដៃគូនានា ដែលក្នុងនោះរួមមានវិទ្យាស្ថានអភិវឌ្ឍន៍បៃតងសកល (GGGI)។ ការរៀបចំទាំងនេះ បានឈានទៅដល់ការរៀបចំបង្កើតនូវប៉ារ៉ាម៉ែត្រជាយុទ្ធសាស្ត្រមួយចំនួន សម្រាប់ជាការណែនាំអំពីការចូលរួមក្រោមមាត្រា ៦ របស់កម្ពុជា ដោយធានានូវភាពស្របគ្នាជាមួយនឹងការប្រែប្រួលអាកាសធាតុ និងចំណុចអាទិភាពនៃការអភិវឌ្ឍប្រកបដោយចីរភាព ព្រមទាំងការកាត់បន្ថយនូវហានិភ័យនៃការលក់ GHG ER ជាអន្តរជាតិលើសកម្រិតផងដែរ។

កម្ពុជា បានអនុម័តវិធីសាស្ត្រតាមដំណាក់កាលសម្រាប់ការចូលរួមក្រោមមាត្រា ៦ (សូមមើលរូបភាព ២)។ បារ៉ាម៉ែត្រ យុទ្ធសាស្ត្រទាំងនេះ អាចអនុវត្តក្នុងដំណាក់កាលទីមួយ ដែលអាចជួយកម្ពុជាឱ្យក្លាយជាប្រទេសនាំមុខ ហើយអាចគ្រប់គ្រងហានិភ័យនៃការចូលរួមបាន៖

- **ដំណាក់កាលទី ១៖ ការចូលរួមអនុវត្តក្រោមមាត្រា ៦ ជាការសាកល្បង៖**
  វិធានប្រតិបត្តិមាត្រា ៦ នេះ បង្កើតនូវលក្ខណៈវិនិច្ឆ័យដើម្បីធៀបនឹងសំណើសុំការអនុញ្ញាតក្រោម មាត្រា ៦ ដែលត្រូវវាយតម្លៃរហូតដល់ខែធ្នូ ឆ្នាំ២០២៥។ រយៈពេលមានកម្រិតនេះ បានកំណត់ដើម្បីកាត់បន្ថយចំនួនគម្រោង GHG ER ដែលបានទទួលការអនុញ្ញាតក្រោមមាត្រា ៦ ខណៈដែលរាជរដ្ឋាភិបាលកម្ពុជាបានបង្កើនការយល់ដឹងកាន់តែច្បាស់អំពីក្របខ័ណ្ឌអភិបាលកិច្ចដែលបានបង្កើតឡើងថ្មីនេះ ប្រព័ន្ធតាមដានថ្នាក់ជាតិ និងលក្ខខណ្ឌតម្រូវរាយការណ៍ជូន UNFCCC ដែលពាក់ព័ន្ធ។ វិធីសាស្ត្រនេះ ក៏អនុញ្ញាតឱ្យប្រទេសកម្ពុជា អាចវាយតម្លៃអំពីឥទ្ធិពលនៃការចូលរួមក្នុងមាត្រា ៦ ទៅលើការសម្រេចបានតាមគោលដៅកាត់បន្ថយការបញ្ចេញឧស្ម័នថ្នាក់ជាតិ និងបង្កើនមហិច្ឆតាកាត់បន្ថយការប្រែប្រួលអាកាសធាតុ។
- **ដំណាក់កាលទី ២៖ ការពង្រីកវិសាលភាពការចូលរួមក្រោមមាត្រា ៦៖**
  បទពិសោធន៍ពីដំណាក់កាលទី១ នឹងផ្តល់នូវព័ត៌មានសម្រាប់ការពិនិត្យមើលលើលក្ខណៈវិនិច្ឆ័យ អនុញ្ញាត ដែលថា ប្រសិនបើចាំបាច់ ត្រូវធ្វើបច្ចុប្បន្នភាពនៅក្នុងដំណាក់កាលកែសម្រួលវិធានប្រតិបត្តិ សម្រាប់ មាត្រា ៦ លើកក្រោយក្នុងឆ្នាំ២០២៥។ ដំណើរការពិនិត្យឡើងវិញនេះ ក៏ធ្វើឡើងដោយមានភាពស្របគ្នាជាមួយនឹងដំណើរការ Updated NDC របស់ប្រទេសកម្ពុជាសម្រាប់រយៈពេលពីឆ្នាំ ២០២៦ ដល់ឆ្នាំ ២០៣៥ ផងដែរ។

*រូបភាព ២៖ យុទ្ធសាស្ត្រចូលរួមក្រោមមាត្រា ៦ របស់ប្រទេសកម្ពុជា*



## លក្ខខណ្ឌតម្រូវសម្រាប់ការចូលរួមក្រោមមាត្រា ៦

ក្នុងនាមជាភាគីនៃកិច្ចព្រមព្រៀងទីក្រុងប៉ារីស ប្រទេសកម្ពុជាធានាថា ការចូលរួមរបស់ខ្លួនតាមវិធីសាស្រ្តសហការ និងការអនុញ្ញាត ការផ្ទេរ និងការប្រើប្រាស់ ITMOs គឺមានសង្គតិភាពស្របទៅនឹងវិធានប្រតិបត្តិមាត្រា ៦.២ និង សេចក្តីសម្រេចកិច្ចប្រជុំភាគីដែលជាកិច្ចប្រជុំភាគីនៃកិច្ចព្រមព្រៀងទីក្រុងប៉ារីស (CMA) ពាក់ព័ន្ធផ្សេងៗ។[10] ការចូលរួមរបស់ប្រទេសកម្ពុជា គឺមានសង្គតិភាពស្របទៅតាមលក្ខខណ្ឌតម្រូវសម្រាប់ការចូលរួមដែលមានចែងនៅក្នុងវិធានប្រតិបត្តិមាត្រា ៦.២៖

- ប្រទេសកម្ពុជាបានធ្វើសច្ចាប័ន្ធកិច្ចព្រមព្រៀងទីក្រុងប៉ារីសនៅក្នុងខែកុម្ភៈ ឆ្នាំ២០១៧។[11]
- ផែនការ Updated NDC របស់ប្រទេសកម្ពុជា ត្រូវបានដាក់ជូន UNFCCC នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០២០។[12]
    - គោលដៅកាត់បន្ថយការបញ្ចេញឧស្ម័នទាំងអស់ គឺត្រូវលើកឡើងជាឯកតា $tCO_2eq$ ដោយប្រើប្រាស់តម្លៃសក្តានុពលកម្តៅសកល (GWP) ដែលបានដកស្រង់ចេញពីរបាយការណ៍វាយតម្លៃលើកទីបួនរបស់ក្រុមការងារអន្តររដ្ឋាភិបាលស្តីពីការប្រែប្រួលអាកាសធាតុ (IPCC)។
    - គោលដៅកាត់បន្ថយការបញ្ចេញឧស្ម័ននេះ ត្រូវបានកំណត់ធៀបនឹងសេណារីយ៉ូបន្ទាត់មូលដ្ឋានការព្យាករណ៍តាមទម្លាប់ធម្មតាក្នុងឆ្នាំ២០៣០។
    - វិធីសាស្រ្តកម្រិតទី ១ បានចែងនៅក្នុងគោលការណ៍ណែនាំ IPCC ឆ្នាំ២០០៦ ហើយកត្តាបញ្ចេញឧស្ម័នដែលបានកំណត់ដោយ IPCC និងទិន្នន័យសកម្មភាពជាក់លាក់តាមប្រទេសពីឆ្នាំ ១៩៩៤ ទៅឆ្នាំ ២០១៦ ត្រូវបានប្រើប្រាស់សម្រាប់ការវាយតម្លៃការព្យាករតាមទម្លាប់ធម្មតា។
    - វិស័យចំនួនប្រាំពីរដែលត្រូវគ្របដណ្តប់៖ ថាមពល សំណល់ ឧស្សាហកម្ម ការដឹកជញ្ជូន កសិកម្ម អគារ និងព្រៃឈើ និងការប្រើប្រាស់ដីផ្សេងៗ (FOLU)។
    - រយៈពេលអនុវត្ត NDC គឺពីឆ្នាំ ២០២១ ទៅឆ្នាំ ២០៣០។
    - ប្រទេសកម្ពុជា ក៏បានបង្កើតនូវឧបករណ៍តាមដាន NDC តាមអនឡាញ ដែលបានធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំផងដែរ។[13]
- ប្រទេសកម្ពុជាមានការរៀបចំក្របខ័ណ្ឌសម្រាប់ការអនុញ្ញាតឱ្យប្រើប្រាស់ ITMOs ដើម្បីសម្រេចគោលដៅ NDC។ ការរៀបចំក្របខ័ណ្ឌនេះ គឺត្រូវបានបង្កើតឡើងស្របតាមបទប្បញ្ញត្តិ និងនីតិវិធីដូចខាងក្រោម៖

[10] GHG ER (ដែលមានការអនុញ្ញាត) សំដៅដល់ក្នុងឯកសារនេះត្រូវនឹងពាក្យ 'លទ្ធផលនៃការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ដែលផ្ទេរជាអន្តរជាតិ' (ITMOs) ដែលប្រើក្នុងបរិបទនៃកិច្ចព្រមព្រៀងប៉ារីស។

[11] https://treaties.un.org/Pages/ViewDetails.aspx?src=TREATY&mtdsg_no=XXVII-៧-d&chapter=២៧&clang=_en

[12] https://unfccc.int/sites/default/files/NDC/២០២២-០៦/២០២០១២៣១_NDC_Updated_Cambodia.pdf

[13] https://ncsd.moe.gov.kh/ndc-tracking/

- ○ អនុក្រឹត្យស្តីពីការគ្រប់គ្រងយន្តការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់។
- ○ ប្រកាសស្តីពីវិធាន និងនីតិវិធីយន្តការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់។
- ○ វិធានប្រតិបត្តិសម្រាប់មាត្រា ៦។

- ប្រទេសកម្ពុជា បានរៀបចំយន្តការសម្រាប់ការតាមដាន ITMOs។ រាជរដ្ឋាភិបាលកម្ពុជា បានប្រើប្រាស់បញ្ជី GHG ER ថ្នាក់ជាតិ សម្រាប់ការតាមដាន ITMOs និងគាំទ្រការដាក់ឯកសារព័ត៌មានពាក់ព័ន្ធជូនដល់ UNFCCC។ គោលការណ៍ណែនាំស្តីពីបញ្ជី GHG ER ជាតិ រៀបរាប់យ៉ាងលម្អិតអំពីដំណើរការសម្រាប់ការគ្រប់គ្រងព័ត៌មាននៅក្នុងបញ្ជី GHG ER ជាតិនោះ។
- ប្រទេសកម្ពុជាបានផ្តល់នូវរបាយការណ៍សារពើភណ្ឌឧស្ម័នផ្ទះកញ្ចក់ជាតិ ដែលបានធ្វើបច្ចុប្បន្នភាពថ្មីចុងក្រោយជូនដល់ UNFCCC នៅក្នុងខែកញ្ញា ឆ្នាំ២០២២ នេះ។[14]
- ការចូលរួមរបស់ប្រទេសកម្ពុជាក្រោមវិធីសាស្ត្រសហការនេះ ជាការរួមចំណែកដល់ការអនុវត្ត NDC និង LTS4CN ព្រមទាំងគោលដៅរយៈពេលវែងរបស់កិច្ចព្រមព្រៀងទីក្រុងប៉ារីសផងដែរ។
  - ○ ដើម្បីធានាថាការចូលរួមក្រោមវិធីសាស្ត្រសហការសម្រាប់មាត្រា ៦ អាចរួមចំណែកដល់ការអនុវត្ត NDC របស់ប្រទេសកម្ពុជាបាន រាជរដ្ឋាភិបាលកម្ពុជា នឹងអនុញ្ញាតឱ្យតែសកម្មភាពនានាដែលមាននៅក្នុង "បញ្ជីវិជ្ជមាន" របស់ប្រទេសប៉ុណ្ណោះ ឧទាហរណ៍ សកម្មភាពដែលនៅក្នុងផែនការបច្ចុប្បន្នភាព NDC ដែលបានកំណត់ថាមានលក្ខខណ្ឌនៅពេលមានការគាំទ្រអន្តរជាតិ (សូមមើលជំពូកទី ២)។
  - ○ ផែនការហិរញ្ញវត្ថុសម្រាប់ LTS4CN បានកំណត់អំពីតម្រូវការការគាំទ្រផ្នែកហិរញ្ញវត្ថុអន្តរជាតិ។ វិធីសាស្ត្រសហការក្រោមមាត្រា ៦ គឺត្រូវបានរំពឹងថានឹងដើរតួនាទីដ៏សំខាន់ក្នុងការផ្តល់នូវហិរញ្ញវត្ថុមួយចំនួន ដែលចាំបាច់សម្រាប់ការអនុវត្ត LTS4CN។

## មហិច្ឆតានៅក្នុងការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ និងសកម្មភាពបន្សុំ

វិធានប្រតិបត្តិមាត្រា ៦.២ ផ្តល់ការលើកទឹកចិត្តយ៉ាងខ្លាំងទៅដល់ភាគី ដើម្បីប្តេជ្ញាចិត្តក្នុងការវិភាគទានធនធានមួយចំនួនសម្រាប់សកម្មភាពបន្សាំ។[15] អាជ្ញាធរជាតិនឹងធ្វើការពិភាក្សាជាមួយនឹងអង្គភាពភាគីទិញ (និង/ឬភាគីដែលជាអង្គភាពទិញ) អំពីចំណែកប្រាក់ចំណេញ (SOP) ដែលនឹងត្រូវទទួលយកនៅពេលធ្វើការផ្ទេរ GHG ER ដែលបានអនុញ្ញាត និងរក្សាទុកសម្រាប់ជាការរួមចំណែកដល់ការសម្របខ្លួននៅក្នុងប្រទេសកម្ពុជា។ កិច្ចពិភាក្សានេះ ក៏អាចនឹងត្រូវពិចារណាអំពីសហអត្ថប្រយោជន៍នៃការបន្សុំពាក់ព័ន្ធនឹងគម្រោង GHG ER ផងដែរ។

វិធានប្រតិបត្តិមាត្រា ៦.២ ក៏បានលើកទឹកចិត្តឱ្យភាគី លុបចោលនូវ GHG ER ដែលបានអនុញ្ញាត ដើម្បីកុំឱ្យមានការរាប់ GHG ER ចូលទៅក្នុង NDC របស់ប្រទេស ឬសម្រាប់គោលបំណងកាត់បន្ថយការបញ្ចេញឧស្ម័នជាអន្តរជាតិ

[14] https://unfccc.int/sites/default/files/resource/២០២២០៩២១_Third%២០National%២០Communication_Cambodia.pdf

[15] UNFCCC សេចក្តីសម្រេច ២/CMA.៣, ឧបសម្ព័ន្ធ, កថាខណ្ឌ ៣៧។

ផ្សេងៗ ដើម្បីសម្រេចបាននូវការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ជារួមនៅក្នុងការបញ្ចេញឧស្ម័នសកល (OMGE)។ [16] អាជ្ញាធរជាតិនឹងធ្វើការពិភាក្សាជាមួយនឹងអង្គភាពទិញ (និង/ឬភាគីដែលអង្គភាពទិញ) អំពីចំណែក GHG ER ដែលបានអនុញ្ញាត ដែលអាចនឹងត្រូវលុបចោល ដើម្បីជួយដល់ការសម្រេចបាននូវ OMGE។

## ២. លក្ខណៈវិនិច្ឆ័យសិទ្ធិនៃគម្រោងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ដើម្បីទទួលបានការអនុញ្ញាតក្រោមមាត្រា ៦

ជំពូកនេះ រៀបរាប់លម្អិតអំពីលក្ខណៈវិនិច្ឆ័យសិទ្ធិមួយចំនួនដែលគម្រោង GHG ER ត្រូវតែបំពេញតាម ដើម្បីទទួលបានការអនុញ្ញាតស្របតាមមាត្រា ៦។ អាជ្ញាធរជាតិនឹងផ្តល់ការអនុញ្ញាតក្រោមមាត្រា ៦ សម្រាប់ GHG ER ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យទាំងនេះ។

### ២.១. លក្ខខណ្ឌវិនិច្ឆ័យដើម្បីទទួលការអនុញ្ញាតសម្រាប់គម្រោង GHG ER

ផ្នែកនេះ រៀបរាប់អំពីលក្ខណៈវិនិច្ឆ័យដែលប្រើប្រាស់ដើម្បីកំណត់ថាតើ GHG ER ដែលបង្កើតចេញពីគម្រោងដែលត្រូវអនុវត្តក្នុងប្រទេសកម្ពុជានេះ គឺមានលក្ខណៈសម្បត្តិទទួលសិទ្ធិស្របតាមការអនុញ្ញាតក្រោមមាត្រា ៦ ដែរឬទេ។ លក្ខណៈវិនិច្ឆ័យដើម្បីទទួលបានការអនុញ្ញាត នេះត្រូវបានបង្កើតឡើង ដើម្បីធានាថាគម្រោង GHG ER នីមួយៗ មានលក្ខណៈសមស្របទៅតាមចំណុចអាទិភាពគោលនយោបាយថ្នាក់ជាតិ និងលក្ខខណ្ឌតម្រូវមាត្រា ៦។ លក្ខណៈវិនិច្ឆ័យដើម្បីទទួលបានការអនុញ្ញាត ក៏មានគោលបំណងកាត់បន្ថយហានិភ័យដែលថាការអនុញ្ញាត GHG ER លើសកម្រិត អាចនឹងប៉ះពាល់ដល់ការសម្រេចបាននូវគោលដៅ NDC បច្ចុប្បន្ន និង/ឬអនាគតរបស់ប្រទេសកម្ពុជា។

**ម្ចាស់គម្រោងទាំងអស់ដែលស្នើសុំការអនុញ្ញាត GHG ER ដែលបង្កើតចេញពីគម្រោង ចាំបាច់ត្រូវបំពេញតាមលក្ខណៈវិនិច្ឆ័យដែលមានរៀបរាប់នៅក្នុងតារាង ១។** ព័ត៌មានបន្ថែមអំពីលក្ខណៈវិនិច្ឆ័យនេះ មានផ្តល់ជូននៅផ្នែកខាងក្រោម។

*តារាង ១៖ លក្ខណៈវិនិច្ឆ័យដើម្បីទទួលបានការអនុញ្ញាតក្រោមមាត្រា ៦ នៃគម្រោង GHG ER ក្នុងប្រទេសកម្ពុជា*

| | |
|---|---|
|  | ១. គម្រោង GHG ER មាននៅក្នុង "បញ្ជីវិជ្ជមាន" |
|  | ២. ចំណែកនៃ GHG ER ត្រូវរក្សាទុកសម្រាប់ការប្រើប្រាស់ក្នុងប្រទេស |

[16] UNFCCC សេចក្តីសម្រេច ២/CMA.៣, ឧបសម្ព័ន្ធ, កថាខណ្ឌ ៣៩។

| | |
|---|---|
| | ៣. រយៈពេលអនុញ្ញាតត្រូវស្របតាមរយៈពេលឥណទាននៃមាត្រា ៦.៤ |
| | ៤. GHG ER ដែលបានអនុញ្ញាត ត្រូវចេញដោយយន្តការកាបូនដែលមានសិទ្ធិទទួលបាន |
| | ៥. GHG ER គឺពិតប្រាកដ បានផ្ទៀងផ្ទាត់ និងបន្ថែម |
| | ៦. GHG ER ត្រូវបានបង្កើតចាប់ពីឆ្នាំ២០២១ តទៅ |
| | ៧. គម្រោង GHG ER ធានានូវសុចរិតភាពបរិស្ថានដោយៈ<br>i. ការកំណត់បន្ទាត់មូលដ្ឋានបែបប៉ាន់ស្មាន និងការព្យាករណ៍ការបញ្ចេញឧស្ម័ន តាមរយៈ "ការព្យាករណ៍តាមទម្លាប់ធម្មតា"<br>ii. ការកាត់បន្ថយហានិភ័យនៃការមិនបំពេញកាតព្វកិច្ចកាត់បន្ថយ ការបញ្ចេញឧស្ម័ន |
| | ៨. គម្រោង GHG ER ស្របតាមចំណុចអាទិភាពអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់ប្រទេសកម្ពុជា។ |

## ១. គម្រោង GHG ER មាននៅក្នុង "បញ្ជីវិជ្ជមាន"

- មានតែ GHG ER ពីគម្រោងដែលមាននៅក្នុង "បញ្ជីវិជ្ជមាន" នៃសកម្មភាពកាត់បន្ថយការបញ្ចេញឧស្ម័នរបស់ប្រទេសកម្ពុជាប៉ុណ្ណោះ ដែលមានសិទ្ធិទទួលបានការអនុញ្ញាតស្របតាមមាត្រា ៦។
- បញ្ជីវិជ្ជមាន មានរៀបរាប់អំពីសកម្មភាពទាំងអស់ដែលចាត់ទុកថាជាសកម្មភាព "មានលក្ខខណ្ឌ" នៅក្នុង ផែនការ Updated NDC របស់រាជរដ្ឋាភិបាលកម្ពុជា។[17]

## ២. ចំណែកនៃ GHG ER ត្រូវរក្សាទុកសម្រាប់ការប្រើប្រាស់ក្នុងប្រទេស

- ចំណែក GHG ER ដែលបានបង្កើតពីគម្រោង ត្រូវតែរក្សាទុកសម្រាប់ការប្រើប្រាស់ក្នុងប្រទេស (ឧ. GHG ER នេះមិនត្រូវបានផ្តល់ការអនុញ្ញាត និងផ្ទេរជាអន្តរជាតិនោះទេ)។ ហេតុផលនេះ គឺដើម្បីធានាថាចំណែក GHG ER ដែលបង្កើតចេញពីគម្រោងដែលបានអនុវត្តនៅកម្ពុជា ត្រូវរាប់ចូលទៅក្នុងគោលដៅ NDC របស់ប្រទេសកម្ពុជា។

[17] https://unfccc.int/sites/default/files/NDC/២០២២-០៦/២០២០១២៣១_NDC_Updated_Cambodia.pdf

## ៣. រយៈពេលអនុញ្ញាតត្រូវស្របតាមរយៈពេលឥណទាននៃមាត្រា ៦.៤

- រយៈពេលដែល GHG ER ទទួលបានការអនុញ្ញាត អាចផ្ទេរជាលក្ខណៈអន្តរជាតិបាន (ឧ. រយៈពេលអនុញ្ញាត) មិនត្រូវលើសពីរយៈពេលឥណទានអតិបរមាដែលមានចែងនៅក្នុងវិធានប្រតិបត្តិមាត្រា ៦.៤ នោះទេ។[18]
- ការអនុញ្ញាត អាចនឹងត្រូវផ្តល់ជូនសម្រាប់រយៈពេលអតិបរមាគឺ៖
    - ៥ ឆ្នាំ ដោយអាចបន្តបានពីរដង ហើយរយៈពេលសរុបគឺ ១៥ ឆ្នាំ ឬ
    - ១០ ឆ្នាំ ដោយមិនមានការបន្តបាននោះទេ ឬ
    - ១៥ ឆ្នាំ ដោយអាចបន្តបានពីរដង ហើយរយៈពេលសរុបគឺ ៤៥ ឆ្នាំ (អនុវត្តចំពោះគម្រោង GHG ER ដែលពាក់ព័ន្ធនឹងការដកចេញប៉ុណ្ណោះ)។[19]

## ៤. GHG ER ដែលបានអនុញ្ញាត ត្រូវចេញដោយយន្តការកាបូនដែលមានសិទ្ធិទទួលបាន

- GHG ER ដែលបានអនុញ្ញាតដោយរាជរដ្ឋាភិបាល ត្រូវតែចេញដោយយន្តការកាបូនដែលមានសិទ្ធិអនុញ្ញាត
- ប្រភេទយន្តការកាបូនខាងក្រោមនេះ គឺមានលក្ខណៈសមស្របសម្រាប់ការចេញសិទ្ធិ GHG ER សម្រាប់គម្រោងដែលបានអនុវត្តនៅកម្ពុជា៖
    - **យន្តការកាបូនទ្វេភាគី**
        - យន្តការទ្វេភាគី គឺជាយន្តការដែលបានបង្កើតឡើងតាមរយៈកិច្ចព្រមព្រៀងរវាងប្រទេសកម្ពុជា និងភាគីមួយផ្សេងទៀតនៃកិច្ចព្រមព្រៀងទីក្រុងប៉ារីស។[20]
    - **យន្តការកាបូនឯករាជ្យ**
        - យន្តការកាបូនឯករាជ្យ គឺមិនស្ថិតក្រោមការគ្រប់គ្រងដោយបទប្បញ្ញត្តិ ឬសន្ធិសញ្ញាអន្តរជាតិនោះទេ។ យន្តការនេះ ស្ថិតក្រោមការត្រួតពិនិត្យដោយស្ថាប័នភាគីទីបីឯករាជ្យ។[21]
    - **យន្តការមាត្រា ៦.៤**
        - យន្តការមាត្រា ៦.៤ គឺជាយន្តការអន្តរជាតិដែលបានបង្កើតឡើងស្របតាមមាត្រា ៦.៤ នៃកិច្ចព្រមព្រៀងទីក្រុងប៉ារីសស្តីពីការប្រែប្រួលអាកាសធាតុ។[22]

---

[18] UNFCCC សេចក្តីសម្រេច ៣/CMA.៣, ឧបសម្ព័ន្ធ, កថាខណ្ឌ ៣១(ច)។

[19] ការដក GHG ER ក៏មាននូវដំណោះស្រាយផ្អែកលើលក្ខណៈ និងបច្ចេកវិទ្យា។ ការដកដោយផ្អែកលើលក្ខណៈ អាចរួមមានសកម្មភាពការដាំដើមឈើឡើងវិញ ការស្រូបទុកកាបូនក្នុងដី និងការស្តារដីសើម។

[20] ឧទាហរណ៍អំពីយន្តការផ្តល់ឥណទានទ្វេភាគី គឺជាយន្តការឥណទានកាបូនរួមគ្នា (JCM) ដែលបានបង្កើតឡើងរវាងប្រទេសជប៉ុន ជាមួយនឹងប្រទេសដៃគូផ្សេងៗ។

[21] ឧទាហរណ៍នៃយន្តការឥណទានកាបូនឯករាជ្យ គឺរួមមាន Gold Standard និងស្តង់ដារកាបូនស្ម័គ្រចិត្ត (VCS)។

[22] យន្តការមាត្រា ៦.៤ គឺមិនរំពឹងថានឹងអាចអនុវត្តបាននៅចុងឆ្នាំ ២០២៤ នេះនោះទេ។

យន្តការកាបូនសម្រាប់បញ្ចេញ GHG ER ដែលបង្កើតចេញពីគម្រោងដែលបានអនុវត្តនៅកម្ពុជា ត្រូវតែមានលក្ខណៈ ដូចខាងក្រោម៖[23]

- យន្តការកាបូន ត្រូវតែបង្កើតឯកតាដែលតំណាងឱ្យការកាត់បន្ថយការបញ្ចេញឧស្ម័ន ឬដកចេញនូវការបញ្ចេញឧស្ម័នដែលលើស។[24]
- ឯកតា GHG ER ត្រូវតែអាចកំណត់ជាចំនួន តាមដាន រាយការណ៍ និងផ្ទៀងផ្ទាត់បាន។
- ឯកតា GHG ER ត្រូវតែមានដំណើរប្រកបដោយភាពច្បាស់លាស់ និងតម្លាភាពនៅក្នុងយន្តការកាបូន (ឧ. GHG ER ដែលបានអនុញ្ញាតនីមួយៗ ត្រូវកំណត់លេខសម្គាល់ជាក់លាក់ ដែលអាចតាមដានបាននៅពេលឯកតាត្រូវបានចេញតាមរយៈការផ្ទេរ និង/ឬការលុបចោល។
- ឯកតា GHG ER ត្រូវតែបង្ហាញអំពីការកាត់បន្ថយ ឬការដកការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ដែលមានលក្ខណៈអចិន្ត្រៃយ៍។
- យន្តការកាបូន ត្រូវតែជាយន្តការដែលមានដំណោះ និងអាចសម្រាលឧប្បត្តិហេតុដែលអាចកើតឡើង។
- GHG ER អាចរាប់បានសម្រាប់តែកាតព្វកិច្ចកាត់បន្ថយការបញ្ចេញឧស្ម័នប៉ុណ្ណោះ (ឧ. យន្តការកាបូនមានយន្តការក្នុងការបញ្ចៀសការចេញទ្វេដង ការប្រើប្រាស់ទ្វេដង និងការអះអាងទ្វេដង)។
- ឯកតា GHG ER ត្រូវតែបង្ហាញអំពីការកាត់បន្ថយ ឬការដកការបញ្ចេញឧស្ម័នពីគម្រោងដោយមិនបង្កគ្រោះថ្នាក់។

## ៥. GHG ER **គឺពិតប្រាកដ ដែលផ្ទៀងផ្ទាត់ និងបន្ថែមបាន**

- វិធានប្រតិបត្តិមាត្រា ៦.២ ចែងថា GHG ER ដែលបានអនុញ្ញាតពីវិធីសាស្ត្រសហការ គឺត្រូវតែមានលក្ខណៈពិតប្រាកដ ដែលផ្ទៀងផ្ទាត់ និងបន្ថែមបាន។[25]
    - ការប្រើប្រាស់យន្តការកាបូនដែលមានលក្ខណៈសិទ្ធិគ្រប់គ្រាន់ក្នុងការចេញឯកតា GHG ER និងការប្រើប្រាស់បន្ទាត់មូលដ្ឋានធម្មតា ធានាថា GHG ER ពីវិធីសាស្ត្រសហការក្រោមមាត្រា ៦.២ ដែលប្រទេសកម្ពុជាជាភាគី គឺពិតជាបង្ហាញអំពីការកាត់បន្ថយ ឬការដកការបញ្ចេញឧស្ម័នពិតប្រាកដមែន។
    - GHG ER ទាំងអស់ដែលបានពីវិធីសាស្ត្រសហការនៃមាត្រា ៦.២ ដែលប្រទេសកម្ពុជាជាភាគី គឺត្រូវតែបានផ្ទៀងផ្ទាត់ដោយឯករាជ្យ ស្របតាមនីតិវិធីនៃយន្តការកាបូន ដែលគម្រោង GHG ER បានចុះបញ្ជី។

---

[23] ដកស្រង់ចេញពី CORSIA Emissions Unit Eligibility Criteria (ខែមីនា ឆ្នាំ២០១៩)។ អាចរកបាននៅ https://www.icao.int/environmental-protection/CORSIA/Documents/ICAO_Document_09.pdf.

[24] មានន័យថា GHG ER ត្រូវតែបង្កើតចេញពីគម្រោងដែលមិនទាន់បានអនុវត្តនៅពេលមិនមានវិធីសាស្ត្រសហការ។

[25] UNFCCC សេចក្តីសម្រេច ២/CMA.៣, ឧបសម្ព័ន្ធ កថាខណ្ឌ ១ (ក)។

- GHG ER ពីវិធីសាស្ត្រសហការក្រោមមាត្រា ៦.២ ដែលប្រទេសកម្ពុជាជាភាគីត្រូវតែមានលក្ខណៈបន្ថែម។ លក្ខណៈបន្ថែមនៃ GHG ER នេះ គឺត្រូវជានាស្របតាមលក្ខណៈដូចខាងក្រោម៖
  - រាជរដ្ឋាភិបាលកម្ពុជា នឹងផ្តល់លិខិតអនុញ្ញាត GHG ER ដែលបង្កើតចេញពីសកម្មភាពនានាដែលមាននៅក្នុង "បញ្ជីវិជ្ជមាន" នៃសកម្មភាពកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ប៉ុណ្ណោះ។ បញ្ជីនេះ រៀបរាប់អំពីសកម្មភាពដែលបានកំណត់ថា "មានលក្ខខណ្ឌ" នៅក្នុង NDC បច្ចុប្បន្នភាពរបស់រាជរដ្ឋាភិបាលកម្ពុជា មានន័យថាសកម្មភាពទាំងនោះមិនអាចអនុវត្តបានដោយមិនមានការគាំទ្រដែលផ្តល់ជូនដោយវិធីសាស្ត្រសហការនោះទេ។
  - លក្ខណៈបន្ថែម ក៏ត្រូវបានវាយតម្លៃនៅក្នុងកម្រិតយន្តការកាបូនដែលគម្រោង GHG ER បានចុះបញ្ជី ស្របតាមវិធីសាស្ត្រពាក់ព័ន្ធដែលបានប្រើប្រាស់ដោយយន្តការកាបូន។

## ៦. GHG ER ត្រូវបានបង្កើតចាប់ពីឆ្នាំ២០២១ តទៅ

- នេះគឺជាលក្ខខណ្ឌតម្រូវនៃវិធានប្រតិបត្តិមាត្រា ៦.២ ដែលថា GHG ER ដែលបានអនុញ្ញាត ត្រូវបង្កើតឡើង ស្របតាម ឬតំណាងឱ្យការកាត់បន្ថយការបញ្ចេញឧស្ម័នចាប់ពីឆ្នាំ២០២១ តទៅ។[26]
- រាជរដ្ឋាភិបាលកម្ពុជា នឹងមិនផ្តល់លិខិតអនុញ្ញាតសម្រាប់ GHG ER ដែលសម្រេចបានមុនឆ្នាំ២០២១ នោះទេ។

## ៧. គម្រោង GHG ER ធានានូវសុចរិតភាពបរិស្ថាន

- ម្ចាស់គម្រោង GHG ER ទាំងអស់ដែលមានបំណងបង្កើត GHG ER ដែលមានការអនុញ្ញាត ត្រូវតែបង្ហាញជាផ្នែកនៃសំណើសុំការអនុញ្ញាតរបស់ពួកគេ ដែលពួកគេធានាបាននូវសុចរិតភាពបរិស្ថានដោយ៖
  - ការកំណត់បន្ទាត់មូលដ្ឋាន និងការព្យាករណ៍ការបញ្ចេញឧស្ម័នក្រោម "ការព្យាករណ៍តាមទម្លាប់ធម្មតា"។
  - ការកាត់បន្ថយហានិភ័យនៃការមិនបំពេញកាតព្វកិច្ចកាត់បន្ថយការបញ្ចេញឧស្ម័ន។
- រាជរដ្ឋាភិបាលនឹងមិនផ្តល់លិខិតអនុញ្ញាតដល់ម្ចាស់គម្រោងដែលមិនបង្ហាញថាគម្រោង GHG ER ធានាបាននូវសុចរិតភាពបរិស្ថាននោះទេ។

[26] UNFCCC សេចក្តីសម្រេច ២/CMA.៣ ឧបសម្ព័ន្ធ កថាខណ្ឌ ១ (e)។

## ៨. គម្រោងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ គឺត្រូវស្របតាមចំណុចអាទិភាពនៃការអភិវឌ្ឍប្រកបដោយចីរភាពរបស់ប្រទេសកម្ពុជា

- គម្រោងដែលបង្កើតចេញពីគម្រោងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ដែលមានការអនុញ្ញាត ត្រូវតែមានសង្គតិភាព និងរួមចំណែកដល់គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់ប្រទេសកម្ពុជា។ រាជរដ្ឋាភិបាលកម្ពុជា បានបង្កើតលក្ខណៈវិនិច្ឆ័យរួចជាស្រេច ដើម្បីវាយតម្លៃភាពស្របគ្នានៃគម្រោងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ជាមួយនឹងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ដែលបង្ហាញនៅក្នុងតារាងទី២។
- គម្រោងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ទាំងអស់ត្រូវតែបំពេញតាមលក្ខណៈវិនិច្ឆ័យទាំងនេះ ដើម្បីទទួលបានការអនុញ្ញាតពីអាជ្ញាធរជាតិ។ ម្ចាស់គម្រោងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ត្រូវតែបង្ហាញអំពីរបៀបដែលខ្លួនបំពេញតាមចំណុចអាទិភាពអភិវឌ្ឍន៍ប្រកបដោយចីរភាពដែលជាផ្នែកមួយនៃពាក្យស្នើសុំការអនុញ្ញាតដោយប្រើប្រាស់គំរូនៅក្នុងគំរូទម្រង់សំណើសុំការអនុញ្ញាតនៃកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ (ឧបសម្ព័ន្ធ ៣)។
- រាល់ពិន្ទុដែលមានសញ្ញាអវិជ្ជមាន [សញ្ញា (-)] ណាមួយ គឺត្រូវចាត់ទុកថាមិនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់។

*តារាង ២៖ បញ្ជីលក្ខណៈវិនិច្ឆ័យអភិវឌ្ឍន៍ប្រកបដោយចីរភាពសម្រាប់ការវាយតម្លៃសំណើសុំគម្រោងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់នៅកម្ពុជា*

| លក្ខណៈវិនិច្ឆ័យសិទ្ធិ | ការវាយតម្លៃ |
|---|---|
| *ប្រភេទ ១. ការលើកកម្ពស់ប្រាក់ចំណូល និងគុណភាពជីវិតនៅក្នុងសង្គម* | |
| ១.១ ការកាត់បន្ថយភាពក្រីក្រ | +<br>• បង្កើនឱកាសបង្កើតប្រាក់ចំណូលសម្រាប់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន<br>• លើកកម្ពស់ជីវភាពរបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន ជាពិសេសប្រជាជនក្រីក្រ និងក្រុមប្រជាជនងាយរងគ្រោះ<br><br>0 មិនមានឥទ្ធិពលគួរឱ្យកត់សម្គាល់ទៅលើជីវភាពរស់នៅរបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋានឡើយ<br><br>-<br>• ការធ្វើឱ្យប្រជាពលរដ្ឋក្នុងមូលដ្ឋានបាត់បង់លទ្ធភាពទទួលបានធនធានសម្រាប់ការបង្កើតចំណូល |

| លក្ខណៈវិនិច្ឆ័យសិទ្ធិ | ការវាយតម្លៃ |
|---|---|
| | • ការបម្លាស់ទីប្រជាពលរដ្ឋដោយមិនមានផ្តល់ជម្រើសផ្សេងទៀតសម្រាប់ការបង្កើតចំណូល |
| ១.២ ការផ្តល់ហេដ្ឋារចនាសម្ព័ន្ធសហគមន៍ | + ការផ្តល់ហេដ្ឋារចនាសម្ព័ន្ធសហគមន៍ (អណ្តូងទឹក ផ្លូវថ្នល់ សាលារៀន ជាដើម)<br><br>0 ពុំមានឥទ្ធិពលអ្វីគួរឱ្យកត់សម្គាល់ទៅលើហេដ្ឋារចនាសម្ព័ន្ធសហគមន៍ឡើយ<br><br>- ការធ្វើឱ្យខូចខាតដល់ហេដ្ឋារចនាសម្ព័ន្ធសហគមន៍ (អណ្តូងទឹក ផ្លូវថ្នល់ សាលារៀន ជាដើម) ដោយសកម្មភាពពាក់ព័ន្ធនឹងគម្រោង |
| ១.៣ ការពិគ្រោះយោបល់ភាគីពាក់ព័ន្ធ | +<br>• ការពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធតាំងពីពេលចាប់ផ្តើមគម្រោង<br>• គម្រោងបានរៀបចំឡើងដោយមានកិច្ចសហការជាមួយភាគីពាក់ព័ន្ធ<br>• ភាគីពាក់ព័ន្ធក្នុងមូលដ្ឋានគាំទ្រដល់គម្រោង<br>• ការចូលរួមរបស់ភាគីពាក់ព័ន្ធនៅក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្ត<br><br>0 បានពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធ និងបានរកឃើញឥទ្ធិពលតិចតួចប៉ុណ្ណោះ<br><br>-<br>• មិនមានការពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធ<br>• មិនយកចិត្តទុកដាក់លើមតិយោបល់របស់ភាគីពាក់ព័ន្ធ<br>• ការពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធធ្វើឡើងតែនៅចុងបញ្ចប់នៃការរៀបចំគម្រោងប៉ុណ្ណោះ ដោយពុំមានឱកាសកែសម្រួលគម្រោងឡើយ<br>• ភាគីពាក់ព័ន្ធក្នុងមូលដ្ឋានមិនគាំទ្រគម្រោង ឬជំទាស់នឹងគម្រោង |

| លក្ខណៈវិនិច្ឆ័យសិទ្ធិ | ការវាយតម្លៃ |
|---|---|
| ១.៤ លទ្ធភាពចូលប្រើប្រាស់ទ្រព្យសម្បត្តិក្នុងសហគមន៍ | + លើកកម្ពស់លទ្ធភាពសម្រាប់សហគមន៍គោលដៅក្នុងការចូលប្រើប្រាស់ទ្រព្យសម្បត្តិក្នុងសហគមន៍<br>0 ពុំមានការផ្លាស់ប្តូរគួរឱ្យកត់សម្គាល់ទៅលើលទ្ធភាពរបស់សហគមន៍គោលដៅក្នុងការចូលប្រើប្រាស់ទ្រព្យសម្បត្តិក្នុងសហគមន៍ឡើយ<br>- ការកាត់បន្ថយលទ្ធភាពរបស់សហគមន៍គោលដៅក្នុងការចូលប្រើប្រាស់ទ្រព្យសម្បត្តិក្នុងសហគមន៍ |
| ១.៥ សមធម៌នៅក្នុងការទទួលបានផលប្រយោជន៍សហគមន៍របស់គម្រោងសម្រាប់សហគមន៍គោលដៅ | + គាំទ្រដល់ក្រុមប្រជាជនងាយរងគ្រោះបំផុតនៃសហគមន៍គោលដៅឱ្យមានលទ្ធភាពទទួលបានផលប្រយោជន៍សហគមន៍របស់គម្រោង<br>0 សមធម៌សម្រាប់សហគមន៍គោលដៅក្នុងការទទួលបានផលប្រយោជន៍សហគមន៍របស់គម្រោង<br>- លទ្ធភាពសម្រាប់សហគមន៍គោលដៅក្នុងការទទួលបានផលប្រយោជន៍សហគមន៍របស់គម្រោងមិនមានសមធម៌ |
| ១.៦ ការបង្កើតការងារនៅក្នុងប្រទេស | + បង្កើនចំនួនការងារនៅថ្នាក់ជាតិ/តំបន់ ឬមូលដ្ឋាន<br>0 ពុំមានការផ្លាស់ប្តូរគួរឱ្យកត់សម្គាល់ទៅលើការងារធៀបទៅនឹងបន្ទាត់គោលនោះទេ ពោលគឺមិនបានបង្កើតការងារ ឬបាត់បង់ការងារ<br>-<br>• ការងារទាំងអស់ដែលបានកំណត់នៅក្នុងបន្ទាត់គោល គឺត្រូវបានលុបចោល<br>• ការបាត់បង់ការងារ |
| ១.៧ ឥទ្ធិពលទៅលើសុខភាពសាធារណៈ | + ការលើកកម្ពស់សុខភាពសាធារណៈ<br>0 ពុំមានឥទ្ធិពលគួរឱ្យកត់សម្គាល់ទៅលើសុខភាពសាធារណៈនោះទេ<br>- ឥទ្ធិពលមិនល្អទៅលើសុខភាពសាធារណៈ |
| ១.៨ សមធម៌យេនឌ័រ | + ការលើកកម្ពស់សមធម៌យេនឌ័រ និងការពង្រឹងសិទ្ធិអំណាចដល់ស្ត្រី |

| លក្ខណៈវិនិច្ឆ័យសិទ្ធិ | ការវាយតម្លៃ |
|---|---|
| | 0 ពុំមានការផ្លាស់ប្តូរអ្វីគួរឱ្យកត់សម្គាល់ទៅលើសមធម៌យេនឌ័រ និងការពង្រឹងសិទ្ធិអំណាចដល់ស្ត្រីនោះទេ<br>- ការធ្វើឱ្យថយចុះនូវសមធម៌យេនឌ័រ ការរើសអើងលើស្ត្រី |
| ១.៩ ការបន្សាំ | + ការរួមចំណែកដល់ការពង្រឹងសមត្ថភាពនៅក្នុងការបន្សាំ<br>0 ពុំមានការផ្លាស់ប្តូរគួរឱ្យកត់សម្គាល់ទៅលើការពង្រឹងសមត្ថភាពនៅក្នុងការបន្សាំនោះទេ<br>- ការថយចុះ ឬការកាត់បន្ថយសមត្ថភាពនៅក្នុងការបន្សាំ |
| *ប្រភេទ ២. ការផ្ទេរបច្ចេកវិទ្យា* | |
| ២.១ ការផ្ទេរបច្ចេកវិទ្យាដែលមានលក្ខណៈសមស្រប និងល្អបំផុត | +<br>• បច្ចេកវិទ្យាល្អបំផុតនៅក្នុងសេដ្ឋកិច្ចឧស្សាហកម្មទំនើប<br>• បច្ចេកវិទ្យាល្អបំផុត និងបច្ចេកវិទ្យាដែលមានការទទួលស្គាល់<br>• បច្ចេកវិទ្យាល្អបំផុត និងបច្ចេកវិទ្យាដែលអាចថែទាំបានយ៉ាងងាយស្រួលនៅក្នុងមូលដ្ឋាន<br>• បច្ចេកវិទ្យាល្អបំផុត និងបច្ចេកវិទ្យាដែលសមស្របសម្រាប់លក្ខខណ្ឌសេដ្ឋកិច្ច និងសង្គមនៅក្នុងមូលដ្ឋាន<br>0 បានប្រើប្រាស់បច្ចេកវិទ្យាស្តង់ដារ<br>-<br>• បច្ចេកវិទ្យាមិនសមស្រប មិនសម្របតាមតម្រូវការ និងសមត្ថភាពក្នុងមូលដ្ឋាន<br>• មិនមានឧបករណ៍ និងជំនាញសម្រាប់ការថែទាំនៅក្នុងប្រទេសកម្ពុជា<br>• បច្ចេកវិទ្យាមិនមានការទទួលស្គាល់ ប្រើប្រាស់នៅកម្ពុជាសម្រាប់ជាការសាកល្បងប៉ុណ្ណោះ |

| លក្ខណៈវិនិច្ឆ័យសិទ្ធិ | ការវាយតម្លៃ |
| --- | --- |
| | • បច្ចេកវិទ្យាមិនទទួលបានការអនុញ្ញាតនៅក្នុងប្រទេសរបស់វិនិយោគិន |
| ២.២ ការកសាងសមត្ថភាព | +<br>• ការផ្ទេរជំនាញសម្រាប់ការប្រើប្រាស់ និងការថែទាំបច្ចេកវិទ្យា/ឧបករណ៍<br>• ការប្រើប្រាស់ក្រុមហ៊ុនក្នុងស្រុក ដើម្បីដំឡើង និងថែទាំឧបករណ៍<br>• ការបណ្តុះបណ្តាលអ្នកបច្ចេកទេសក្នុងមូលដ្ឋាននៅក្នុងជំនាញដែលមិនមាននៅក្នុងប្រទេសកម្ពុជា<br>0 ការបណ្តុះបណ្តាលអ្នកបច្ចេកទេសក្នុងមូលដ្ឋាននៅក្នុងជំនាញដែលមានស្រាប់នៅក្នុងប្រទេសកម្ពុជា<br>-<br>• មិនមានការផ្ទេរជំនាញសម្រាប់ការប្រើប្រាស់ និងការថែទាំបច្ចេកវិទ្យា/ឧបករណ៍<br>• មិនប្រើប្រាស់ក្រុមហ៊ុនក្នុងស្រុកដើម្បីដំឡើង និងថែទាំឧបករណ៍<br>• ការពឹងផ្អែកទៅលើជំនាញការអន្តរជាតិដើម្បីដំឡើង/ថែទាំឧបករណ៍ |
| *ប្រភេទ ៣. អត្ថប្រយោជន៍ផ្នែកសេដ្ឋកិច្ច* | |
| ៣.១ ការប្រើប្រាស់អាជីវកម្ម និងឧស្សាហកម្មក្នុងមូលដ្ឋាន | +<br>• គម្រោងធ្វើការងារផ្ទាល់ជាមួយដៃគូក្នុងមូលដ្ឋាន<br>• ប្រើប្រាស់ក្រុមហ៊ុនក្នុងស្រុកដើម្បីផលិតឧបករណ៍<br>0 ការប្រើប្រាស់អាជីវកម្ម និងឧស្សាហកម្មក្នុងមូលដ្ឋានតិចតួច<br>-<br>• មិនបានចាត់តាំងក្រុមហ៊ុនក្នុងមូលដ្ឋានក្នុងអំឡុងពេលនៃដំណាក់កាលរចនា សាងសង់ អនុវត្ត ឬថែទាំ<br>• មិនបានចាត់តាំងឱ្យក្រុមហ៊ុនក្នុងស្រុកផលិតឧបករណ៍ឡើយ |

| លក្ខណៈវិនិច្ឆ័យសិទ្ធិ | ការវាយតម្លៃ |
|---|---|
| ៣.១ ចំណែកនៃថវិកាគម្រោងដែលបានចំណាយនៅក្នុងប្រទេស | + ចំណែកយ៉ាងធំនៃថវិកាសរុបបានចំណាយនៅក្នុងប្រទេសទៅលើសេដ្ឋកិច្ចកម្ពុជា<br><br>0 ចំណែកសមរម្យនៃថវិកាសរុបដែលបានចំណាយនៅក្នុងប្រទេសទៅលើសេដ្ឋកិច្ចកម្ពុជា<br><br>- ចំណែកតិចតួចនៃថវិកាសរុបដែលបានចំណាយនៅក្នុងប្រទេសទៅលើសេដ្ឋកិច្ចកម្ពុជា |
| ៣.៣ ការកាត់បន្ថយការពឹងផ្អែកទៅលើឥន្ធនៈផូស៊ីល (គម្រោងថាមពលប៉ុណ្ណោះ) | +<br><br>• ការកាត់បន្ថយការពឹងផ្អែកទៅលើឥន្ធនៈហ្វូស៊ីល<br>• ការបង្កើនការប្រើប្រាស់ថាមពលកកើតឡើងវិញ និង/ឬប្រភពថាមពលស្អាត<br><br>0 មិនមានឥទ្ធិពលអ្វីគួរឱ្យកត់សម្គាល់ទៅលើការពឹងផ្អែកទៅលើឥន្ធនៈហ្វូស៊ីលនោះទេ<br><br>- បង្កើនការពឹងផ្អែកទៅលើឥន្ធនៈហ្វូស៊ីល |
| ៣.៤ ការកាត់បន្ថយការពឹងផ្អែកលើថាមពលនាំចូល (គម្រោងថាមពលប៉ុណ្ណោះ) | + ការកាត់បន្ថយការពឹងផ្អែកលើថាមពលនាំចូល<br><br>0 មិនមានឥទ្ធិពលអ្វីគួរឱ្យកត់សម្គាល់ទៅលើការពឹងផ្អែកលើថាមពលនាំចូល<br><br>- បង្កើនការពឹងផ្អែកលើថាមពលនាំចូល |

## ៣. ដំណើរការសម្រាប់គម្រោងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ក្រោមមាត្រា ៦

**ជំពូកនេះ មានគោលបំណងផ្តល់នូវការណែនាំអំពីដំណើរការដែលត្រូវអនុវត្តតាម ដើម្បីបង្កើត GHG ER ដែលបានអនុញ្ញាត សម្រាប់ប្រើប្រាស់ក្រោមវិធីសាស្រ្តសហការមាត្រា ៦.២ ដែលប្រទេសកម្ពុជាគឺជាសមាជិក។** ជំពូកនេះ លើកឡើងអំពីដំណើរការដែលបានបង្កើតឡើងដោយរាជរដ្ឋាភិបាលកម្ពុជាចំពោះ "លិខិតគាំទ្រ" ជូនដល់គម្រោងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ការអនុញ្ញាតនៃគម្រោងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ដែលបានបង្កើតឡើងពីគម្រោងនានាដែលបានអនុវត្តនៅក្នុងប្រទេសកម្ពុជា ក៏ដូចជាសម្រាប់ការចេញ និងការផ្ទេរ/ការលុប GHG ER ដែលបានអនុញ្ញាតរួច។

ចំណុចជាក់លាក់នៃជំពូកនេះ៖

- បង្កើតនីតិវិធី រួមទាំង លំដាប់លំដោយ និងពេលវេលាសម្រាប់សកម្មភាព ដែលម្ចាស់គម្រោងមានបំណងស្នើសុំការអនុញ្ញាត GHG ER ត្រូវតែអនុវត្តតាម។
- បញ្ជីឯកសារគាំទ្រ ដែលម្ចាស់គម្រោង GHG ER ត្រូវតែដាក់ជូន អាជ្ញាធរជាតិទៅតាមជំហាននីមួយៗ។ គំរូពាក់ព័ន្ធ គឺមានបញ្ចូលទៅក្នុងឧបសម្ព័ន្ធនៃឯកសារនេះ។
- បញ្ជាក់អំពីសកម្មភាពរបស់ អាជ្ញាធរជាតិដែលពាក់ព័ន្ធនៅក្នុងវដ្តគម្រោង GHG ER មាត្រា ៦ ក្នុងនោះត្រូវរួមបញ្ចូលទាំងលក្ខខណ្ឌតម្រូវរាយការណ៍ផងដែរ។

## ៣.១ រចនាសម្ព័ន្ធជំពូក

**វដ្តនៃគម្រោង GHG ER មាត្រា ៦ ក្នុងជំពូកនេះ បែងចែកជាដំណាក់កាលសំខាន់ៗចំនួនបី រួមមានដំណាក់កាលមុនការអនុវត្តគម្រោង ដំណាក់កាលអនុវត្តគម្រោង និងដំណាក់កាលចេញ និងផ្ទេរ/លុបចោល។**

*រូបភាព ៣៖ ដំណាក់កាលនៃវដ្ត GHG ER មាត្រា ៦*




= ដំហានដែលមិនចាំបាច់

ជំពូកនេះ បែងចែកជាបីផ្នែក ដែលឆ្លើយតបទៅនឹងជំហានទាំងបីនៃវដ្តគម្រោង GHG ER មាត្រា ៦ ដូចមានបង្ហាញនៅក្នុងរូបភាព ផ្នែកនីមួយៗរួមមាន៖

- តារាងលំហូរដំណើរការ ដែលបង្ហាញអំពីសកម្មភាពដែលតម្រូវដោយតួអង្គជាក់លាក់។
- បញ្ជីនៃជំហានដែលគ្របដណ្តប់នៅក្នុងតារាងលំហូរដំណើរការ ដែលមានរូបសញ្ញា (សូមមើលតារាង ៣) ដើម្បីបង្ហាញអំពីតួអង្គពាក់ព័ន្ធ និងផ្សារភ្ជាប់ទៅនឹងឯកសារផ្សេងៗទៀតក្នុងករណីពាក់ព័ន្ធ។
- តារាងដែលផ្តល់ព័ត៌មានអំពីជំហានលម្អិតសម្រាប់ម្ចាស់គម្រោងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ និងអាជ្ញាធរជាតិ ពាក់ព័ន្ធនឹងការដាក់ជូន និងការវាយតម្លៃ "លិខិតគាំទ្រ" នៃគម្រោងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ការអនុញ្ញាត និងការពិនិត្យវិជ្ជមាននៃគម្រោងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ព្រមទាំងការចេញ និងការផ្ទេរ/ការលុបចោលគម្រោងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ដែលបានអនុម័ត។

*តារាង ៣.៖ ការពិពណ៌នាអំពីតួអង្គ*

| តួអង្គ | ការពិពណ៌នា |
|---|---|
| ម្ចាស់គម្រោង<br> | ម្ចាស់គម្រោង (ត្រូវបានគេស្គាល់ថាជាអ្នកអភិវឌ្ឍន៍គម្រោង) គឺជាអង្គភាពដែលរចនា និងអនុវត្តគម្រោងដែលបង្កើត GHG ER ។ ម្ចាស់គម្រោងអាចជាអង្គភាពរដ្ឋាភិបាល អង្គភាពវិស័យឯកជន ឬអង្គការមិនមែនរដ្ឋាភិបាល។ |
| អាជ្ញាធរជាតិ (NA)<br> | អាជ្ញាធរជាតិ សម្រាប់យន្តការ GHG ER គឺជាស្ថាប័នមួយដែលត្រូវបានបង្កើតឡើងតាមរយៈសៀវភៅណែនាំប្រតិបត្តិការនៃមាត្រា ៦ នេះ។ អាជ្ញាធរជាតិ ក៏ទទួលខុសត្រូវចំពោះការអនុញ្ញាត GHG ER ដែលបង្កើតដោយគម្រោង GHG ER សម្រាប់ប្រើប្រាស់ក្រោមមាត្រា ៦។ |
| យន្តការកាបូន<br> | យន្តការផ្តល់ឥណទានកាបូន (ត្រូវបានគេស្គាល់ថាជាស្តង់ដារកាបូន) គឺជាប្រព័ន្ធដែលអនុញ្ញាតឱ្យមានការទូទាត់ GHG ER ដោយការចេញឥណទាន។ យន្តការផ្តល់ឥណទានកាបូនកំណត់ក្របខ័ណ្ឌដែល GHG ER ត្រូវបានវាស់វែង ផ្ទៀងផ្ទាត់ និងចេញជាឥណទាន។ មុខងារសំខាន់ៗដែលអនុវត្តដោយយន្តការឥណទានកាបូនមាន៖<br>• បង្កើត និងអនុម័តវិធីសាស្ត្រដែលបញ្ជាក់ពីរបៀបគណនាមូលដ្ឋាន និងវាស់វែង GHG ER ។<br>• ការទទួលស្គាល់សវនករឯករាជ្យភាគីទីបី ដែលទទួលខុសត្រូវក្នុងការត្រួតពិនិត្យភាពត្រឹមត្រូវនៃការរចនាគម្រោងប្រឆាំងនឹងវិធីសាស្ត្រជាក់លាក់មួយដែលត្រូវបានប្រើប្រាស់ដោយយន្តការផ្តល់ឥណទាន និងការផ្ទៀងផ្ទាត់ GHG ER។<br>• ដំណើរការបញ្ជីឈ្មោះដែលចេញឥណទានកាបូន (១ ឥណទាន = ១$tCO_2e$) និងអនុញ្ញាតឱ្យផ្ទេរកម្មសិទ្ធិនៃឥណទាន។ |
| សវនករឯករាជ្យ<br> | សវនករឯករាជ្យគឺជាអង្គភាពដែលត្រូវបានទទួលស្គាល់ដោយយន្តការឥណទានកាបូនដើម្បីអនុវត្តមុខងារសំខាន់ពីរ៖<br>• ធ្វើសុពលកម្មនៃការរចនាគម្រោង GHG ER ដោយពិនិត្យលើច្បាប់ និងតម្រូវការនៃយន្តការ/ស្តង់ដារ និងវិធីសាស្ត្រដែលអាចអនុវត្តបាន។<br>• ការផ្ទៀងផ្ទាត់ GHG ER ដែលបានកើតឡើងជាលទ្ធផលនៃគម្រោង។ ដំណើរការផ្ទៀងផ្ទាត់បញ្ជាក់៖<br>  ○ GHG ER សម្រេចបាន ស្របតាមឯកសារគម្រោងដែលធ្វើសុពលកម្ម។<br>  ○ ការប្រើប្រាស់ត្រឹមត្រូវនៃវិធីសាស្ត្រ និងឧបករណ៍ដែលអាចអនុវត្តបាននៃយន្តការកាបូន។<br>  ○ គម្រោងបន្តបំពេញតាមវិធាន និងតម្រូវការនៃយន្តការកាបូន។ |

## ៣.២ដំណាក់កាលមុនអនុវត្តគម្រោង

ផ្នែក ៣.២ នេះ (*ដំណាក់កាលមុនការអនុវត្តគម្រោង*) គូសបញ្ជាក់អំពីដំណើរការសម្រាប់ការស្នើសុំ "លិខិតគាំទ្រ" នៃគម្រោងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ និងការអនុម័តគម្រោងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ដែលបង្កើតចេញពីគម្រោងនានាដែលអនុវត្តនៅកម្ពុជាក្នុងអំឡុងពេលដំណាក់កាលមុនអនុវត្តគម្រោង (រូបភាព ៤)។

*រូបភាព ៤៖ ដំណើរការផ្តល់ការអនុញ្ញាតលើ GHG ER*




### ១. ជំហាន ១៖ លិខិតគាំទ្រ *(ជម្រើស)*

- **ការស្នើសុំលិខិតគាំទ្រ គឺជាជំហានជម្រើស ដែលអនុវត្តក៏បាន មិនអនុវត្តក៏បាន សម្រាប់គម្រោងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ទាំងអស់។** អាជ្ញាធរជាតិ លើកទឹកចិត្តឱ្យម្ចាស់គម្រោងទាំងអស់ធ្វើការស្នើសុំលិខិតបញ្ជាក់ការគាំទ្រដើម្បីទទួលបានអនុសាសន៍ពីអាជ្ញាធរជាតិ អំពីរបៀបបង្កើន សហអត្ថប្រយោជន៍នៃការអភិវឌ្ឍប្រកបដោយចីរភាពឱ្យដល់កម្រិតអតិបរិមា និងដើម្បីធានាភាពស្របគ្នាជាមួយនឹងអាទិភាពការអភិវឌ្ឍជាតិ។
- នីតិវិធីសម្រាប់ការស្នើសុំ និងការទទួលបានលិខិតគាំទ្រ គឺមានរៀបរាប់លម្អិតនៅក្នុងតារាង៤។ ម្ចាស់គម្រោង នឹងភ្ជាប់ឯកសារទស្សនទាននៃគម្រោងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ជាមួយនឹងសំណើសុំលិខិតគាំទ្រ។
- បន្ទាប់ពីការចេញលិខិតគាំទ្ររួចហើយ អាជ្ញាធរជាតិ ក៏នឹងទទួលខុសត្រូវផងដែរចំពោះការបញ្ចូលព័ត៌មានលម្អិតអំពីគម្រោងទៅក្នុងបញ្ជីការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ថ្នាក់ជាតិ[27]

[27] មុនពេលដាក់ឱ្យដំណើរការបញ្ជីការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ថ្នាក់ជាតិ អាជ្ញាធរជាតិ អាចប្រើប្រាស់មធ្យោបាយផ្សេងៗដើម្បីតាមដានគម្រោងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ដែលត្រូវបានចេញជាមួយនឹងលិខិតគាំទ្រ។

- តួអង្គពាក់ព័ន្ធ៖
  - ម្ចាស់គម្រោង
  - អាជ្ញាធរជាតិ (NA)

*តារាង ៤. ដំណើរការសម្រាប់ការស្នើសុំលិខិតគាំទ្រលើគម្រោងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់*

| ជំហាន | តួអង្គ | ធាតុចូល | សកម្មភាព | ធាតុចេញ |
|---|---|---|---|---|
| ១.១ | ម្ចាស់គម្រោង | • ពាក្យស្នើសុំលិខិតគាំទ្រ (ឧបសម្ព័ន្ធ ១)<br>• ឯកសារទស្សនាទានគម្រោង | • ដាក់សំណើសុំលិខិតគាំទ្រជូនដល់លេខាធិការដ្ឋានអាជ្ញាធរជាតិ។ | • លេខាធិការដ្ឋានអាជ្ញាធរជាតិទទួលសំណើសុំលិខិតគាំទ្រ។ |
| ១.២ | លេខាធិការដ្ឋានអាជ្ញាធរជាតិ | • សំណើសុំលិខិតគាំទ្រ | • ផ្ទៀងផ្ទាត់ភាពពេញលេញនៃសំណើសុំលិខិតគាំទ្រក្នុងរយៈពេល ៥ ថ្ងៃធ្វើការ។<br>• ស្នើសុំព័ត៌មានបន្ថែមប្រសិនបើចាំបាច់។ | • ជូនដំណឹងដល់ម្ចាស់គម្រោងអំពីសំណើសុំលិខិតគាំទ្រ និង<br>• បញ្ជូនសំណើសុំលិខិតគាំទ្រ ភ្លាមៗទៅកាន់អ្នកសម្របសម្រួលអាជ្ញាធរជាតិ និងប្រធានក្រុមបច្ចេកទេសអាជ្ញាធរជាតិ។ |
| ១.៣ | ប្រធានក្រុមបច្ចេកទេសអាជ្ញាធរជាតិ | • សំណើសុំលិខិតគាំទ្រ | • ពិគ្រោះយោបល់ជាមួយសមាជិកក្រុមបច្ចេកទេសអាជ្ញាធរជាតិមកពីវិស័យពាក់ព័ន្ធ។<br>• បង្កើតអនុសាសន៍ក្នុងរយៈពេល ១៥ ថ្ងៃធ្វើការ។ | • ដាក់ជូនលទ្ធផលរកឃើញ និងអនុសាសន៍ជូនដល់អ្នកសម្របសម្រួលអាជ្ញាធរជាតិ។ |
| ១.៤ | អ្នកសម្របសម្រួលអាជ្ញាធរជាតិ | • លទ្ធផលរកឃើញ និងអនុសាសន៍របស់ប្រធានក្រុមបច្ចេកទេសអាជ្ញាធរជាតិ | • ធ្វើសេចក្តីសម្រេចចិត្តស្ថាពរ (ការទទួលយក/ការបដិសេធ) សំណើសុំការអនុញ្ញាតក្នុងរយៈពេល ៥ ថ្ងៃធ្វើការ។ | • ក្នុងករណីសេចក្តីសម្រេចវិជ្ជមាន ចេញលិខិតគាំទ្រជូនដល់ម្ចាស់គម្រោង។<br>• ក្នុងករណីសេចក្តីសម្រេចអវិជ្ជមាន ជូនដំណឹងដល់ម្ចាស់គម្រោងអំពីការបដិសេធ។ |

## ២. ជំហាន ២៖ ការធ្វើសុពលកម្ម

- ម្ចាស់គម្រោង ត្រូវដាក់សំណើសុំការធ្វើសុពលកម្មឯករាជ្យស្របតាមនីតិវិធីដែលបានបង្កើតឡើងដោយយន្តការកាបូនពាក់ព័ន្ធ។
- យន្តការកាបូនដែលមានសិទ្ធិចេញបរិមាណការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ដែលបានអនុញ្ញាតដែលបានបង្កើតពីគម្រោងនៅក្នុងប្រទេសកម្ពុជា គឺមាន នៅក្នុងជំពូក ២។
- តួអង្គពាក់ព័ន្ធ៖
    - ម្ចាស់គម្រោង
    - សវនករ
    - យន្តការវេណទានកាបូន

## ៣. ជំហាន ៣៖ ការអនុញ្ញាត

- ការស្នើសុំលិខិតអនុញ្ញាត គឺជាជំហានចាំបាច់សម្រាប់គ្រប់ម្ចាស់គម្រោងទាំងអស់ ដែលស្នើសុំការអនុញ្ញាតនៃមាត្រា ៦ ទៅលើការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ដែលបានបង្កើតឡើងពីគម្រោងរបស់ខ្លួន។
- ដំណើរការសម្រាប់ការស្នើសុំការអនុញ្ញាតគម្រោងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ គឺមានរៀបរាប់លម្អិតនៅក្នុងតារាង ៥។
- តួអង្គពាក់ព័ន្ធ៖
    - ម្ចាស់គម្រោង
    - អាជ្ញាធរជាតិ (NA)

*តារាង ៥៖ ដំណើរការសម្រាប់ការអនុញ្ញាតការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់*

| ជំហាន | តួអង្គ | ធាតុចូល | សកម្មភាព | លទ្ធផល |
|---|---|---|---|---|
| ៣.១ | ម្ចាស់គម្រោង | • ពាក្យស្នើសុំការអនុញ្ញាត (ឧបសម្ព័ន្ធ ៣)<br>• របាយការណ៍សុពលកម្ម | • ដាក់ទម្រង់ស្នើសុំលិខិតអនុញ្ញាតជូនលេខាធិការដ្ឋានអាជ្ញាធរជាតិ | • លេខាធិការដ្ឋាននៃអាជ្ញាធរជាតិទទួលបានសំណើសុំការអនុញ្ញាត |
| ៣.២ | លេខាធិការដ្ឋានអាជ្ញាធរជាតិ | • សំណើសុំការអនុញ្ញាត | • ផ្ទៀងផ្ទាត់ភាពពេញលេញនៃសំណើសុំការអនុញ្ញាតនៅក្នុងរយៈពេល ៥ ថ្ងៃធ្វើការ<br>• ស្នើសុំឯកសារបន្ថែមប្រសិនបើចាំបាច់ | • ជូនដំណឹងដល់ម្ចាស់គម្រោងអំពីការទទួលបានសំណើសុំការអនុញ្ញាតនិង<br>• ផ្ញើសំណើសុំការអនុញ្ញាតភ្លាមៗទៅកាន់អ្នកសម្របសម្រួលនៃ អាជ្ញាធរជាតិ និងប្រធានក្រុមបច្ចេកទេសនៃអាជ្ញាធរជាតិ |
| ៣.៣ | ប្រធានក្រុមបច្ចេកទេសនៃអាជ្ញាធរជាតិ | • សំណើសុំការអនុញ្ញាត | • ចាត់តាំងសមាជិកគណៈកម្មការត្រួតពិនិត្យបច្ចេកទេសនៃអាជ្ញាធរជាតិនៅក្នុងរយៈពេល ១០ ថ្ងៃធ្វើការ | • ជូនដំណឹងដល់បុគ្គលដែលបានចាត់តាំងឱ្យដើរតួនាទីជាសមាជិកនៃគណៈកម្មការត្រួតពិនិត្យបច្ចេកទេស |

| | | | | |
|---|---|---|---|---|
| ៣.៤ | គណៈកម្មការត្រួតពិនិត្យបច្ចេកទេសនៃអាជ្ញាធរជាតិ | • សំណើសុំការអនុញ្ញាត | • វាយតម្លៃសំណើសុំការអនុញ្ញាតដោយធៀបទៅនឹងលក្ខណៈវិនិច្ឆ័យអនុញ្ញាតនៅក្នុងរយៈពេល ៣០ ថ្ងៃធ្វើការ<br>• លក្ខណៈវិនិច្ឆ័យនៃការអនុញ្ញាតមានរៀបរាប់នៅក្នុងតារាងទី ១ | • ដាក់ជូនរបាយការណ៍អមជាមួយលទ្ធផលរកឃើញ និងអនុសាសន៍ជូនដល់ប្រធានក្រុមបច្ចេកទេសនៃអាជ្ញាធរជាតិ |
| ៣.៥ | ប្រធានក្រុមបច្ចេកទេសនៃអាជ្ញាធរជាតិ | • របាយការណ៍របស់គណៈកម្មការត្រួតពិនិត្យបច្ចេកទេសនៃអាជ្ញាធរជាតិ | • ផ្តល់អនុសាសន៍បច្ចេកទេសចុងក្រោយនៅក្នុងរយៈពេល ៥ ថ្ងៃធ្វើការ | • ផ្តល់អនុសាសន៍បច្ចេកទេសចុងក្រោយដល់អ្នកសម្របសម្រួលនៃអាជ្ញាធរជាតិ |
| ៣.៦ | អ្នកសម្របសម្រួលនៃអាជ្ញាធរជាតិ | • អនុសាសន៍ស្ថាពររបស់ប្រធានក្រុមបច្ចេកទេសអាជ្ញាធរជាតិ | • ផ្តល់សម្រេចចិត្តស្ថាពរទៅលើសំណើសុំការអនុញ្ញាតនៅក្នុងរយៈពេល ១០ ថ្ងៃធ្វើការ | • ក្នុងករណីសេចក្តីសម្រេចវិជ្ជមានសូមឱ្យប្រធានអាជ្ញាធរជាតិចុះហត្ថលេខា និងចេញលិខិតអនុញ្ញាត (ឧបសម្ព័ន្ធ ២) ជូនដល់ម្ចាស់គម្រោង<br>• ក្នុងករណីសេចក្តីសម្រេចអវិជ្ជមាន លិខិតបដិសេធនឹងចេញជូនដល់ម្ចាស់គម្រោង (រួមទាំងអនុសាសន៍អំពីការកែសម្រួល ប្រសិនបើមាន) |

## ៤. ជំហាន ៤៖ របាយការណ៍បឋម

- បន្ទាប់ពីការចេញលិខិតអនុញ្ញាតរួចហើយ លេខាធិការដ្ឋានអាជ្ញាធរជាតិ នឹងដាក់ជូននូវរបាយការណ៍បឋមក្រោមមាត្រា ៦ ជូនដល់ UNFCCC សម្រាប់វិធីសាស្ត្រសហការពាក់ព័ន្ធ។
- ដំណើរការសម្រាប់ការដាក់ជូនរបាយការណ៍បឋម គឺមានរៀបរាប់លម្អិតបន្ថែមខាងក្រោម (លក្ខខណ្ឌតម្រូវរបស់របាយការណ៍ UNFCCC ។
- តួអង្គពាក់ព័ន្ធ៖
    - អាជ្ញាធរជាតិ

## លក្ខខណ្ឌតម្រូវរបាយការណ៍របស់អនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC)

- *របាយការណ៍បឋម*
    - លេខាធិការដ្ឋានអាជ្ញាធរជាតិ នឹងដាក់របាយការណ៍បឋមក្រោមមាត្រា ៦.២ ស្របតាមវិធានប្រតិបត្តិមាត្រា ៦.២៖[28]
        - របាយការណ៍បឋមក្រោមមាត្រា ៦.២ ត្រូវតែដាក់ជូនឱ្យបានមុនលិខិតអនុញ្ញាតនៃការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់តាមរយៈវិធីសាស្ត្រសហការ អមជាមួយនឹងរបាយការណ៍តម្លាភាពពីរឆ្នាំម្តងរបស់កម្ពុជា។[29]
        - ជនបង្គោលថ្នាក់ជាតិរបស់ប្រទេសកម្ពុជា ត្រូវដាក់ជូនរបាយការណ៍បឋម តាមរយៈគេហទំព័របញ្ជូនឯកសាររបស់អនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC)។[30]
        - អនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC) បានផ្តល់គំរូរបាយការណ៍បឋមរួចហើយ។[31]

---

[28] សេចក្តីសម្រេចរបស់អនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC) លេខ ២/CMA.៣, ឧបសម្ព័ន្ធ កថាខណ្ឌ ១៨។

[29] យោងតាមកថាខណ្ឌ ១៧(ក) បុព្វកថានៃវិធានប្រតិបត្តិរបស់មាត្រា ៦.២ ដែលបានអនុម័តនៅ CMA.៤ វិធានប្រតិបត្តិបន្ថែមពាក់ព័ន្ធនឹងការកំណត់ដំណាក់កាល និងការកំណត់ពេលវេលានៃការដាក់របាយការណ៍បឋម គឺត្រូវពិចារណាតាម CMA.៥។

[30] ដំណោះស្រាយនេះគឺជាដំណោះស្រាយបណ្តោះអាសន្ន ដោយផ្អាកការបង្កើតវេទិកាគណនេយ្យ និងរបាយការណ៍មជ្ឈការរបស់ (CARP) របស់អនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC)។ វេបសាយឯកសារនេះអាចចូលប្រើប្រាស់បានតាមរយៈ៖ https://www4.unfccc.int/sites/submissionsstaging/Pages/Home.aspx.

[31] គំរូរបាយការណ៍បឋម គឺអាចរកបាននៅ៖ https://unfccc.int/process-and-meetings/the-paris-agreement/the-paris-agreement/cooperative-implementation/centralized-accounting-and-reporting-platform#Template.

- ○ សម្រាប់វិធីសាស្រ្តសហការបន្ថែមនីមួយៗ កម្ពុជា ត្រូវដាក់ជូនព័ត៌មានស្តីពីវិធីសាស្រ្តសហការនោះនៅក្នុងរបាយការណ៍បឋមបច្ចុប្បន្នភាព និងរួមបញ្ចូលព័ត៌មាននោះនៅក្នុងរបាយការណ៍តម្លាភាពពីរឆ្នាំម្តងដែលដល់កាលកំណត់។[32]

## ៣.៣ ការអនុវត្តគម្រោង

ផ្នែក ៣.៣ នេះ (*ការអនុវត្តគម្រោង*) គូសបញ្ជាក់អំពីដំណើរការសម្រាប់គម្រោងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ក្រោមមាត្រា ៦ ដែលអនុវត្តនៅក្នុងប្រទេសកម្ពុជា ក្នុងអំឡុងពេលដំណាក់កាលអនុវត្តគម្រោង (រូបភាព៥)។

*រូបភាព ៥៖ ដំណើរការសម្រាប់ការត្រួតពិនិត្យវិជ្ជមាននៃគម្រោងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់*




### ១. ជំហាន ១៖ ការចុះបញ្ជីគម្រោង

- ម្ចាស់គម្រោង ត្រូវតែស្នើសុំការចុះបញ្ជីគម្រោងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ជាមួយយន្តការកាបូនពាក់ព័ន្ធស្របតាមនីតិវិធីនៃយន្តការ។
- តួអង្គពាក់ព័ន្ធ៖
  - ○ ម្ចាស់គម្រោង
  - ○ យន្តការផលធានកាបូន



[32] សេចក្តីសម្រេចរបស់អនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC) លេខ ២/CMA.៣, ឧបសម្ព័ន្ធ កថាខណ្ឌ ១៩។

## ២. ជំហាន ២៖ ការអនុវត្តគម្រោង

- ម្ចាស់គម្រោង អនុវត្តគម្រោងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់។
- តួអង្គពាក់ព័ន្ធ៖
    - ម្ចាស់គម្រោង



## ៣. ជំហាន ៣៖ ការផ្ទៀងផ្ទាត់

- ម្ចាស់គម្រោង ត្រូវដាក់សំណើសុំការផ្ទៀងផ្ទាត់ឯករាជ្យស្របតាមនីតិវិធីដែលបានបង្កើតឡើងដោយយន្តការកាបូនពាក់ព័ន្ធ។
- តួអង្គពាក់ព័ន្ធ៖
    - ម្ចាស់គម្រោង
    - សវនករ
    - យន្តការឥណទានកាបូន



## ៤. ជំហាន ៤៖ ការត្រួតពិនិត្យវិជ្ជមាន

- ការស្នើសុំលិខិតត្រួតពិនិត្យវិជ្ជមាន គឺជាជំហានចាំបាច់សម្រាប់គ្រប់ម្ចាស់គម្រោងទាំងអស់ ដែលស្នើសុំការអនុញ្ញាតទៅលើការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ដែលបានអនុញ្ញាត និងបានបង្កើតឡើងពីគម្រោងរបស់ខ្លួន។
- **ការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ណាមួយដែលមិនមានលិខិតត្រួតពិនិត្យវិជ្ជមាន នោះរាជរដ្ឋាភិបាលកម្ពុជា នឹងមិនចាត់ទុកថាជាការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ដែលមានការអនុញ្ញាតឡើយ។**
- ដំណើរការសម្រាប់ការស្នើសុំការត្រួតពិនិត្យវិជ្ជមានលើការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ គឺមានរៀបរាប់លម្អិតនៅក្នុងតារាង ខាងក្រោម។
- តួអង្គពាក់ព័ន្ធ៖
    - ម្ចាស់គម្រោង
    - អាជ្ញាធរជាតិ (NA)



*តារាង ៦៖ ដំណើរការសម្រាប់ការត្រួតពិនិត្យវិជ្ជមាននៃការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់*

| ជំហាន | តួអង្គ | ធាតុចូល | សកម្មភាព | លទ្ធផល |
|---|---|---|---|---|
| ៤.១ | ម្ចាស់គម្រោង | • ទម្រង់ស្នើសុំត្រួតពិនិត្យវិជ្ជមាន (ឧបសម្ព័ន្ធ៥)<br>• របាយការណ៍ផ្ទៀងផ្ទាត់ | • ដាក់ជូនទម្រង់សំណើសុំការត្រួតពិនិត្យវិជ្ជមាន និងរបាយការណ៍ផ្ទៀងផ្ទាត់ជូនដល់លេខាធិការដ្ឋាននៃអាជ្ញាធរជាតិ | • លេខាធិការដ្ឋាននៃអាជ្ញាធរជាតិត្រួតពិនិត្យសំណើ |
| ៤.២ | លេខាធិការដ្ឋានអាជ្ញាធរជាតិ | • សំណើសុំត្រួតពិនិត្យវិជ្ជមាន | • ផ្ទៀងផ្ទាត់ភាពពេញលេញនៃសំណើសុំត្រួតពិនិត្យវិជ្ជមាននៅក្នុងរយៈពេល ៥ ថ្ងៃធ្វើការ<br>• ស្នើសុំឯកសារបន្ថែមប្រសិនបើចាំបាច់ | • ជូនដំណឹងដល់ម្ចាស់គម្រោងអំពីការទទួលបានសំណើសុំត្រួតពិនិត្យ |
| ៤.៣ | លេខាធិការដ្ឋានអាជ្ញាធរជាតិ | • សំណើសុំត្រួតពិនិត្យវិជ្ជមាន | • ផ្ទៀងផ្ទាត់ថា សំណើសុំត្រួតពិនិត្យវិជ្ជមាន គឺស្របជាមួយនឹងខ្លឹមសារអនុញ្ញាតនៅក្នុងលិខិតអនុញ្ញាតនៅក្នុងរយៈពេល ៥ ថ្ងៃធ្វើការ[33] | • ក្នុងករណីនៃការវាយតម្លៃវិជ្ជមាន សូមផ្តល់អនុសាសន៍ដល់អ្នកសម្របសម្រួលនៃអាជ្ញាធរជាតិ<br>• ក្នុងករណីនៃការវាយតម្លៃអវិជ្ជមាន សូមផ្តល់អនុសាសន៍អំពីការបដិសេធនោះជូនដល់អ្នកសម្របសម្រួលនៃអាជ្ញាធរជាតិ។ |

[33] សមាសធាតុទាំងនេះ គឺមានរៀបរាប់លម្អិតនៅក្នុងលិខិតអនុញ្ញាត។ សមាសធាតុទាំងនេះមាន៖ វិធីសាស្ត្រសហការដែលបានអនុញ្ញាត អង្គភាពដែលបានអនុញ្ញាត បរិមាណនៃការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់សរុបបូកបង្គរអតិបរិមាដែលទទួលបានការអនុញ្ញាតឱ្យផ្ទេរ និងប្រើប្រាស់ជាលក្ខណៈអន្តរជាតិ រយៈពេលអនុញ្ញាត រយៈពេលនៃការចូលរួមចំណែករបស់ជាតិ ដែលក្នុងរយៈពេលនោះមានការអនុញ្ញាតឱ្យប្រើប្រាស់ការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ការចេញយន្តការកាបូន ការប្រើប្រាស់ការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ដែលបានអនុញ្ញាត។

| | | | | |
|---|---|---|---|---|
| ៤.៤ | អ្នកសម្របសម្រួលនៃអាជ្ញាធរជាតិ | • អនុសាសន៍របស់លេខាធិការដ្ឋាននៃអាជ្ញាធរជាតិ | • ធ្វើការសម្រេចចិត្តស្តាពរទៅលើសំណើសុំត្រួតពិនិត្យវិជ្ជមាននៅក្នុងរយៈពេល ១០ ថ្ងៃ | • ក្នុងករណីជាសេចក្តីសម្រេចវិជ្ជមាន សូមណែនាំលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិឱ្យចេញលិខិតត្រួតពិនិត្យវិជ្ជមាន (ឧបសម្ព័ន្ធ ៦) ដល់ម្ចាស់គម្រោង<br>• ក្នុងករណីជាសេចក្តីសម្រេចអវិជ្ជមាន សូមណែនាំលេខាធិការដ្ឋាននៃ អាជ្ញាធរជាតិឱ្យចេញលិខិតបដិសេធដល់ម្ចាស់គម្រោង។ |
| ៤.៥ | លេខាធិការដ្ឋានអាជ្ញាធរជាតិ | • លិខិតត្រួតពិនិត្យវិជ្ជមាន | • ធ្វើបច្ចុប្បន្នភាពបញ្ជីការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ថ្នាក់ជាតិដោយមានបរិមាណនៃការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ដែលមានសិទ្ធិសម្រាប់ការបញ្ចេញពីគម្រោង[34] | • ព័ត៌មានគម្រោង ត្រូវបានធ្វើបច្ចុប្បន្នភាពនៅក្នុងបញ្ជីការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ថ្នាក់ជាតិ ដើម្បីបង្ហាញថាគម្រោងអាចបង្កើតបរិមាណជាក់លាក់លើការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ដែលបានអនុញ្ញាត។ |

## ៥. ជំហាន ៥៖ ធ្វើបច្ចុប្បន្នភាពព័ត៌មានគម្រោងនៅក្នុងបញ្ជីការថ្នាក់ជាតិ

- បន្ទាប់ពីការចេញលិខិតត្រួតពិនិត្យវិជ្ជមាន អាជ្ញាធរជាតិ ត្រូវធ្វើបច្ចុប្បន្នភាពព័ត៌មានសម្រាប់គម្រោងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ពាក់ព័ន្ធនៅក្នុងបញ្ជីការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ថ្នាក់ជាតិ

[34] នីតិវិធីសម្រាប់ការគ្រប់គ្រងបញ្ជីការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ថ្នាក់ជាតិ រួមទាំងការធ្វើបច្ចុប្បន្នភាពព័ត៌មានពាក់ព័ន្ធនឹងការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ដែលបានអនុញ្ញាត គឺមានរៀបរាប់លម្អិតនៅក្នុងគោលការណ៍ណែនាំនៃបញ្ជីការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ថ្នាក់ជាតិ។

ដើម្បីបង្ហាញថា ឥឡូវនេះគម្រោងគឺអាចចេញ និងផ្ទេរការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ដែលបានអនុញ្ញាតហើយ (ស្របតាមលក្ខខណ្ឌដែលមានចែងនៅក្នុងលិខិតអនុញ្ញាត)។

- ម្យ៉ាងវិញទៀត មុនពេលដាក់ឱ្យដំណើរការបញ្ជីការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ថ្នាក់ជាតិ អាជ្ញាធរជាតិអាចប្រើប្រាស់បញ្ជីការអន្តរជាតិ ដែលនឹងផ្តល់ជូនដោយ UNFCCC ឬប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធ ដែលផ្តល់ជូនដោយយន្តការឥណទានកាបូនឯករាជ្យ ពាក់ព័ន្ធនឹងការផ្តល់ព័ត៌មានទាំងអស់ដែលតម្រូវដោយរាជរដ្ឋាភិបាលកម្ពុជា ដើម្បីបំពេញតាមលក្ខខណ្ឌតម្រូវរាយការណ៍នៃមាត្រា ៦។
- តួអង្គពាក់ព័ន្ធ៖
    - អាជ្ញាធរជាតិ

## លក្ខខណ្ឌតម្រូវរាយការណ៍របស់អនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC)

នៅក្នុងដំណាក់កាលនេះ មិនមានលក្ខខណ្ឌតម្រូវរាយការណ៍របស់អនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុនោះទេ។

## ៣.៤ ការចេញ និងផ្ទេរ/លុបចោល

ផ្នែក ៣.៤ នេះ (*ការចេញ និងការផ្ទេរ/ការលុបចោល*) គូសបញ្ជាក់អំពីដំណើរការសម្រាប់ការចេញ និងការផ្ទេរ និង/ឬការលុបចោលកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ថ្នាក់ជាតិដែលបានអនុញ្ញាត (រូបភាព ៦)។

*រូបភាព ៦៖ ដំណើរការសម្រាប់ការចេញ និងផ្ទេរ/លុបចោលការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ដែលបានអនុញ្ញាត*



## ១. ជំហាន ១៖ សំណើសុំចេញការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់

- នៅពេលដែលទទួលបានលិខិតត្រួតពិនិត្យវិជ្ជមានហើយ ម្ចាស់គម្រោងអាចដាក់សំណើសុំការចេញការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ តាមយន្តការកាបូនពាក់ព័ន្ធ ស្របតាមនីតិវិធីដែលបានបង្កើតឡើងដោយយន្តការនោះ។
- តួអង្គពាក់ព័ន្ធ៖
    - ម្ចាស់គម្រោង
    - យន្តការឥណទានកាបូន

## ២. ជំហាន ២៖ ជូនដំណឹងដល់អាជ្ញាធរជាតិអំពីការចេញការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់

- ម្ចាស់គម្រោង គឺតម្រូវឱ្យជូនដំណឹងដល់អាជ្ញាធរជាតិអំពីការចេញការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ នៅក្នុងរយៈពេលម្ភៃ(២០)ថ្ងៃធ្វើការបន្ទាប់ពីការចេញនោះដូចមានបញ្ជាក់នៅក្នុងតារាង៧។
- តួអង្គពាក់ព័ន្ធ៖
    - ម្ចាស់គម្រោង
    - អាជ្ញាធរជាតិ (NA)

*តារាង ៧៖ ការចេញ ការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ដែលបានអនុញ្ញាត*

| ជំហាន | តួអង្គ | ធាតុចូល | សកម្មភាព | លទ្ធផល |
|---|---|---|---|---|
| ២.១ | ម្ចាស់គម្រោង | លិខិតត្រួតពិនិត្យវិជ្ជមាន | • ស្នើសុំយន្តការកាបូន ដើម្បីចេញការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ដែលបានអនុញ្ញាត | • យន្តការកាបូនចេញបរិមាណជាក់លាក់នៃការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ដែលបានអនុញ្ញាត |
| ២.២ | ម្ចាស់គម្រោង | ភស្តុតាងបញ្ជាក់អំពីការចេញការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ | • ដាក់ជូនភស្តុតាងអំពីការចេញការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ដែលបានអនុញ្ញាតជូនដល់លេខាធិការដ្ឋានអាជ្ញាធរជាតិក្នុងរយៈពេល ២០ ថ្ងៃធ្វើការបន្ទាប់ពីការចេញ។ | • ប្រសិនបើបញ្ជីការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ថ្នាក់ជាតិដំណើរការ នោះលេខាធិការដ្ឋានអាជ្ញាធរជាតិត្រូវធ្វើបច្ចុប្បន្នភាពបញ្ជីការកាត់បន្ថយឧស្ម័ន ផ្ទះកញ្ចក់ថ្នាក់ជាតិជាមួយនឹងបរិមាណ |

| | | | | |
|---|---|---|---|---|
| | | | • លុះត្រាតែមានបញ្ជាក់ផ្សេងពីនេះការជូនដំណឹងនេះគួរតែធ្វើតាមរយៈអ៊ីម៉ែលទៅកាន់អាជ្ញាធរជាតិ។ | ពាក់ព័ន្ធនឹងការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ដែលបានចេញ និងលេខសម្គាល់កំណត់អត្តសញ្ញាណនៃការចេញនោះ និងផ្លាស់ប្តូរស្លាកសម្គាល់ទៅជា "បានចេញ"។<br>• ប្រសិនបើបញ្ជីការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ថ្នាក់ជាតិមិនទាន់ដំណើរការទេ នោះលេខាធិការដ្ឋានអាជ្ញាធរជាតិនឹងត្រូវពឹងផ្អែកលើព័ត៌មានដែលផ្តល់ជូនដោយយន្តការឥណទានកាបូនពាក់ព័ន្ធ។ |

### ៣. ជំហាន ៣៖ ស្នើសុំការផ្ទេរ/ការលុបចោលការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់លើកទី១

- ម្ចាស់គម្រោងត្រូវដាក់សំណើសុំផ្ទេរ និង/ឬលុបចោលការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ស្របតាមនីតិវិធីដែលបានបង្កើតឡើងដោយយន្តការកាបូនពាក់ព័ន្ធ។
- តួអង្គពាក់ព័ន្ធ៖
  - ម្ចាស់គម្រោង
  - យន្តការឥណទានកាបូន

### ៤. ជំហាន ៤៖ ជូនដំណឹងដល់អាជ្ញាធរជាតិអំពីការផ្ទេរ/ការលុបចោលការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់លើកទី១

- ម្ចាស់គម្រោង ដែលអនុវត្តគម្រោងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ក្រោមមាត្រា ៦ គឺតម្រូវឱ្យជូនដំណឹងដល់អាជ្ញាធរជាតិអំពីការផ្ទេរ និង/ឬការលុបចោលការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ដែលបានអនុញ្ញាតក្នុងរយៈពេលម្ភៃ (២០) ថ្ងៃធ្វើការ បន្ទាប់ពីការផ្ទេរ និង/ឬការលុបចោលនោះ ដូចមានបញ្ជាក់នៅក្នុងតារាង ៨។
- តួអង្គពាក់ព័ន្ធ៖
  - ម្ចាស់គម្រោង
  - អាជ្ញាធរជាតិ (NA)

*តារាង ៨៖ ការផ្ទេរ/ការលុបចោលការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ដែលបានអនុញ្ញាត*

| ជំហាន | តួអង្គ | ធាតុចូល | សកម្មភាព | លទ្ធផល |
|---|---|---|---|---|
| ២.១ | ម្ចាស់គម្រោង | ភស្តុតាងបញ្ជាក់អំពីការផ្ទេរ / ការលុបចោល | • ជូនដំណឹងដល់លេខាធិការដ្ឋានអាជ្ញាធរជាតិអំពីការផ្ទេរ/ការលុបចោលកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ដែលបានអនុញ្ញាតក្នុងរយៈពេល ២០ ថ្ងៃធ្វើការ បន្ទាប់ពីការផ្ទេរ/ការលុបចោល។<br>• លុះត្រាតែមានបញ្ជាក់ផ្សេងពីនេះការជូនដំណឹងនេះគួរតែធ្វើតាមរយៈអ៊ីម៉ែលទៅកាន់អាជ្ញាធរជាតិ។ | • ប្រសិនបើបញ្ជីកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ថ្នាក់ជាតិដំណើរការ លេខាធិការដ្ឋានអាជ្ញាធរជាតិត្រូវធ្វើបច្ចុប្បន្នភាពស្លាកសញ្ញាកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ពាក់ព័ន្ធនៅក្នុងបញ្ជីកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ថ្នាក់ជាតិ ទៅជា "បានផ្ទេរ" ឬ "បានលុបចោល"។<br>• ប្រសិនបើបញ្ជីកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ថ្នាក់ជាតិមិនទាន់ដំណើរការទេនោះ លេខាធិការដ្ឋានអាជ្ញាធរជាតិត្រូវពឹងផ្អែកលើព័ត៌មានដែលផ្តល់ជូនដោយយន្តការឥណទានកាបូនពាក់ព័ន្ធ។ |

### ៥. ជំហាន ៥៖ បញ្ចូលការប្រើប្រាស់ការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់នៅក្នុងព័ត៌មានប្រចាំឆ្នាំ

- លេខាធិការដ្ឋានអាជ្ញាធរជាតិ ត្រូវរួមបញ្ចូលព័ត៌មានពាក់ព័ន្ធនឹងការផ្ទេរ ការទិញ ការកាន់កាប់ និងការលុបចោលលើកដំបូងនៃការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ដែលបានអនុញ្ញាតដោយរាជរដ្ឋាភិបាលកម្ពុជានៅក្នុងព័ត៌មានដែលខ្លួនដាក់ជូននៅក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យក្រោមមាត្រា ៦ ជារៀងរាល់ឆ្នាំ។
- ដំណើរការសម្រាប់ការដាក់ជូនព័ត៌មានប្រចាំឆ្នាំ គឺមានរៀបរាប់លម្អិតបន្ថែមនៅក្នុងលក្ខខណ្ឌតម្រូវរាយការណ៍របស់ UNFCCC។
- តួអង្គពាក់ព័ន្ធ៖
    - អាជ្ញាធរជាតិ

## ៦. ជំហាន ៦៖ អនុវត្តវិធីសាស្ត្រកែតម្រូវឱ្យត្រូវគ្នា

- លេខាធិការដ្ឋានអាជ្ញាធរជាតិ ត្រូវអនុវត្តវិធីសាស្ត្រកែតម្រូវឱ្យត្រូវគ្នា ចំពោះគ្រប់ការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ដែលបានអនុញ្ញាតទាំងអស់ ដែលត្រូវបាន "ផ្ទេរលើកដំបូង" ដែលនាំឱ្យមានសមតុល្យការបញ្ចេញឧស្ម័ន ដែលនឹងត្រូវដាក់ជូន UNFCCC អមជាមួយនឹងរបាយការណ៍តម្លាភាពពីរឆ្នាំម្តង។
- ដំណើរការសម្រាប់ការអនុវត្ត និងការរាយការណ៍អំពីវិធីសាស្ត្រកែតម្រូវឱ្យត្រូវគ្នា គឺមានរៀបរាប់លម្អិតបន្ថែមនៅខាងក្រោម (គន្លឹះសម្រាប់ការអនុវត្តវិធីសាស្ត្រកែតម្រូវឱ្យត្រូវគ្នា)។
- តួអង្គពាក់ព័ន្ធ៖
    - អាជ្ញាធរជាតិ

## គន្លឹះសម្រាប់ការអនុវត្តវិធីសាស្ត្រកែតម្រូវឱ្យត្រូវគ្នា

- វិធីសាស្ត្រកែតម្រូវឱ្យត្រូវគ្នា ត្រូវតែអនុវត្តចំពោះចំនួនសរុបនៃការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ដែលបានអនុញ្ញាត ដែលជាការ "ផ្ទេរលើកដំបូង" សម្រាប់ឆ្នាំនីមួយៗនៅក្នុងរយៈពេលអនុវត្ត NDC របស់ជាតិ។[35]

- និយមន័យអំពីការ "ផ្ទេរលើកដំបូង" អាស្រ័យលើការប្រើប្រាស់ការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ដែលបានអនុញ្ញាត៖

    - ចំពោះការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ដែលបានអនុញ្ញាតឱ្យប្រើប្រាស់ឆ្ពោះទៅរកការចូលរួមចំណែករបស់ជាតិរបស់ប្រទេសដទៃទៀត ការ "ផ្ទេរលើកដំបូង" គឺជាការផ្ទេរជាអន្តរជាតិលើកដំបូងនៃការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់។

        - នៅក្នុងករណីដែលការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ឆ្ពោះទៅរកការសម្រេចឱ្យបាននូវការចូលរួមចំណែករបស់ជាតិរបស់ប្រទេសដទៃទៀតការទទួលបានការជូនដំណឹងពីម្ចាស់គម្រោងថា ការផ្ទេរជាអន្តរជាតិលើកដំបូងនៃការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ដែលបានអនុវត្តបានធ្វើឡើង គឺជា "ចំណុចគន្លឹះ" ដើម្បីឱ្យលេខាធិការដ្ឋានអាជ្ញាធរជាតិ ក្នុងការអនុវត្តវិធីសាស្ត្រកែតម្រូវឱ្យត្រូវគ្នាចំពោះសមតុល្យបញ្ចេញឧស្ម័នរបស់រាជរដ្ឋាភិបាលកម្ពុជា ស្មើទៅនឹងបរិមាណនៃការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ដែលបានផ្ទេរលើកដំបូង។

[35] សេចក្តីសម្រេចរបស់អនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC) លេខ ២/CMA.៣, ឧបសម្ព័ន្ធ កថាខណ្ឌ ៧។

- ចំពោះការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ដែលបានអនុញ្ញាត សម្រាប់គោលបំណងកាត់បន្ថយការបញ្ចេញឧស្ម័នជាលក្ខណៈអន្តរជាតិផ្សេងៗ ការ "ផ្ទេរលើកដំបូង" គឺជា ១) ការអនុញ្ញាត ឬ ២) ការចេញ ឬ ៣) ការប្រើប្រាស់ ឬការលុបចោល ការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ដូចដែលបានបញ្ជាក់នៅក្នុងលិខិតអនុញ្ញាត។[36]

## ការអនុវត្តវិធីសាស្ត្រកែតម្រូវឱ្យត្រូវគ្នា

- បន្ទាប់ពីការ "ផ្ទេរលើកដំបូង" នៃការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ដែលបានអនុញ្ញាតវិធីសាស្ត្រកែតម្រូវឱ្យត្រូវគ្នា នឹងត្រូវយកមកអនុវត្តចំពោះសមតុល្យការបញ្ចេញឧស្ម័នដែលរាយការណ៍នៅក្នុងព័ត៌មានទូទៅជូនដល់ UNFCCC ដែលដាក់ជូនជាឧបសម្ព័ន្ធនៃរបាយការណ៍តម្លាភាពពីរឆ្នាំម្តង។ សូមមើល "លក្ខខណ្ឌតម្រូវរាយការណ៍របស់ UNFCCC" នៅក្នុងអនុផ្នែកខាងក្រោម។
- រាជរដ្ឋាភិបាលកម្ពុជា នឹងប្រើប្រាស់វិធីសាស្ត្រ "មធ្យមភាគ" ដើម្បីអនុវត្តវិធីសាស្ត្រកែតម្រូវឱ្យត្រូវគ្នា សម្រាប់រាល់ការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ដែលបានអនុញ្ញាតទាំងអស់ដែលបានផ្ទេរជាលើកដំបូង។ វិធីសាស្ត្រ "មធ្យមភាគ" នេះ គឺមានរៀបរាប់លម្អិតនៅក្នុងសេចក្តីសម្រេចរបស់អនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC) លេខ ២/CMA.៣, ឧបសម្ព័ន្ធ កថាខណ្ឌ ៧ និងសង្ខេបជូននៅខាងក្រោម៖
  - រាជរដ្ឋាភិបាលកម្ពុជា ចាំបាច់ត្រូវធ្វើការគណនាចំនួនប្រចាំឆ្នាំជាមធ្យមនៃបរិមាណកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ដែលបានផ្ទេរជាអន្តរជាតិលើកដំបូង ដោយយកចំនួនបូកបញ្ចូលគ្នានៃបរិមាណការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ដែលបានផ្ទេរលើកដំបូង ចែកនឹងចំនួនឆ្នាំដែលបានកន្លងផុតនៅក្នុងរយៈពេលអនុវត្ត NDC។ វិធីសាស្ត្រកែតម្រូវឱ្យត្រូវគ្នា "ដាក់លាក់" គឺស្មើទៅនឹងចំនួនមធ្យមនេះ គណនាជាប្រចាំឆ្នាំ និងបន្ទាប់មក វិធីសាស្ត្រកែតម្រូវឱ្យត្រូវគ្នា គឺស្មើទៅនឹងចំនួនមធ្យមនេះ គណនានៅក្នុងឆ្នាំគោលដៅ NDC។
  - ការអនុវត្តវិធីសាស្ត្រកែតម្រូវឱ្យត្រូវគ្នា ដើម្បីគណនាសមតុល្យនៃការបញ្ចេញឧស្ម័នរបស់រាជរដ្ឋាភិបាលកម្ពុជា នឹងត្រូវរួមបញ្ចូលនៅក្នុងរបាយការណ៍អំពី "ព័ត៌មានទៀងទាត់" (ភ្ជាប់ជាឧបសម្ព័ន្ធនៃរបាយការណ៍តម្លាភាពពីរឆ្នាំម្តង) ជូនដល់អនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC)។

[36] OIMP សំដៅទៅលើទាំង "គោលបំណងកាត់បន្ថយអន្តរជាតិជាជាងសមិទ្ធិផលនៃការចូលរួមចំណែករបស់ជាតិផ្សេងទៀត" (ឧ. ប្រើប្រាស់នៅក្នុង CORSIA) និង "គោលបំណងផ្សេងទៀត" (ឧ. ការប្រើប្រាស់ដោយស្ម័គ្រចិត្ត)។

## **លក្ខខណ្ឌតម្រូវរាយការណ៍របស់អនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពី ការប្រែប្រួលអាកាសធាតុ** (UNFCCC)

- *ព័ត៌មានប្រចាំឆ្នាំ*
    - លេខាធិការដ្ឋាននៃ អាជ្ញាធរជាតិ នឹងបញ្ចូលព័ត៌មានប្រចាំឆ្នាំចូលទៅក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យនៃមាត្រា ៦ ដោយប្រើប្រាស់គំរូដែលផ្តល់ជូនដោយ UNFCCC។[37] ព័ត៌មានដែលមាននៅក្នុងរបាយការណ៍ប្រចាំឆ្នាំ រួមមានព័ត៌មានពាក់ព័ន្ធនឹងការចេញ ការផ្ទេរលើកដំបូង ការផ្ទេរ ការទិញ ការកាន់កាប់ ការលុបចោល និងការលុបចោលដោយស្ម័គ្រចិត្តនៃការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ដែលបានអនុញ្ញាត។
    - ព័ត៌មានប្រចាំឆ្នាំ ត្រូវតែដាក់ជូនជាប្រចាំឆ្នាំដោយមិនឱ្យលើសពីថ្ងៃទី១៥ ខែមេសានៃឆ្នាំបន្ទាប់ឡើយ។
- *ព័ត៌មានទៀងទាត់*
    - លេខាធិការដ្ឋាននៃអាជ្ញាធរជាតិ នឹងដាក់ជូន "ព័ត៌មានទៀងទាត់" ជូនដល់ UNFCCC ជា**ឧបសម្ព័ន្ធនេះរបាយការណ៍តម្លាភាពពីរឆ្នាំម្តងរបស់កម្ពុជា** ស្របតាមមាត្រា ១៣ នៃកិច្ចព្រមព្រៀងទីក្រុងប៉ារីស។ ការដាក់ ជូនព័ត៌មាននេះ ត្រូវធ្វើឡើងមិនឱ្យលើសពីថ្ងៃទី៣១ ខែធ្នូនៃឆ្នាំពាក់ព័ន្ធនោះទេ។
    - អនុសញ្ញាក្របខ័ណ្ឌអង្គការសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC) នឹងផ្តល់គំរូសម្រាប់ព័ត៌មានទៀងទាត់ជូន។
    - រាជរដ្ឋាភិបាលកម្ពុជា នឹងអនុវត្តវិធីសាស្ត្រកែតម្រូវឱ្យត្រូវគ្នាបែបចង្កូលបង្ហាញ សម្រាប់គ្រប់ការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ដែលបានអនុញ្ញាតដែលបានផ្ទេរលើកដំបូងទាំងអស់ ក្នុងអំឡុងពេលរាយការណ៍ពាក់ព័ន្ធ និងរាយការណ៍អំពីការផ្ទេរទាំងនេះនៅក្នុងព័ត៌មានទៀងទាត់។
    - ចំពោះ របាយការណ៍តម្លាភាពពីរឆ្នាំម្តងដែលមានចែងអំពីឆ្នាំគោលដៅនៃការចូលរួមចំណែករបស់ជាតិដើម្បីអនុវត្តអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (២០៣០) របស់កម្ពុជា វិធីសាស្ត្រកែតម្រូវឱ្យត្រូវគ្នា នឹងត្រូវអនុវត្តដោយប្រើប្រាស់វិធីសាស្ត្រមធ្យមភាគ ដើម្បីគណនារកសមតុល្យបញ្ចេញឧស្ម័ន។

[37] គំរូព្រាង គឺអាចស្វែងរកបាននៅ https://unfccc.int/documents/624366។

## ឧបសម្ព័ន្ធ៖ ឯកសារគំរូ

| លេខឧបសម្ព័ន្ធ | ឈ្មោះឯកសារ |
|---|---|
| ១ | សំណើសុំលិខិតគាំទ្រសម្រាប់គម្រោងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ |
| ២ | លិខិតគាំទ្រ |
| ៣ | សំណើសុំការអនុញ្ញាតសម្រាប់ការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ |
| ៤ | លិខិតអនុញ្ញាត |
| ៥ | សំណើត្រួតពិនិត្យវិជ្ជមានទៅលើការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ |
| ៦ | លិខិតត្រួតពិនិត្យវិជ្ជមាន |

## ១.សំណើសុំលិខិតគាំទ្រសម្រាប់គម្រោងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់

### សំណើសុំលិខិតគាំទ្រ

សេចក្តីណែនាំសម្រាប់ការបំពេញទម្រង់នេះ៖

- ទម្រង់ស្នើសុំនេះ ត្រូវដាក់ជូនជាទម្រង់អេឡិចត្រូនិក (MS Word) ទៅកាន់អាជ្ញាធរជាតិ។
- ដើម្បីសម្របសម្រួលដល់ដំណើរការដាក់ពាក្យស្នើសុំឱ្យបានទាន់ពេលវេលា សូមប្រាកដថាចន្លោះទាំងអស់គឺត្រូវបានបំពេញឱ្យបានពេញលេញ។ ប្រសិនបើមិនមានព័ត៌មានដែលបានស្នើសុំទេ សូមផ្តល់សេចក្តីពន្យល់សង្ខេបអំពីមូលហេតុដែលមិនមានព័ត៌មានទាំងនោះ។
- ឯកសារគាំទ្រខាងក្រោមនេះ ត្រូវតែដាក់ជូនអមជាមួយនឹងសំណើសុំលិខិតអនុញ្ញាតការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់នេះ៖
  - ឯកសារទស្សនទានគម្រោង
  - ឯកសារពាក់ព័ន្ធផ្សេងទៀត (ដូចជាការវាយតម្លៃផលប៉ះពាល់បរិស្ថាន)។

**សូមបំពេញគ្រប់ចន្លោះទាំងអស់នៅក្នុងតារាងខាងក្រោម៖**

| | |
|---|---|
| អង្គភាពអនុវត្តគម្រោង | |
| កាលបរិច្ឆេទដាក់ជូន | |
| សំណើសុំដាក់ឯកសារ៖<br><br>(សូមគូសសញ្ញា X ក្នុងប្រអប់ពាក់ព័ន្ធ)<br><br>ចំណាំ៖ ទម្រង់ពាក្យសុំនេះត្រូវតែភ្ជាប់មកជាមួយ PIN ដែលបានបញ្ចប់។ | ☐ ឯកសារទស្សនទានគម្រោង<br><br>☐ឯកសារពាក់ព័ន្ធផ្សេងទៀត (សូមបញ្ជាក់)៖ |
| **ក. ព័ត៌មានលម្អិតអំពីគម្រោង** | |
| ឈ្មោះគម្រោង | |
| តើគម្រោងនេះត្រូវបានអាជ្ញាធរជាតិពិនិត្យហើយឬនៅ? | ☐បាទ/ចាស<br><br>☐ទេ |

| | |
|---|---|
| ប្រសិនបើបាទ/ចាស សូមផ្តល់កាលបរិច្ឆេទនៃការដាក់ស្នើលើកដំបូង ថាតើវាជាពាក្យស្នើសុំលិខិតគាំទ្រ ឬលិខិតអនុញ្ញាត ហើយសង្ខេបលទ្ធផលនៃការពិនិត្យរបស់អាជ្ញាធរជាតិ (១-២ បន្ទាត់ប៉ុណ្ណោះ) | ប្រសិនបើបាទ/ចាស សូមផ្តល់កាលបរិច្ឆេទ និងសេចក្តីសង្ខេបនៃលទ្ធផលពិនិត្យ៖ |
| ទីតាំងគម្រោង | *សូមផ្តល់អាសយដ្ឋាន/ទីតាំង* |
| ប្រភេទនៃគម្រោង | □ការផ្គត់ផ្គង់ថាមពល<br>□តម្រូវការថាមពល<br>□ដំណើរការឧស្សាហកម្ម<br>□ការដឹកជញ្ជូន<br>□ការគ្រប់គ្រងកាកសំណល់<br>□ព្រៃឈើ/ការប្រើប្រាស់ដី<br>□ផ្សេងទៀត (សូមបញ្ជាក់)៖ |
| ឧស្ម័នផ្ទះកញ្ចក់គោលដៅ | សូមបញ្ជាក់ និងផ្តល់នូវបរិមាណប៉ាន់ស្មាននៃការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ពីគម្រោង (គិតជា $tCO_2eq$) |
| សូមបញ្ជាក់ពីរបៀបដែលគម្រោងការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ស្របតាម «បញ្ជីវិជ្ជមាន» នៃគម្រោងការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់របស់កម្ពុជា។ | |
| សូមបញ្ជាក់អំពីរបៀបដែលគម្រោងការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ក្នុងស្រុកត្រូវស្របតាមអាទិភាពនៃការអភិវឌ្ឍប្រកបដោយចីរភាពរបស់កម្ពុជា។ | សូមបំពេញតារាងទី២ ខាងក្រោមឱ្យបានច្រើនតាមដែលអាចធ្វើទៅបាន។ សូមកំណត់ការឆ្លើយតបចំពោះលក្ខណៈវិនិច្ឆ័យនីមួយៗត្រឹម២០០ពាក្យ។ |
| កាលបរិច្ឆេទចាប់ផ្តើមគម្រោង | |
| កាលបរិច្ឆេទបញ្ចប់គម្រោង | |
| ឆ្នាំដំបូងនៃការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ | |
| **ខ. ព័ត៌មានលម្អិតអំពី ម្ចាស់គម្រោង** | |
| ប្រភេទនៃអង្គការ | ជ្រើសរើសស្ថាប័នខាងក្រោម៖<br><br>□រដ្ឋាភិបាលជាតិ<br>□ទីភ្នាក់ងាររដ្ឋាភិបាល |

| | |
|---|---|
| | ☐រដ្ឋបាលខេត្ត<br>☐អាជ្ញាធរក្នុងស្រុក<br>☐ក្រុមហ៊ុនឯកជន<br>☐អង្គការក្រៅរដ្ឋាភិបាល<br>☐ផ្សេងទៀត (សូមបញ្ជាក់)៖ |
| អាសយដ្ឋាន | |
| អាសយដ្ឋានប្រៃសណីយ៍ (ប្រសិនបើខុសពីខាងលើ) | |
| ជនបង្គោល | |
| អាសយដ្ឋានអ៊ីម៉ែល | |
| លេខទូរស័ព្ទ | |

*តារាង២៖ ការពិនិត្យភាពស្របតាមរវាងគម្រោងនឹងសកម្មភាពអាទិភាពនៃការអភិវឌ្ឍប្រកបដោយចីរភាពរបស់កម្ពុជា*

| លក្ខណៈវិនិច្ឆ័យ | ព័ត៌មានលម្អិត |
|---|---|
| ***ប្រភេទ១. ការលើកកម្ពស់ប្រាក់ចំណូល និងគុណភាពជីវិតនៅក្នុងសង្គម*** | |
| ១.១ ការកាត់បន្ថយភាពក្រីក្រ | |
| ១.២ ការផ្តល់ហេដ្ឋារចនាសម្ព័ន្ធសហគមន៍ | |
| ១.៣ ការពិគ្រោះយោបល់ភាគីពាក់ព័ន្ធ | |
| ១.៤ លទ្ធភាពចូលប្រើប្រាស់ទ្រព្យសម្បត្តិក្នុងសហគមន៍ | |
| ១.៥ សមធម៌នៅក្នុងការទទួលបានផលប្រយោជន៍សហគមន៍របស់គម្រោងសម្រាប់សហគមន៍គោលដៅ | |
| ១.៦ ការបង្កើតការងារនៅក្នុងប្រទេស | |
| ១.៧ ឥទ្ធិពលទៅលើសុខភាពសាធារណៈ | |
| ១.៨ សមធម៌យេនឌ័រ | |
| ១.៩ ការបន្សាំ | |

| លក្ខណៈវិនិច្ឆ័យ | ព័ត៌មានលម្អិត |
| --- | --- |
| ***ប្រភេទ ២. ការផ្ទេរបច្ចេកវិទ្យា*** | |
| ២.១ ការផ្ទេរបច្ចេកវិទ្យាដែលមានលក្ខណៈសមស្រប និងល្អបំផុត | |
| ២.២ ការកសាងសមត្ថភាព | |
| ***ប្រភេទ ៣. អត្ថប្រយោជន៍ផ្នែកសេដ្ឋកិច្ច*** | |
| ៣.១ ការប្រើប្រាស់អាជីវកម្ម និងឧស្សាហកម្មក្នុងមូលដ្ឋាន | |
| ៣.១ ចំណែកនៃថវិកាគម្រោងដែលបានចំណាយនៅក្នុងប្រទេស | |
| ៣.៣ ការកាត់បន្ថយការពឹងផ្អែកទៅលើឥន្ទនៈហ្វូស៊ីល (គម្រោងថាមពលប៉ុណ្ណោះ) | |
| ៣.៤ ការកាត់បន្ថយការពឹងផ្អែកលើថាមពលនាំចូល (គម្រោងថាមពលប៉ុណ្ណោះ) | |

*ចប់*

## ២.លិខិតគាំទ្រសម្រាប់គម្រោងការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់

**លិខិតគាំទ្រ**

*[កាលបរិច្ឆេទ]*

លេខយោង៖

**ពី៖** រាជរដ្ឋាភិបាលកម្ពុជា

[ឈ្មោះ] អ្នកសម្របសម្រួលនៃអាជ្ញាធរជាតិ សម្រាប់យន្តការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់

**លិខិតគាំទ្រពាក់ព័ន្ធនឹង** *[ឈ្មោះគម្រោង]*

ក្នុងនាមជាអង្គភាពទទួលបន្ទុកដែលបានចាត់តាំងរបស់រាជរដ្ឋាភិបាលកម្ពុជា អាជ្ញាធរជាតិសម្រាប់យន្តការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ សូមបញ្ជាក់ថា អាជ្ញាធរជាតិផ្តល់លិខិតគាំទ្រលើ «[ឈ្មោះគម្រោង]» ។ [ឈ្មោះគម្រោង] គឺមានលក្ខណៈគ្រប់គ្រាន់ក្នុងការដាក់ពាក្យស្នើសុំការអនុញ្ញាតការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ដែលបង្កើតឡើងដោយគម្រោង ស្របតាមបទប្បញ្ញត្តិ និងនីតិវិធីដែលមានចែងក្នុងវិធានប្រតិបត្តិសម្រាប់មាត្រា ៦ នៃកិច្ចព្រមព្រៀងទីក្រុងប៉ារីសស្តីពីការប្រែប្រួលអាកាសធាតុនៅកម្ពុជា។

លិខិតគាំទ្រនេះមិនធានាថា ការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ណាមួយដែលបង្កើតឡើងដោយគម្រោងនេះនឹងត្រូវបានអនុញ្ញាតដោយអាជ្ញាធរជាតិសម្រាប់ការផ្ទេរការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ អន្តរជាតិក្រោមមាត្រា ៦ នៃកិច្ចព្រមព្រៀងទីក្រុងប៉ារីសនោះទេ។

លិខិតគាំទ្រត្រូវបានចុះហត្ថលេខាដោយ [ឈ្មោះ] អ្នកសម្របសម្រួលនៃអាជ្ញាធរជាតិសម្រាប់យន្តការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់នៃរាជរដ្ឋាភិបាលកម្ពុជា។

……………………………………………..

**[ឈ្មោះ]**

**អ្នកសម្របសម្រួលនៃអាជ្ញាធរជាតិសម្រាប់យន្តការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់**

**អាជ្ញាធរចេញលិខិតៈ**

ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព

ជាន់ទី ៣ អគារមរតកតេជោ ដីឡូត៍លេខ ៥០៣ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ

ព្រះរាជាណាចក្រកម្ពុជា

gssdadmin@camclimate.org.kh

*ចប់*

## ៣ .ស្នើសុំលិខិតអនុញ្ញាតកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់

**សំណើសុំការអនុញ្ញាតសម្រាប់ការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់**

សេចក្តីណែនាំសម្រាប់ការបំពេញទម្រង់នេះ៖

- ទម្រង់ស្នើសុំនេះ ត្រូវដាក់ជូនជាទម្រង់អេឡិចត្រូនិក (MS Word) ទៅកាន់ អាជ្ញាធរជាតិ។
- ដើម្បីសម្របសម្រួលដល់ដំណើរការដាក់ពាក្យស្នើសុំឱ្យបានទាន់ពេលវេលា សូមប្រាកដថាចន្លោះទាំងអស់គឺត្រូវបានបំពេញឱ្យបានពេញលេញ។ ប្រសិនបើមិនមានព័ត៌មានដែលបានស្នើសុំទេ សូមផ្តល់សេចក្តីពន្យល់សង្ខេបអំពីមូលហេតុដែលមិនមានព័ត៌មានទាំងនោះ។
- មុនការចេញលិខិតអនុញ្ញាត ម្ចាស់គម្រោងត្រូវបង់ថ្លៃសេវាជូនអាជ្ញាធរជាតិ តាមការណែនាំដែលត្រូវបង្កើតដោយក្រសួងបរិស្ថាន។
- ឯកសារគាំទ្រខាងក្រោមនេះ ត្រូវតែដាក់ជូនអមជាមួយនឹងសំណើសុំលិខិតអនុញ្ញាត ការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់នេះ៖
    - លិខិតគាំទ្រ (ប្រសិនជាមាន)
    - ឯកសារស្តីពីការរចនាគម្រោង
    - របាយការណ៍សុពលកម្ម
    - លិខិតអនុញ្ញាតដែលទទួលបានកន្លងមក (ចំពោះការស្នើសុំបន្តរយៈពេលអនុញ្ញាតប៉ុណ្ណោះ)

**សូមបំពេញគ្រប់ចន្លោះទាំងអស់នៅក្នុងតារាងខាងក្រោម៖**

| | |
|---|---|
| អង្គភាពអនុវត្តគម្រោង | |
| កាលបរិច្ឆេទដាក់ជូន | |
| **ក. ព័ត៌មានលម្អិតអំពីគម្រោង** | |
| ឈ្មោះគម្រោង | |

| | |
|---|---|
| សំណើសុំដាក់ឯកសារៈ<br><br>(សូមគូសសញ្ញា X នៅក្នុងប្រអប់ពាក់ព័ន្ធ)<br><br>សម្គាល់៖ ចំពោះសំណើសុំពាក់ព័ន្ធនឹងការបន្តរយៈពេលអនុញ្ញាត នោះចាំបាច់ត្រូវដាក់ជូនទាំងលិខិតអនុម័ត និងលិខិតអនុញ្ញាតច្បាប់ដើម | ☐សំណើសុំការអនុញ្ញាត<br><br>☐សំណើសុំបន្តរយៈពេលអនុញ្ញាត |
| តើពីមុនមក អាជ្ញាធរជាតិធ្លាប់បានបដិសេធសំណើសុំការអនុញ្ញាតពាក់ព័ន្ធនឹងគម្រោងការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់នេះដែរឬទេ?<br><br>ប្រសិនបើធ្លាប់ សូមផ្តល់កាលបរិច្ឆេទនៃការដាក់ឯកសារជូនដំបូង និងមូលហេតុនៃការបដិសេធ (១-២ បន្ទាត់ប៉ុណ្ណោះ) | ☐ធ្លាប់<br><br>☐មិនធ្លាប់ |
| | ប្រសិនបើធ្លាប់ សូមផ្តល់មូលហេតុនៃការបដិសេធ៖ |
| បញ្ជាក់អំពីបរិមាណ (គិតជា $tCO_2eq$) នៃការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ដែលកំពុងស្នើសុំការអនុញ្ញាត | |
| **ខ. ការបន្សុីទៅនឹងលក្ខណៈវិនិច្ឆ័យសិទ្ធិ** | |
| ១. សូមបញ្ជាក់ថាគម្រោងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់មានភាពស្របគ្នាជាមួយនឹង «បញ្ជីវិជ្ជមាន» នៃគម្រោងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់របស់កម្ពុជា។<br>តើពីមុនមក អ្នកធ្លាប់បានទទួលលិខិតអនុម័តសម្រាប់គម្រោងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់មានស្រាប់ដែរឬទេ? | |
| ២. សូមបញ្ជាក់អំពីចំណែកនៃការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ដែលនឹងត្រូវរក្សាទុកសម្រាប់ការប្រើប្រាស់ក្នុងស្រុក (ឧ. ដែលនឹងមិនត្រូវបានអនុញ្ញាត) | |

| | |
|---|---|
| ៣. សូមបញ្ជាក់អំពីរយៈពេលដែលស្នើសុំការអនុញ្ញាត (កាលបរិច្ឆេទចាប់ផ្តើម-កាលបរិច្ឆេទបញ្ចប់) | |
| ៤. សូមបញ្ជាក់អំពីប្រភេទយន្តការកាបូនដែលត្រូវ ឬនឹងត្រូវចុះបញ្ជីគម្រោងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ | ☐យន្តការទ្វេភាគី<br>☐យន្តការឯករាជ្យ<br>☐យន្តការមាត្រា ៦.៤ |
| | ឈ្មោះយន្តការកាបូន៖ |
| | លេខចុះបញ្ជីនៃគម្រោងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ប្រសិនបើពាក់ព័ន្ធ)៖ |
| ៥. បញ្ជាក់ថាតើគម្រោងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់មានស្រាប់ ធានាបាននូវសុចរិតភាពបរិស្ថាននៅក្នុងទិដ្ឋភាពខាងក្រោមបានដូចម្តេច៖<br><br>សូមមើលឯកសារ និង/ឬរបាយការណ៍ សុពលកម្មនៃការរចនាគម្រោងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ប្រសិនបើពាក់ព័ន្ធ | *កម្រិតមូលដ្ឋាន គឺត្រូវបានកំណត់ដោយប្រុងប្រយ័ត្ន និងនៅក្រោមការព្យាករណ៍ការបញ្ចេញឧស្ម័ន "ការព្យាករណ៍តាមទម្លាប់ធម្មតា"។ សូមកម្រិតការឆ្លើយតបក្រោម ៣០០ ពាក្យ។* |
| | *ហានិភ័យនៃការកាត់បន្ថយការបញ្ចេញឧស្ម័នមិនអចិន្ត្រៃយ៍ គឺត្រូវបានកាត់បន្ថយ។ សូមកម្រិតការឆ្លើយតបក្រោម ៣០០ ពាក្យ។* |

| | |
|---|---|
| ៦. សូមបញ្ជាក់អំពីរបៀបដែលគម្រោងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ត្រូវបានបន្សីជាមួយសកម្មភាពអាទិភាពអភិវឌ្ឍន៍ ប្រកបដោយចីរភាពរបស់កម្ពុជា។ | *សូមបំពេញតារាង ២ នៅខាងក្រោមពាក្យស្នើសុំនេះ។ សូមកម្រិតចម្លើយចំពោះលក្ខណៈវិនិច្ឆ័យនីមួយៗ ក្រោម ៣០០ ពាក្យ។* |
| **គ. ព័ត៌មានលម្អិតអំពីភាគីទិញ** | |
| តើភាគីទិញសម្រាប់ការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ដែលបានអនុញ្ញាត ត្រូវបានកំណត់អត្តសញ្ញាណដែរឬទេ? | ☐បាទ/ចាស – សូមបំពេញផ្នែក គ<br>☐ទេ – សូមរំលងទៅផ្នែក ឃ |
| ប្រភេទភាគីទិញ | ☐រដ្ឋាភិបាលជាតិ (ឬអ្នកតំណាងមានសិទ្ធិ)<br>☐ភាគីទិញផ្សេងទៀត |
| សូមបញ្ជាក់អំពីការប្រើប្រាស់ការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ដែលកំពុងតែស្នើសុំការអនុញ្ញាត (សូមជ្រើសរើសចំណុចទាំងអស់ដែលពាក់ព័ន្ធ) | ☐ប្រើប្រាស់ដើម្បីសម្រេចបាននូវ NDC<br>☐គោលបំណងកាត់បន្ថយអន្តរជាតិផ្សេងទៀត |
| តើប្រទេសដែលភាគីទិញ ធ្លាប់ចុះកិច្ចព្រមព្រៀងក្របខ័ណ្ឌសម្រាប់ការសហការមាត្រា ៦.២ ជាមួយ រាជរដ្ឋាភិបាលកម្ពុជាដែរឬទេ?[38] | ☐ធ្លាប់<br>☐មិនធ្លាប់<br>ប្រសិនបើធ្លាប់ សូមបញ្ជាក់ឈ្មោះប្រទេស៖ |
| **ឃ. ការទទួលស្គាល់ និងការបញ្ជាក់** | |
| ខ្ញុំ (ម្ចាស់គម្រោង) សូមទទួលស្គាល់ថា លិខិតអនុញ្ញាតដែលបានផ្តល់ជូនដោយរាជរដ្ឋាភិបាលកម្ពុជា គឺមានលក្ខណៈយថាភូត នៅពេលទទួលបានលិខិតត្រួតពិនិត្យវិជ្ជមាន ដែលនឹងត្រូវផ្តល់ជូនបន្ទាប់ពីការដាក់ជូនសំណើសុំការត្រួតពិនិត្យវិជ្ជមាន និងរបាយការណ៍ផ្ទៀងផ្ទាត់សម្រាប់ គម្រោងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់។ | |
| ខ្ញុំ (ម្ចាស់គម្រោង) សូមប្រកាសអំពីការប្រកាន់ខ្ជាប់ទៅតាមច្បាប់ និងបទប្បញ្ញត្តិស្តីពីការវាយតម្លៃផលប៉ះពាល់បរិស្ថាន និងសង្គម (ESIA) នៃព្រះរាជាណាចក្រកម្ពុជា ក៏ដូចជាការការពារបរិស្ថាន និងសង្គម ដាក់លាក់តាមយន្តការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ដែលគម្រោងនេះស្នើសុំ។ | |

[38] សូមកត់សម្គាល់ថា ប្រសិនបើអង្គភាពភាគីទិញ មានមូលដ្ឋាននៅក្នុងប្រទេសដែលបានចុះកិច្ចព្រមព្រៀងក្របខណ្ឌសម្រាប់ការសហការ មាត្រា ៦.២ ជាមួយរាជរដ្ឋាភិបាលកម្ពុជា នោះលក្ខខណ្ឌបន្ថែមនានាដែលមានចែងនៅក្នុងកិច្ចព្រមព្រៀងក្របខ័ណ្ឌ នឹងអនុវត្តចំពោះសំណើសុំការអនុញ្ញាតនេះ។

| | |
|---|---|
| ខ្ញុំ (ម្ចាស់គម្រោង) សូមប្រកាសថានឹងចៀសចាងពីការចុះបញ្ជីជាន់គ្នាសម្រាប់គម្រោងតែមួយនៅក្រោមយន្តការការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ពីរ ឬច្រើន ដែលនាំឱ្យមានការរាប់ទ្វេដង និងទទួលស្គាល់ការលុបចោលឥណទាន និងទណ្ឌកម្មពាក់ព័ន្ធក្នុងការមានការរាប់ទ្វេ។ | |
| ខ្ញុំ (ម្ចាស់គម្រោង) យល់ព្រមដាក់ជូនគម្រោងឱ្យបានទាន់ពេលវេលា ស្របតាមវិធាននានាដែលចែងដោយអាជ្ញាធរជាតិ។ | |
| ខ្ញុំ (ម្ចាស់គម្រោង) សូមទទួលស្គាល់ថា រាល់ព័ត៌មានទាំងអស់ដែលបានដាក់ជូនអាជ្ញាធរជាតិ គឺមានសង្គតិភាព សុក្រឹត និងពេញលេញប្រាកដមែន។ | |
| **ង. ព័ត៌មានទំនាក់ទំនងរបស់ម្ចាស់គម្រោង** | |
| អាសយដ្ឋានអ៊ីម៉ែល | |
| លេខទូរស័ព្ទ | |

*តារាង២៖ ការពិនិត្យភាពស្របតាមរវាងគម្រោងនឹងសកម្មភាពអាទិភាពនៃការអភិវឌ្ឍប្រកបដោយចីរភាពរបស់ កម្ពុជា*

| លក្ខណៈវិនិច្ឆ័យ | ព័ត៌មានលម្អិត |
|---|---|
| ***ប្រភេទ១. ការលើកកម្ពស់ប្រាក់ចំណូល និងគុណភាពជីវិតនៅក្នុងសង្គម*** | |
| ១.១ ការកាត់បន្ថយភាពក្រីក្រ | |
| ១.២ ការផ្តល់ហេដ្ឋារចនាសម្ព័ន្ធសហគមន៍ | |
| ១.៣ ការពិគ្រោះយោបល់ភាគីពាក់ព័ន្ធ | |
| ១.៤ លទ្ធភាពចូលប្រើប្រាស់ទ្រព្យសម្បត្តិក្នុងសហគមន៍ | |
| ១.៥ សមធម៌នៅក្នុងការទទួលបានផលប្រយោជន៍សហគមន៍របស់គម្រោងសម្រាប់សហគមន៍គោលដៅ | |
| ១.៦ ការបង្កើតការងារនៅក្នុងប្រទេស | |
| ១.៧ ឥទ្ធិពលទៅលើសុខភាពសាធារណៈ | |
| ១.៨ សមធម៌យេនឌ័រ | |

| លក្ខណៈវិនិច្ឆ័យ | ព័ត៌មានលម្អិត |
|---|---|
| ១.៩ ការបន្សុំ | |
| *ប្រភេទ ២. ការផ្ទេរបច្ចេកវិទ្យា* | |
| ២.១ ការផ្ទេរបច្ចេកវិទ្យាដែលមានលក្ខណៈសមស្រប និងល្អបំផុត | |
| ២.២ ការកសាងសមត្ថភាព | |
| *ប្រភេទ ៣. អត្ថប្រយោជន៍ផ្នែកសេដ្ឋកិច្ច* | |
| ៣.១ ការប្រើប្រាស់អាជីវកម្ម និងឧស្សាហកម្មក្នុងមូលដ្ឋាន | |
| ៣.១ ចំណែកនៃថវិកាគម្រោងដែលបានចំណាយនៅក្នុងប្រទេស | |
| ៣.៣ ការកាត់បន្ថយការពឹងផ្អែកទៅលើឥន្ធនៈហ្វូស៊ីល (គម្រោងថាមពលប៉ុណ្ណោះ) | |
| ៣.៤ ការកាត់បន្ថយការពឹងផ្អែកលើថាមពលនាំចូល (គម្រោងថាមពលប៉ុណ្ណោះ) | |

.........................................

**[ឈ្មោះ]**

*ចប់*

## ៤. លិខិតអនុញ្ញាតសម្រាប់ការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់

**លិខិតអនុញ្ញាត**

[*កាលបរិច្ឆេទ*]

លេខយោង៖

**ពី៖** រាជរដ្ឋាភិបាលកម្ពុជា

[ឈ្មោះ] ប្រធានអាជ្ញាធរជាតិសម្រាប់យន្តការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់

**លិខិតអនុញ្ញាតពាក់ព័ន្ធនឹង** [*ឈ្មោះគម្រោង*]

ក្នុងនាមជាអង្គភាពទទួលបន្ទុកដែលបានចាត់តាំងដោយរាជរដ្ឋាភិបាលកម្ពុជា ប្រធានអាជ្ញាធរជាតិសម្រាប់យន្តការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ សូមជូនដំណឹងដល់លោក/លោកស្រីថា "[ឈ្មោះគម្រោង]" ដែលបានចុះបញ្ជីជា [លេខគម្រោង] នៅក្នុងបញ្ជីការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ថ្នាក់ជាតិរបស់ប្រទេសកម្ពុជា គឺត្រូវបានអនុញ្ញាតឱ្យបង្កើតការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ (GHG ER) សម្រាប់ការផ្ទេរជាលក្ខណៈអន្តរជាតិស្របតាមមាត្រា ៦ នៃកិច្ចព្រមព្រៀងទីក្រុងប៉ារីសស្តីពីការប្រែប្រួលអាកាសធាតុ យោងតាមលក្ខខណ្ឌដែលមានចែងនៅក្នុងលិខិតនេះ។[39]

[39] ការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ដែលបានអនុញ្ញាត សំដៅក្នុងលិខិតអនុញ្ញាតនេះ គឺស្របតាមពាក្យថា "លទ្ធផលនៃការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ដែលផ្ទេរជាអន្តរជាតិ" (ITMOs) ដែលប្រើប្រាស់នៅក្នុងបរិបទនៃកិច្ចព្រមព្រៀងទីក្រុងប៉ារីស។

រាជរដ្ឋាភិបាលកម្ពុជា សូមបញ្ជាក់ថា៖

ក) កម្ពុជាបានអនុម័តលើកិច្ចព្រមព្រៀងទីក្រុងប៉ារីសនៅថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០១៧ និងបានដាក់ផែនការ ការចូលរួមចំណែករបស់ជាតិដើម្បីអនុវត្តអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (NDC) នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០។

ខ) គម្រោងនេះ គឺស្ថិតនៅក្នុងវិសាលភាពនៃការចូលរួមចំណែករបស់ជាតិដែលមានលក្ខខណ្ឌរបស់កម្ពុជា។

គ) ចំពោះការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ដែលបានផ្ទេរនៅក្រោមគម្រោងនេះ រាជរដ្ឋាភិបាលកម្ពុជា មិនប្រើប្រាស់ដើម្បីបង្ហាញអំពីសមិទ្ធផលនៃការចូលរួមចំណែករបស់ជាតិនោះទេ។

ឃ) ការចូលរួមរបស់កម្ពុជានៅក្នុងវិធីសាស្រ្តសហការពាក់ព័ន្ធនឹងគម្រោងនេះ គឺជាការចូលរួមដោយស្ម័គ្រចិត្ត។

ង) គម្រោងនេះរួមចំណែកដល់ការអភិវឌ្ឍប្រកបដោយចីរភាពនៅកម្ពុជា និង

ច) រាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តតាមលក្ខខណ្ឌតម្រូវទាំងអស់របស់កិច្ចព្រមព្រៀងទីក្រុងប៉ារីស រួមទាំងការ រាយការណ៍ ការបង្ការការរាប់ទ្វេដង និងការអនុវត្ត វិធីសាស្រ្តកែតម្រូវឱ្យត្រូវគ្នាតាមការចាំបាច់។

រាជរដ្ឋាភិបាលកម្ពុជា សូមអនុញ្ញាតឱ្យ [អង្គភាពអនុវត្តគម្រោង] សម្របសម្រួល គ្រប់គ្រង និងអនុវត្តគម្រោងក្នុង នាមជាអង្គភាពសម្របសម្រួល គ្រប់គ្រង និងចុះកិច្ចព្រមព្រៀងសម្រាប់ការផ្ទេរបរិមាណការកាត់បន្ថយការបញ្ចេញ ឧស្ម័នផ្ទះកញ្ចក់ [ក្នុងបរិមាណដែលបានអនុញ្ញាតអតិបរិមា] ដែលបានបង្កើតឡើងដោយគម្រោងសម្រាប់រយៈពេល [រយៈពេលអនុញ្ញាត]។

[អង្គភាពអនុវត្តគម្រោង] ត្រូវបានផ្តល់សិទ្ធិកម្មសិទ្ធិទាក់ទងនឹង [ទាំងអស់] ការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ដែលបានអនុញ្ញាតដែលបង្កើតឡើងដោយគម្រោង។

លក្ខខណ្ឌនៅក្នុងតារាងខាងក្រោមនេះ ត្រូវអនុវត្តចំពោះលិខិតអនុញ្ញាតនេះ៖

| **សមាសធាតុនៃការអនុញ្ញាត** | **ព័ត៌មានលម្អិត** |
|---|---|
| **វិធីសាស្រ្តសហការដែលបានអនុញ្ញាត** | [សូមបញ្ចូលឈ្មោះគម្រោង GHG ER] |
| អង្គភាពដែលបានអនុញ្ញាត | [សូមបញ្ចូលឈ្មោះអង្គភាពអនុវត្តគម្រោង GHG ER] |
| បរិមាណអតិបរិមាបូកបង្គរសរុបនៃការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ដែល | [សូមបញ្ចូល $tCO_2eq$ ដែលគ្របដណ្តប់លើឆ្នាំទាំងអស់នៃវិធីសាស្រ្តសហការ] |

| | |
|---|---|
| បានអនុញ្ញាតឱ្យផ្ទេរជាអន្តរជាតិ និងប្រើប្រាស់ | |
| រយៈពេលអនុញ្ញាត | [ឆ្នាំដែលបរិមាណខាងលើអាចនឹងត្រូវបានបង្កើតឡើងសម្រាប់ការផ្ទេរជាអន្តរជាតិស្របតាមមាត្រា ៦.២] |
| រយៈពេល NDC ដែលក្នុងរយៈពេលនោះ GHG ER គឺត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ | [សូមបញ្ចូលឆ្នាំនៃរយៈពេល NDC] |
| ការចេញយន្តការកាបូន | [សូមបញ្ចូលឈ្មោះ យន្តការកាបូនដែល GHG ER ដែលបានអនុញ្ញាត នឹងត្រូវចេញជូន] |
| ការប្រើប្រាស់ដែលបានអនុញ្ញាតសម្រាប់ GHG ER | ក. ☐ប្រើប្រាស់សម្រាប់សមិទ្ធផលនៃ ការចូលរួមចំណែករបស់ជាតិ<br>ខ. ☐ប្រើប្រាស់សម្រាប់គោលបំណងកាត់បន្ថយអន្តរជាតិផ្សេងៗ |
| | ប្រសិនបើ ខ នោះ GHG ER ដែលបានអនុញ្ញាត នឹងត្រូវចាត់ទុកថា "បានផ្ទេរលើកដំបូង" នៅពេល៖<br>☐ការអនុញ្ញាត<br>☐ការចេញ<br>☐ការប្រើប្រាស់ ឬការលុបចោល |

តាមរយៈលិខិតនេះ រាជរដ្ឋាភិបាលកម្ពុជា សូមប្តេជ្ញាថា រដ្ឋាភិបាលត្រូវគាំទ្រដល់ការផ្ទេរ និងគណនាបរិមាណនៃការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ពីគម្រោងនេះស្របតាមលក្ខខណ្ឌតម្រូវរបស់កិច្ចព្រមព្រៀងទីក្រុងប៉ារីស។

លិខិតអនុញ្ញាតនេះមានលក្ខណៈយថាភូត នៅពេលទទួលបានលិខិតត្រួតពិនិត្យវិជ្ជមាន ដែលនឹងត្រូវចេញជូនដោយអាជ្ញាធរជាតិសម្រាប់យន្តការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ នៅមុនពេលការចេញ និងការផ្ទេរលើកដំបូងនៃ ការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ដែលបានអនុញ្ញាតដែលយោងនៅក្នុងលិខិតអនុញ្ញាតនេះ។

*លិខិតអនុញ្ញាតនេះ គឺត្រូវបានចុះហត្ថលេខាដោយ [ឈ្មោះ]* ប្រធានអាជ្ញាធរជាតិសម្រាប់យន្តការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ *នៃរាជរដ្ឋាភិបាលកម្ពុជា។*

……………………………………………..

**[ឈ្មោះ]**

**ប្រធានអាជ្ញាធរជាតិសម្រាប់យន្តការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់**

**អាជ្ញាធរចេញលិខិតៈ**

ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព

ជាន់ទី ៣ អគារមរតកតេជោ ដីឡូត៍លេខ ៥០៣ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ

ព្រះរាជាណាចក្រកម្ពុជា

gssdadmin@camclimate.org.kh

*ចប់*

## ៥. សំណើសុំការត្រួតពិនិត្យវិជ្ជមាន

**សំណើសុំការត្រួតពិនិត្យវិជ្ជមាន**

សេចក្តីណែនាំសម្រាប់ការបំពេញទម្រង់នេះ៖

- ទម្រង់ស្នើសុំនេះ ត្រូវដាក់ជូនជាទម្រង់អេឡិចត្រូនិក (MS Word) ទៅកាន់ អាជ្ញាធរជាតិ។
- ដើម្បីសម្របសម្រួលដល់ការដំណើរការពាក្យស្នើសុំឱ្យបានទាន់ពេលវេលា សូមប្រាកដថាចន្លោះទាំងអស់គឺត្រូវបានបំពេញឱ្យបានពេញលេញ។ ប្រសិនបើមិនមានព័ត៌មានដែលបានស្នើសុំទេ សូមផ្តល់សេចក្តីពន្យល់សង្ខេបអំពីមូលហេតុដែលមិនមានព័ត៌មានទាំងនោះ។
- ឯកសារគាំទ្រខាងក្រោមនេះ ត្រូវតែដាក់ជូនអមជាមួយនឹងសំណើសុំការត្រួតពិនិត្យវិជ្ជមាននៃការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់នេះ៖
